ព្រះរាជាណាចក្រកម្ពុជា

# សំណួរ_ចម្លើយ

# សីលធម៌_ពលរដ្ឋ

## ១១



ស្របតាមកម្មវិធីសិក្សាថ្មី

# អារម្ភកថា

សួស្តីៗ ! ប្អូនៗសិស្សានុសិស្ស ប្រិយមិត្តអ្នកអានទាំងអស់ជាទីស្រឡាញ់រាប់អាន ។

ដើម្បីឆ្លើយតបតាមតម្រូវការ និង បង្កើនសមត្ថភាពការយល់ដឹងរបស់ប្អូនៗសិស្សានុសិស្ស ក៏ដូចជាមិត្តអ្នកអាន អ្នកស្រាវជ្រាវទាំងអស់។ ខ្ញុំបាទបានឆ្លៀតឱកាសដ៏មមាញឹក ដើម្បីបង្កើតជាកូនសៀវភៅវិញ្ញាសាសំណួរ_ចម្លើយ មុខវិជ្ជា សីលធម៌_ពលរដ្ឋវិជ្ជា **ថ្នាក់ទី ១១ថ្មី**នេះឡើងស្របតាមកម្មវិធីសិក្សាថ្មីរបស់ក្រសួងអប់រំយុវជន និង កីឡា(ឆ្នាំ២០១០)។

ខ្ញុំសង្ឃឹមនិងជឿជាក់ថា កូនសៀវភៅនេះនឹងអាចបំពេញនូវសេចក្តីត្រូវការបានយ៉ាងច្រើន ។

ទោះជាមានការពិនិត្យពិច័យល្អិតល្អន់យ៉ាងណាក៏ដោយ ក៏ខ្ញុំបាទជឿជាក់ថា នៅតែមានកំហុសមិនខាន ចៀសមិនផុតឡើយ ដូចជា កំហុសអក្ខរាវិរុទ្ធ កំហុសបច្ចេកទេសក្នុងការរៀបរៀងជួរអក្សរ រចនាបថ និង រៀបចំពាក្យពេចន៍ជាដើម ។

ខ្ញុំបាទនៅរង់ចាំទទួលនូវការរិះគន់កែលម្អ ក្នុងន័យស្ថាបនា ពីគ្រប់មជ្ឈដ្ឋាន ដើម្បីជាពន្លឺដល់ការស្រាវជ្រាវបន្ត ។

សូមអរគុណ !

រៀបរៀង និង ចងក្រងដោយ

**លោក សំ ម៉ុនណា**

សាស្ត្រាចារ្យនៃវិទ្យាល័យ ជា ស៊ីមបឹងកេងកង

# បញ្ជីអត្ថបទ


| ជំពូក | មេរៀន | ទំព័រ |
|---|---|---|
| ជំពូក I | 1. ភាពជាមនុស្សមានតម្លៃ | 02 ☛ 11 |
| | 2. ព្រហ្មវិហារធម៌ | 12 ☛ 23 |
| | 3. ធម៌អហិង្សា | 24 ☛ 33 |
| | 4. សច្ចធម៌ | 34 ☛ 41 |
| | 5. សេរីភាព | 42 ☛ 47 |
| | 6. ឯករាជភាព | 48 ☛ 53 |
| | 7. ការវិនិច្ឆ័យ | 54 ☛ 57 |
| | 8. ការអធ្យាស្រ័យ និងការសន្ដោស | 58 ☛ 66 |
| | 9. សុចរិតធម៌ | 67 ☛ 73 |
| | 10. កម្លាភាព | 74 ☛ 77 |
| | 11. សាមគ្គីធម៌ | 78 ☛ 87 |
| ជំពូក II | 1. ប្រវត្តិកំណើតសាសនា | 88 ☛ 95 |
| | 2. ស្ថាបនាព្រះសង្ឃ និងវត្ត | 96 ☛ 100 |
| | 3. វត្តអារាម និងព្រះសង្ឃនៅកម្ពុជា | 101 ☛ 107 |
| | 4. ភាពជាបព្វជិតក្នុងព្រះពុទ្ធសាសនាថេរវាទ | 108 ☛ 116 |
| | 5. ព្រះពុទ្ធសាសនាមហាយាន | 117 ☛ 123 |
| | 6. ភាពជាបព្វជិតក្នុងសាសនាគ្រិស្ដ | 124 ☛ 127 |
| | 7. ភាពជាបព្វជិតក្នុងសាសនាឥស្លាម | 128 ☛ 133 |
| | 8. ភាពជាបព្វជិតក្នុងសាសនាតៅ | 134 ☛ 137 |
| | 9. ការប្រតិបត្តិសាសនាក្នុងសង្គមបច្ចុប្បន្ន | 138 ☛ 140 |
| | 10. គុណវិបត្តិនៃគ្រឿងញៀន | 141 ☛ 148 |
| | 11. គុណវិបត្តិនៃសុរា និងបារី | 149 ☛ 154 |
| | 12. ការតាំងចិត្ត | 155 ☛ 167 |
| ជំពូក III | 1. លទ្ធិប្រជាធិបតេយ្យ | 168 ☛ 173 |
| | 2. សិទ្ធិពលរដ្ឋ | 174 ☛ 177 |
| | 3. សិទ្ធិនិងការទទួលខុសត្រូវ | 178 ☛ 184 |
| | 4. តួនាទីពលរដ្ឋក្នុងសហគមន៍ | 185 ☛ 188 |
| | 5. ច្បាប់ការងារ | 189 ☛ 193 |
| | 6. ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ | 194 ☛ 200 |
| | 7. ក្រមនីតិវិធីរដ្ឋប្បវេណី | 201 ☛ 206 |
| | 8. ក្រមនីតិវិធីព្រហ្មទណ្ឌ | 207 ☛ 210 |
| | 9. ច្បាប់ភូមិបាល | 211 ☛ 214 |
| | 10. វប្បធាបេសាករណៈ | 215 ☛ 217 |
| | 11. គណបក្សនយោបាយ និងតួនាទី | 218 ☛ 221 |
| | 12. ការពបរឈ្មោះ និងការបោះឆ្នោត | 222 ☛ 237 |

## ជំពូក I : តម្លៃមនុស្ស

# មេរៀនទី១ : ការច្នៃប្រឌិត

## I. ពន្យល់ពាក្យ

- ទេពកោសល្យ : សមត្ថភាពឈ្លាសវៃបំផុតរបស់មនុស្ស ។

## II. *ចូរបំពេញល្បះឱ្យបានត្រឹមត្រូវ :*

១. ប្រាក់ ផ្ទះ ចំណីអាហារ ។ល ។ ជាវត្ថុមាន តម្លៃ ព្រោះវាជាអ្វីដែលមនុស្សប្រាថ្នាចង់បាន ប៉ុន្តែអ្វីដែលមានតម្លៃលើសពីមាសប្រាក់ទៅទៀតនោះគឺ..***គំនិត***.. ។

២. តម្លៃរបស់បុគ្គលម្នាក់ៗប្រមូលផ្ដុំគ្នាចងក្រងជា..***ប្រព័ន្ធតម្លៃមួយ***..ហើយរៀបចំទៅតាមការវិនិច្ឆ័យរបស់មនុស្សម្នាក់ៗដែលយល់ថាសំខាន់ចំពោះគេ ។

៣. តម្លៃរបស់យើងត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈ..***អាកប្បកិរិយា***.. និង..***ការប្រព្រឹត្ត***..ដែលបានបង្ហាញចំពោះអ្នកដទៃ ។

៤. មានទិដ្ឋភាពពីរក្នុងការឱ្យតម្លៃចំពោះការជ្រើសរើសគឺ..***ការចេះស្រឡាញ់***.. និង..***ការចេះឱ្យតម្លៃ***..ទៅលើអ្វី

ដែលខ្លួនបានជ្រើសរើសយក ។

៥. មនុស្សដែលមានករុណា តែងតែស្តែងចេញនូវមនោសញ្ចេតនាអាណិតអាសូរតាមរយៈ...***ការបរិច្ចាគទាន***... ។

៦. ទោសៈ ជាបដិបក្ខនឹង..***មេត្តា***..។

## III. សំនួររំលឹក

**សំនួរទី ១. តើតម្លៃជាអ្វី ? តើមនុស្សម្នាក់ៗ ត្រូវមានតម្លៃអ្វីខ្លះ ? ចូរផ្តល់ឧទាហរណ៍ ។**

**ចម្លើយ តម្លៃ** ជាលក្ខណៈនៃអ្វីដែលគេប្រាថ្នា ឬ អ្វីដែលគួរឱ្យចង់បាន ឬ ជាអ្វីដែលគេជ្រើសរើសយក ។

ឧទាហរណ៍ : ប្រាក់ ផ្ទះ ចំណីអាហារ។ល ។

មនុស្សម្នាក់ៗត្រូវមានតម្លៃដូចខាងក្រោម :

- **តម្លៃផ្ទាល់ខ្លួន** បានដល់ការស្គាល់តម្លៃខ្លួនឯងច្បាស់ និងការឱ្យតម្លៃខ្លួនឯង ការគោរពខ្លួនឯង ការថែទាំសុខភាព ភាពស្ងប់ស្ងាត់ខាងផ្លូវចិត្ត សមត្ថភាព ការច្នៃប្រឌិត ការចេះគ្រប់គ្រងខ្លួនឯ[illegible] ស្នាដៃដែលធ្វើអ្វីមួយបានសម្រេច និងអាជីកំបាំងផ្ទាល់ខ្លួន ។

**ឧទាហរណ៍** : ខ្ញុំដឹងថាអ្វីខុស អ្វីត្រូវ ។

[illegible]ម្លៃគ្រួសារ [illegible]ានការខិតខំរក និង ថែរក្សាទ្រព្យសម្បត្តិ

សន្សំសំចៃ ទំនាក់ទំនងល្អរវាងសមាជិកគ្រួសារ ការចិញ្ចឹមបីបាច់ ថែរក្សាក្រុមគ្រួសារ ការដឹងគុណ ការតបគុណ ការចេះជួយគ្នា ការអធ្យាស្រ័យគ្នា ការស្តាប់បង្គាប់ ការចេះព្រួយបារម្ភឈឺឆ្អាលគ្នា ប្រកាន់ខ្ជាប់ប្រពៃណី ទំនៀមទម្លាប់ល្អ ។ល ។

**ឧទាហរណ៍** : ខ្ញុំស្តាប់បង្គាប់ឪពុកម្តាយខ្ញុំ ។

- **តម្លៃស្មារតី ឬសីលធម៌** មានការស្រឡាញ់ មេត្តាធម៌ ការគោរព សេចក្តីទុកចិត្ត ការប្តេជ្ញាចិត្ត សេចក្តីសង្ឃឹម ការតាំងចិត្ត ការគោរពបូជា ។

**ឧទាហរណ៍** : ខ្ញុំស្រឡាញ់មិត្តភក្តិខ្ញុំ ខ្ញុំជួយទុក្ខធុរៈពួកគេ

- **តម្លៃការងារ** មានក្រមសីលធម៌ការងារ មនសិការការងារ ការចេះច្នៃប្រឌិត ផលិតផលមានគុណភាព ការទទួលបានលទ្ធផលល្អ ស្នាដៃការងារ ការគោរពពេលវេលាធ្វើការងារ គោរពវិន័យ ការទទួលខុសត្រូវ ការដឹកនាំល្អ ការងារស្របច្បាប់ ការងារសុចរិត ។

**ឧទាហរណ៍** : ខ្ញុំគោរពពេលវេលាធ្វើបានយ៉ាងទៀងទាត់ ។

- **តម្លៃវប្បធម៌** មានការថែរក្សា និងការអភិរក្សកេរដំណែលវប្បធម៌ទំនៀមទម្លាប់ប្រពៃណីពិធីរៀបអាពាហ៍ពិពាហ៍ ។ល ។

**ឧទាហរណ៍** : ការថែរក្សាប្រាសាទបុរាណនានា ។

- **តម្លៃសង្គម និងមនុស្សធម៌** មានការចេះជួយគ្នាទៅវិញទៅមក ការទទួលខុសត្រូវក្នុងសង្គម ការបម្រើសហគមន៍ ការស្គាល់តួនាទីខ្លួនជាពលរដ្ឋ ការគោរពច្បាប់សង្គមជាដើម ។

**<u>សំនួរទី ២.</u> ដើម្បីរក្សាតម្លៃរបស់ខ្លួន តើមនុស្សម្នាក់ៗត្រូវធ្វើដូចម្ដេចខ្លះ ?**

**<u>ចម្លើយ</u>** ដើម្បីរក្សាតម្លៃរបស់ខ្លួនមនុស្សម្នាក់ៗត្រូវ :

- ចេះឱ្យតម្លៃលើខ្លួនឯង
- ត្រូវមានចំណង់ចំណូលចិត្ត ចេះស្រឡាញ់អ្វីដែលខ្លួនបានជ្រើសរើស
- ត្រូវមានចំណេះដឹងជ្រាលជ្រៅ
- ត្រូវចេះច្នៃប្រឌិត
- ត្រូវចេះគ្រប់គ្រង
- ត្រូវមានជំហរមួយច្បាស់លាស់
- ត្រូវមានកិរិយាបថសមរម្យ សុភាពរាបសារ ថ្លៃថ្នូរ
- ត្រូវចេះទទួលខុសត្រូវនូវរាល់ទង្វើដែលខ្លួនបានធ្វើ

. ត្រូវមានយុត្តិធម៌ ស្មោះត្រង់

. ត្រូវចេះគោរពសិទ្ធិអ្នកដទៃ មិនក្រអឺតក្រទម រើសអើង ឬប្រមាថអ្នកដទៃ ។

. ត្រូវគោរពពាក្យសច្ចៈ មិននិយាយកុហក់ ។ល។

**<u>សំនួរទី ៣.</u> ចូរសរសេរតម្លៃដែលអ្នកប្រកាន់យកយ៉ាងខ្ជាប់ខ្ជួនឱ្យបាន ១០ ។ រួចបង្ហាញតម្លៃទាំងនោះទៅមិត្តរួមថ្នាក់ដែលគេស្គាល់តម្លៃរបស់អ្នកច្បាស់លាស់ តើអ្នកពិតជាមានតម្លៃទាំងនោះមែន ឬទេ ?**

**<u>ចម្លើយ</u>** តម្លៃទាំង ១០ ដែលប្រកាន់យកយ៉ាងខ្ជាប់ខ្ជួន :

. តម្លៃផ្ទាល់ខ្លួន . តម្លៃគ្រួសារ . តម្លៃវប្បធម៌

. តម្លៃសេដ្ឋកិច្ច . តម្លៃរូប ឬសាច់ឈាម

. តម្លៃគំនិតចិត្ត ឬវិចារណញ្ញាណ . តម្លៃការងារ

. តម្លៃសង្គម និងមនុស្សធម៌ . តម្លៃសីលធម៌

. តម្លៃសិល្បៈតម្លៃ ។

ខ្ញុំបង្ហាញតម្លៃទាំង ១០ខាងលើទៅមិត្តរួមថ្នាក់របស់ខ្ញុំ ដោយបានបញ្ជាក់យ៉ាងច្បាស់ថា រូបខ្ញុំពិតជាមានតម្លៃ

ទាំងអស់នោះមែន ព្រោះថាតម្លៃដែលខ្ញុំបានរៀបរាប់ខាងលើសុទ្ធសឹងជាតម្លៃដែលខ្ញុំបានផ្ទាល់ត្រូវបំពេញដើម្បីក្លាយជាកូនល្អ មិត្តល្អ និងពលរដ្ឋល្អ ។

**<u>សំនួរទី ៤.</u> ដើម្បីឱ្យអ្នកដទៃទទួលស្គាល់ និងគោរពតម្លៃរបស់អ្នក តើអ្នកត្រូវធ្វើដូចម្ដេចខ្លះ ?**

**<u>ចម្លើយ</u>** ដើម្បីឱ្យអ្នកដទៃទទួលស្គាល់និងគោរពតម្លៃរបស់យើង យើងត្រូវ :

- បញ្ជាក់ឱ្យច្បាស់ពីតម្លៃដែលយើងមានពិតប្រាកដ
- ត្រូវមានចំណេះដឹងជ្រាលជ្រៅ
- ត្រូវចេះច្នៃប្រឌិត និងអភិវឌ្ឍជានិច្ច
- ចេះគ្រប់គ្រងនូវចំណង់ចំណូលចិត្តអាកប្បកិរិយា និងត្រូវមានជំហរមួយច្បាស់លាស់ក្នុងជីវិត (ឆន្ទៈមោះមុត)
- ត្រូវមានយុត្តិធម៌ ស្មោះត្រង់
- ត្រូវចេះគោរពសិទ្ធិអ្នកដទៃ មិនក្រអឺតក្រទម រើសអើង ឬប្រមាថអ្នកដទៃ ។
- ត្រូវគោរពពាក្យសច្ចៈ មិននិយាយកុហក់ ។ល។

**សំនួរទី ៥. ចូរអ្នកតែងអត្ថបទមួយក្រោមចំណងជើងថា" ការឱ្យតម្លៃផ្ទាល់ខ្លួន "។**

**ចម្លើយ** អត្ថបទមួយក្រោមចំណងជើងថា "ការឱ្យតម្លៃផ្ទាល់ខ្លួន" ។

មនុស្សយើងម្នាក់ៗ តែងតែធ្វើអ្វីមួយទៅតាមការយល់ឃើញការគិតរបស់គេម្នាក់ៗដោយប្រកាន់ខ្ជាប់ ឥរិយាបថបែបនេះនៅក្នុងឆាកជីវិតរបស់ខ្លួន ។ ជាក់ស្តែងមនុស្សគ្រប់រូបតែងមានតម្លៃផ្ទាល់ខ្លួនដាច់ដោយឡែកពីគ្នា ។ ដោយមនុស្សម្នាក់ៗមានគំនិតជំរើសគោលដៅនៃជីវិត សកម្មភាពចំណង់ចំណូលចិត្ត និងតម្រូវការមិនដូចគ្នា ដោយសារការយល់ឃើញផ្ទាល់នូវចំណេះដឹង បទពិសោធន៍ ផ្ទាល់ខ្លួនរបស់ពួកគេទាំងនោះ គឺជាការឱ្យតម្លៃផ្ទាល់ខ្លួន ។

ដូចនេះការឱ្យតម្លៃផ្ទាល់ខ្លួន ជាការស្គាល់តម្លៃខ្លួនឯងគោរពខ្លួនឯងការបំពេញ សមត្ថភាព ការច្នៃប្រឌិត ការចេះគ្រប់គ្រងខ្លួនឯងដើម្បីបង្កើតស្នាដៃអ្វីមួយឱ្យបានជោគជ័យ ។

**<u>សំនួរទី ៦.</u> តើអ្វីខ្លះជាតម្លៃគំនិត ? ប្រសិនបើសច្ចភាពជាតម្លៃសម្រាប់យើង តើវាអាចធ្វើឱ្យយើងដូចម្តេចដែរ ?**

**<u>ចម្លើយ</u>** គេអាចហៅតម្លៃគំនិតដូចជា ភាពស្មោះត្រង់ យុត្តិធម៌ ភក្តីភាព សច្ចភាព ។ល ។

ប្រសិនបើសច្ចភាពជាតម្លៃសម្រាប់យើង វានឹងបញ្ជាយើង ឬជម្រុញចិត្តយើងឱ្យនិយាយ ឬធ្វើសកម្មភាពរាល់ថ្ងៃប្រកបដោយសច្ចភាព ។

**<u>សំនួរទី ៧.</u> តើតម្លៃរបស់យើងត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈអ្វីខ្លះ ?**

**<u>ចម្លើយ</u>** តម្លៃរបស់យើងត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈអាកប្បកិរិយា និងការប្រព្រឹត្តិដែលបានបង្ហាញចំពោះអ្នកដទៃ ។

**<u>សំនួរទី ៨.</u> តើគេចែកតម្លៃសំខាន់ៗជាប៉ុន្មាន ? អ្វីខ្លះ ?**

**<u>ចម្លើយ</u>** គេចែកតម្លៃសំខាន់ៗជា **៦ យ៉ាង**គឺ :

១. **តម្លៃផ្ទាល់ខ្លួន** បានដល់ការស្គាល់តម្លៃខ្លួនឯង និង ការឱ្យតម្លៃខ្លួនឯង ការគោរពខ្លួនឯង ការថែទាំសុខភាព ភាព

ស្ញប់ស្ញាត់ ខាងផ្លូវចិត្ត សមត្ថភាព ការចេះច្នៃប្រឌិត ការចេះគ្រប់គ្រងខ្លួនឯង ស្នាដៃដែលធ្វើអ្វីមួយបានសម្រេច ។

២. **តម្លៃគ្រួសារ** មានការខិតខំរក និងថែរក្សាទ្រព្យសម្បត្តិសន្សំសំចៃ ទំនាក់ទំនងល្អរវាងសមាជិកគ្រួសារ ការចិញ្ចឹមបីបាច់ ថែរក្សាក្រុមគ្រួសារ ការដឹងគុណ ការតបគុណ ការចេះជួយគ្នា ការអធ្យាស្រ័យគ្នា ការស្តាប់បង្គាប់ ការចេះព្រួយបារម្ភឈឺឆ្អាលគ្នា ប្រកាន់ខ្ជាប់ប្រពៃណីទំនៀមទម្លាប់ល្អ ។ល ។

៣. **តម្លៃស្មារតី ឬសីលតម្លៃ** មានការស្រឡាញ់ មេត្តាធម៌ ការគោរព សេចក្តីទុកចិត្ត ការប្តេជ្ញាចិត្ត សេចក្តីសង្ឃឹម ការតាំងចិត្ត ការគោរពបូជា ។

៤. **តម្លៃការងារ** មានក្រមសីលធម៌ការងារ មនសិការការងារ ការចេះច្នៃប្រឌិតផលិតផលមានគុណភាព ការទទួលបាន លទ្ធផលល្អ ស្នាដៃការងារ ការគោរពពេលវេលាធ្វើការងារ គោរពវិន័យ ការទទួលខុសត្រូវ ការដឹកនាំល្អ ការងារស្របច្បាប់ ការងារសុចរិត ។

៥. **តម្លៃវប្បធម៌** មានការថែរក្សានិងការអភិរក្សកេរដំណែលវប្បធម៌ទំនៀមទម្លាប់ប្រពៃណី ពិធីរៀបអាពាហ៍ពិពាហ៍។ល។

៦. **តម្លៃសង្គម និងមនុស្សធម៌** មានការចេះជួយគ្នាទៅវិញ

ទៅមក ការទទួលខុសត្រូវក្នុងសង្គម ការបម្រើសហគមន៍ ការស្គាល់តួនាទីខ្លួនជាពលរដ្ឋ ការគោរពច្បាប់សង្គមជាដើម ។



# មេរៀនទី៦ : ព្រហ្មវិហារធម៌

## I. *ចូរបំពេញល្បះឱ្យបានត្រឹមត្រូវ :*

១. ការដឹងគុណ ការទទួលស្គាល់គុណបំណាច់ដ៏ធំធេងរបស់បុព្វការីជន មានមាតាបិតាជាដើម ដែលលោកបានធ្វើចំពោះយើង គេហៅថា..***កតញ្ញុតាធម៌***.. ។ ឯការតបស្នងចំពោះលោកអ្នកមានគុណគេហៅថា ..***កតវេទិតាធម៌***.. ។

២. ពាក្យកតញ្ញូតាធម៌ និងកតវេទិតាធម៌មានន័យផ្សេងគ្នា តែគេច្រើនប្រើពាក្យនេះបញ្ចូលគ្នា គឺ..***កតញ្ញុកតវេទី***.. ដែល មានន័យថាជាការ..***ដឹងគុណផង*** ..និងជាការ..***តបគុណផង***.. ។

## II. សំនួរត្រិះរិះ

សំនួរទី ១. ដូចម្តេចហៅថា ព្រហ្មវិហារធម៌ ?

ចម្លើយ **ព្រហ្មវិហារធម៌** ជាធម៌របស់ព្រះព្រហ្មដែលក្រាលចិត្តសន្តោសប្រោសប្រណីចំពោះគ្រប់មនុស្សសត្វដោយគ្មានរើសអើង ។ ព្រហ្មវិហារធម៌ គឺធម៌ជាទីនៅរបស់ព្រហ្ម ឬជាធម៌ប្រតិបត្តិ ដើម្បីឱ្យមនុស្សរស់នៅបាន

ល្អប្រសើរ ដែលប្រជាជនគ្រប់ស្រទាប់វណ្ណៈនឹងត្រូវប្រតិបត្តិ ដើម្បីសាមគ្គីភាព និងភាពសុខក្សេមក្សាន្តក្នុងគ្រួសារ និងសង្គម ។

**<u>សំនួរទី ២.</u> ដូចម្តេចហៅថា កតញ្ញូតាធម៌ ?**

**<u>ចម្លើយ</u>** ***កតញ្ញូតាធម៌*** ជាការដឹងគុណ ការទទួលស្គាល់គុណបំណាច់ដ៏ធំធេងរបស់បុព្វការីជន មានមាតាបិតាជាដើម ដែលលោកបានធ្វើចំពោះយើង ។

**<u>សំនួរទី ៣.</u> ចូរពន្យល់ពីធាតុនីមួយៗនៃព្រហ្មវិហារធម៌ ៤**

**<u>ចម្លើយ</u>** ព្រហ្មវិហារធម៌ទាំង ៤ គឺ **មេត្តា ករុណា មុទិតា និង ឧបេក្ខា** ។

**១. មេត្តា**

- ការមានចិត្តស្រឡាញ់រាប់អានញាតិមិត្ត និងសាធារណជនក្នុងសង្គមដោយគ្មានការរើសអើង និង ប្រកបដោយសន្តានចិត្តភក្តីទូលាយ ដូចជាមាតាបិតាចង់ឱ្យតែកូនបានសុខ បានចម្រើនជានិច្ច ចៀសផុតពីទុក្ខវេទនា ពៀរវេរា និងគ្រោះមហន្តរាយគ្រប់ប្រការ ។
- មេត្តា ជាថាមពលនៃធម៌ដែលមានអនុភាពបំផុត អាច

ផ្សព្វផ្សាយដោយគ្មានការរើសអើងទៅកាន់បុគ្គលដែលជាទីស្រឡាញ់របស់យើងឬទៅកាន់អ្នកដទៃដែលមិនមែនជាក្រុមញាតិមិត្ត ឬទៅកាន់បច្ចាមិត្តទៀតផង ។

. មេត្តា មានន័យថា ស្និទ្ធស្នាល ការប្រតិបត្តិប្រកបដោយមេត្តា គឺសត្រូវទាំងអស់នឹងត្រឡប់ប្រែក្លាយជាមិត្ត មិនអាចស្អប់ និង មិនចងពៀរវេរាចំពោះយើងបានយូរឡើយ ។

អ្នកមានមេត្តាគ្មានការភ័យតក់ស្លុត អំពីហេតុការណ៍អាក្រក់កើតឡើងទេ គេអាចដោះស្រាយបានរាល់បញ្ហាទាំងអស់ ។

**២. ករុណា**

. ករុណា គឺការមានចិត្តអាណិតអាសូរដោយគ្មានច្រណែនឈ្នានីស យកត្រូវតែខ្លួនឯង ទិតៀន រិះគន់កំហុសអ្នកដទៃឡើយ ។

. ការអាណិតអាសូរចំពោះមនុស្សទាំងអស់នៅក្នុងសង្គមដែលបានទទួលរងទុក្ខលំបាកផ្សេងៗទាំងផ្លូវចិត្តទាំងផ្លូវកាយ ដោយចង់ឱ្យពួកគេរួចពីទុក្ខលំបាក និងរស់នៅបានសុខស្រួលដូចខ្លួនដែរ ។

**៣. មុទិតា**

មុទិតា គឺមានចិត្តទន់ភ្លន់ មានចិត្តរីករាយអបអរសាទរ ចំពោះសេចក្តីសុខចម្រើនរបស់អ្នកដទៃមិនរើសមុខ និង ចង់ឱ្យគេស្ថិតនៅក្នុងសេចក្តីសុខសុវត្ថិភាពជានិច្ច ដោយ គ្មានការច្រណែននិន្ទាឈ្នានីស ។

## ៤. ឧបេក្ខា

ឧបេក្ខា គឺការប្រកាន់ចិត្តជាកណ្តាល មិនលំអៀងទៅ ខាងណា និងមានចិត្តជាអព្យាក្រឹត ។

- មិនមានចិត្តត្រេកអរហួសហេតុ និងមិនខឹងសំបារចំពោះ អ្នកណាទាំងអស់ ។ បំណងសំខាន់ គឺចង់ឱ្យតែពួកគេរស់ នៅតាមលទ្ធភាព សមត្ថភាព និងសេរីភាពរបស់ពួកគេ។
- មិនមានចិត្តលោភលន់ ឬព្រួយកង្វល់ ចំពោះអ្នកជិតខាង ដែលមានទ្រព្យសម្បត្តិច្រើនជាងខ្លួន ។

មនុស្សតែងតែមានចិត្តជាប់ជំពាក់ទៅលើមនុស្សណា ម្នាក់ ឬ វត្ថុអ្វីមួយដែលជាទីស្រឡាញ់ពេញចិត្តរបស់ខ្លួន ហើយ ការជាប់ជំពាក់នេះនាំមនុស្សឱ្យមានចិត្តលំអៀង ឬអគតិ ។

ដូចនេះ មនុស្សម្នាក់ត្រូវប្រកាន់ខ្ជាប់ព្រហ្មវិហារធម៌ ព្រោះវាជាប្រភពនៃសន្តិភាព និងវឌ្ឍនភាពនៃសង្គម និង ពិភពលោក ។

**សំនួរទី ៤. តើកតញ្ញូ និងកតវេទី មានអត្ថន័យដូចម្ដេច និងខុសគ្នាយ៉ាងណាដែរ ? ចូរពន្យល់ ។**

**ចម្លើយ កតញ្ញូតាធម៌ និងកតវេទីតាធម៌** ជាធម៌ដែលបុគ្គលគ្រប់រូបយល់ដឹង និងអនុវត្តជាប់ជានិច្ច ដើម្បីចៀសវាងការប្រមាថ មាក់ងាយពីអ្នកដទៃដែលនាំឱ្យអាប់ឱនសិរីសួស្ដី ។ ការយល់ដឹង និង ការអនុវត្តបានល្អនូវធម៌ទាំងពីរនេះ នឹងដឹកនាំឱ្យបុគ្គលនោះក្លាយជាមនុស្សមានភាពថ្លៃថ្នូរក្នុងសង្គមប្រកបដោយសិរីសួស្ដី និងសុភមង្គល

***ក. កតញ្ញូតាធម៌*** ជាការដឹងគុណ ការទទួលស្គាល់គុណបំណាច់ដ៏ធំធេងរបស់បុព្វការីជន មានមាតាបិតាជាដើមដែលលោកបានធ្វើចំពោះយើង ។

***ខ. កតវេទីតាធម៌*** ជាការតបស្នងចំពោះលោកអ្នកមានគុណ ។

ពាក្យកតញ្ញូតាធម៌ និងកតវេទីតាធម៌មានន័យផ្សេងគ្នា តែគេច្រើនប្រើពាក្យនេះបញ្ចូលគ្នា គឺ**កតញ្ញូកតវេទី**ដែលមានន័យថា ជាការដឹងគុណផង និងជាការតបគុណផង។

បុត្រធីតាគ្រប់រូបត្រូវអប់រំខ្លួន ឱ្យក្លាយជាមនុស្សដឹងគុណមាតា បិតា និងការខិតខំតបគុណ លោកទាំងពីរវិញ ។

**សំនួរទី ៥. តើមានកត្តាអ្វីខ្លះ ដើម្បីឱ្យខ្លួនអ្នកក្លាយជាអ្នកមានគុណលើអ្នកនៅជុំវិញ ?**

**ចម្លើយ** ដើម្បីឱ្យខ្លួនយើងក្លាយជាអ្នកមានគុណលើអ្នកនៅជុំវិញខ្លួនយើងត្រូវ :

១. ត្រូវចេះជួយទុក្ខធុរៈ យកអាសាអ្នកនៅជុំវិញ

២. ត្រូវប្រកាន់ខ្ជាប់នូវ សុចរិត ស្មោះត្រង់ និងយុត្តិធម៌

៣. មិនត្រូវរើសអើង ដូចជាភេទ ពូជសាសន៍ និងជំនឿខុសៗគ្នា ត្រូវមានការអត់ឱន អធ្យាស្រ័យ និងសន្តោស

៤. ត្រូវស្គាល់នូវអំពើល្អ និង អំពើអាក្រក់ ។

**សំនួរទី ៦. តើអ្នកត្រូវធ្វើដូចម្តេច ដើម្បីឱ្យក្លាយជាកូនកតញ្ញូកតវេទី ?**

**ចម្លើយ** ដើម្បីឱ្យក្លាយជា កូនកតញ្ញូកតវេទី កូនៗត្រូវ :

- គោរព ស្តាប់ដំបូន្មាន និង ចិញ្ចឹមបីបាច់ថែរក្សាលោកជាប្រចាំតាមលទ្ធភាព និង សមត្ថភាពរបស់ខ្លួន និង មានស្មារតីទទួលខុសត្រូវចំពោះជីវភាព សុខភាព និងសុវត្ថិភាពរបស់លោកគ្រប់កាលៈទេសៈមិនធុញទ្រាន់ ទោះជាពេលវេលាដែលជួបការលំបាកស្មុគស្មាញក្នុងជីវភាព ឬហេតុ

ការណ៍អ្វីផ្សេងក៏ដោយ ។

- មិនធ្វើឱ្យលោកទាំងពីរពិបាកចិត្ត ត្រូវបង្កបរិយាកាស ឱ្យមានការសប្បាយរីករាយ និងមានការជួបជុំគ្នា ស្រុះស្រួលគ្នារវាងបងប្អូនសាច់ញាតិទាំងអស់ ។
- ត្រូវចេះនាំលោកទាំងពីរទៅធ្វើបុណ្យទានផ្សេងៗ ឬនាំលោកធ្វើដំណើរកំសាន្តកន្លែងផ្សេងៗ ។
- ត្រូវចេះជួយសម្រាលការងារលោកទាំងពីរតាមលទ្ធភាព.
- ត្រូវចេះលើកទឹកចិត្តដល់លោកតាមប្រការផ្សេងៗដូចជាចេះនិយាយសួរសុខទុក្ខ..និយាយរឿងកំប្លែង..ឬត្រូវខំរៀនឱ្យបានលទ្ធផលល្អ ជាសិស្សពូកែជាដើម ។
- មិនត្រូវប្រព្រឹត្តអំពើណាដែលធ្វើឱ្យវង្សត្រកូលខូចកិត្តិយស
- ត្រូវចេះការពារទ្រព្យសម្បត្តិគ្រួសារ និងជួយសន្សំសំចៃប្រាក់កាសឪពុកម្តាយដែលលោកខំរកដោយលំបាក ។

**សំនួរទី ៧.** ចូរបង្ហាញសកម្មភាពទាំងឡាយណាដែលបញ្ជាក់ថាអ្នកជាកូនកតញ្ញូកតវេទី ?

**ចម្លើយ** ដូចចម្លើយ សំណួរលេខ៦

**សំនួរទី ៨.** តាមព្រះពុទ្ធសាសនា តើកូនដែលដឹងគុណឪពុកម្តាយត្រូវទទួលបានសម្បត្តិប៉ុន្មានយ៉ាង ?

គឺអ្វីខ្លះ ?

**ចម្លើយ** តាមព្រះពុទ្ធសាសនា កូនដែលដឹងគុណឪពុកម្ដាយត្រូវទទួលបានសម្បត្តិ **៣ ប្រការ** គឺ សម្បត្តិមនុស្ស សម្បត្តិទេវតា និង សម្បត្តិព្រះនិពាន្ទ ។

**ក. សម្បត្តិមនុស្ស** មាន :

- ភោគសម្បត្តិ : ទ្រព្យសម្ភារៈ ប្រាក់កាស ផ្ទះ ឡាន...
- វិជ្ជាសម្បត្តិ : ជាមនុស្សចេះដឹងជ្រៅជ្រះ មានសមត្ថភាព
- ចរិយាសម្បត្តិ : មានអត្តចរិតស្លូត សុភាពរាបសារ ចេះគួរសម..
- មានវណ្ណៈ គឺមានពណ៌សម្បុរកាយល្អ ស្អាត
- មានពលៈ គឺមានកម្លាំងខ្លាំងក្លា សុខភាពល្អ គ្មានជម្ងឺ..

**ខ. សម្បត្តិទេវតា** សំដៅដល់សម្បត្តិសួគ៌ ដែលជាសម្បត្តិដ៏ប្រសើរថ្លៃថ្លា ។

**គ. សម្បត្តិព្រះនិព្វាន** គឺបានដល់ឋានបរមសុខ គ្មានកើត គ្មានចាស់ គ្មានឈឺ គ្មានស្លាប់ ។

**សំនួរទី ៩. តើកូនអកតញ្ញូ អកតវេទី ឬកូនរមើលគុណ ជាមនុស្សដូចម្តេច ?**

**ចម្លើយ** កូនចៅដែលមិនដឹងគុណ មិនបានតបគុណមាតា

បិតា មិនស្តាប់ដំបូន្មានមិនប្រព្រឹត្តអំពើល្អ ធ្វើឱ្យវង្សត្រកូល ខូចកិត្តិយស និងមិនយកចិត្តទុកដាក់ចិញ្ចឹមបីបាច់ថែរក្សា មាតាបិតាតាមលទ្ធភាពរបស់ខ្លួនទោះបីខ្លួនមានទ្រព្យ សម្បត្តិគ្រប់គ្រាន់ ក៏មិនរវល់អើពើនឹងលោកទាំងពីរទាល់ តែសោះ គិតតែពីជីវិតខ្លួនប្រពន្ធកូនខ្លួន ទុកបណ្តោយឱ្យ លោកទទួលរងទុក្ខលំបាកតាមយថាកម្ម ទាំងនេះមាន ឈ្មោះថាជា **កូនអកតញ្ញូ អកតវេទី ឬ កូនរមិលគុណ** ។

**<u>សំនួរទី ១០.</u> តើសិស្សកតញ្ញូកតវេទី ជាសិស្សដូចម្តេច ?**

<u>**ចម្លើយ**</u> ចំពោះសិស្សានុសិស្សនៅពេលមានចំណេះដឹង ច្រើន មានបុណ្យសក្តិខ្ពស់ និងមានទ្រព្យសម្បត្តិគ្រប់គ្រាន់ ពេលឃើញគ្រូរបស់ខ្លួនចាស់ជរា ឬមានទុក្ខធុរៈផ្សេងៗ យកចិត្តទុកដាក់ជួយសង្គ្រោះលោកតាមកាលៈទេសៈ និង មានលទ្ធភាពទើបមានឈ្មោះថា **សិស្សកតញ្ញូកតវេទី** ។

**<u>សំនួរទី ១១.</u> តើបុគ្គលគ្រប់រូបត្រូវធ្វើអ្វីខ្លះ ដើម្បីក្លាយខ្លួនជាជនដែលមានកតញ្ញូកតវេទីចំពោះប្រទេសជាតិរបស់ខ្លួន ?**

<u>**ចម្លើយ**</u> បុគ្គលគ្រប់រូប គឺមានភារៈជួយទំនុកបម្រុងប្រទេស

ជាតិរបស់ខ្លួនតាមលទ្ធភាព ដូចជា :

- បង់ពន្ធជូនរដ្ឋតាមច្បាប់កំណត់មិនគេចវេះ
- មិនពុករលួយ ត្រូវមានយុត្តិធម៌
- ចូលរួមការពារសម្បត្តិវប្បធម៌ជាតិ និងការពារបរិស្ថាន
- ចេះជួយទុក្ខលំបាកមនុស្សផងគ្នារស់ក្នុងសង្គម(សម្បទាន)
- មិនបង្កឱ្យមានបញ្ហាផ្សេងៗដល់ការរក្សាសុខសន្តិភាព និងសុវត្ថិភាពសង្គម ។

**<u>សំនួរទី ១២.</u> តើអ្វីជា បដិបក្ខនឹងមេត្តា ?**

**<u>ចម្លើយ</u>** ទោសៈ ជាបដិបក្ខនឹងមេត្តា ។ នៅពេលមានទោសៈចូលបុកលុយក្នុងចិត្ត យើងត្រូវយកមេត្តាធម៌មកលាងសម្អាតចិត្តរបស់យើង ។ ប្រសិនបើមនុស្សគ្រប់រូបសុទ្ធតែមានមេត្តាដូចគ្នា មនុស្សទាំងអស់នៅក្នុងលោកនឹងមិនមានជម្លោះអំពើហិង្សាជាមួយគ្នាឡើយ ។

**<u>សំនួរទី ១៣.</u> តើព្រហ្មវិហារធម៌របស់អ្នកមានគុណជាអ្វី ?**

**<u>ចម្លើយ</u>** ព្រហ្មវិហារធម៌របស់អ្នកមានគុណ គឺជាព្រហ្មវិហារធម៌របស់បុព្វការីជនដែលបានចិញ្ចឹមបីបាច់ថែរក្សាអាណិតស្រឡាញ់ បានបង្រៀន និងជួយទំនុកបម្រុងផ្គង

ផ្ដើមឱ្យបានសម្រេចផលប្រយោជន៍ផ្សេងៗក្នុងការប្រកបរបរចិញ្ចឹមជីវិតនាពេលបច្ចុប្បន្ន និងទៅអនាគត ។

**សំនួរទី ១៤. តើមាតា និងបិតា មានព្រហ្មវិហារធម៌អ្វីខ្លះចំពោះកូន ? ចូរពន្យល់ ?**

**ចម្លើយ** ព្រហ្មវិហារធម៌របស់មាតាបិតា ជាធម៌ដ៏ប្រសើរខ្ពង់ខ្ពស់ ព្រោះលោកទាំងពីរប្រកបទៅដោយ :

**មេត្តា** : ការស្រឡាញ់ ប្រាថ្នាឱ្យកូនបានសុខ ពិសេសស្រឡាញ់តាំងពីដឹងថាខ្លួនមានផ្ទៃពោះ គឺធ្វើយ៉ាងណាមិនឱ្យខូចសុខភាពដល់កូនក្នុងផ្ទៃឡើយ ដូចជាមិនហ៊ានហូបអាហារដែលមានជាតិហឹរជាដើម ។

**ករុណា** : សេចក្ដីអាណិតអាសូរគិតចង់ឱ្យកូនបានរួចពីទុក្ខចាប់តាំងពីប្រសូត្រមក ប្រុសក្ដី ស្រីក្ដីល្អ អាក្រក់យ៉ាងណាក៏ដោយ ក៏មាតាបិតាខំចិញ្ចឹមកូនឱ្យរស់រានដែរ ។

**មុទិតា** : សេចក្ដីត្រេកអរក្នុងវេលាដែលកូនបានសុខ ត្រេកអរតាំងពីកូនរៀនចេះនិយាយ ចេះសើច ហើយតែងតែសរសើរកូនគ្រប់ពេល ។

**ឧបេក្ខា** : តាំងចិត្តជាកណ្ដាល ឪពុកម្ដាយស្រឡាញ់កូនស្មើៗគ្នា ។ មាតាបិតាតែងតែប្រស់ព្រំមកលើបុត្រធីតា

ជានិច្ច ។

ដោយអំណាចព្រហ្មវិហារធម៌នេះ លោកជាមាតាបិតា ខិតខំព្យាយាមស្វែងរកទ្រព្យសម្បត្តិសម្រាប់ជួយឧបត្ថម្ភ ដល់បុត្រធីតា ទោះបីជាលោកបានជួបប្រទះនឹងសេចក្តី ក្រលំបាកវេទនាយ៉ាងណាក៏ដោយ ក៏លោកនៅតែព្យាយាម ប្រឹងប្រែងជួយឧបត្ថម្ភបុត្រធីតា របស់ខ្លួនតាមលទ្ធភាព ដែរ ។ មិនតែប៉ុណ្ណោះ ពេលបុត្រធីតាចម្រើនវ័យ ពេញ រូបរាង មាតាបិតា ទាំង ឡាយតែងព្យាយាមរំពៃរកមើល ជ្រើសរើសគូស្រករដ៏សមរម្យ ដើម្បីរៀបចំផ្សំផ្គុំជាគូស្វាមី ភរិយា និងចែកទ្រព្យសម្បត្តិទុក ប្រកបរបរចិញ្ចឹមជីវិត តទៅទៀត ។

**សំនួរទី ១៥.** តើព្រះសម្មាសម្ពុទ្ធទ្រង់ចាត់ទុកមាតាបិតា ជាអ្វី ? ហេតុអ្វី ?

**ចម្លើយ** ព្រះសម្មាសម្ពុទ្ធទ្រង់បានចាត់ទុកមាតាបិតាជា **ព្រះ** ជា**អ្នកមានគុណ** ព្រោះលោកទាំងពីរមានព្រហ្មវិហារ ធម៌ចំពោះបុត្រធីតា ។

# មេរៀនទី៧ : ធម៌អហិង្សា

**I.** *__ចូរបំពេញឃ្លាឱ្យបានត្រឹមត្រូវ :__*

១. អំពើហិង្សាដែលកើតមាននៅក្នុងប្រវត្តិសាស្ត្រគឺ ការ ..*ប្រើអាវុធយុទ្ធភ័ណ្ឌ*.. និងការ..*ធ្វើសង្គ្រាមសមរភូមិ* ..។

២. ជាទូទៅ ក្នុងការអប់រំអំពីការដោះស្រាយទំនាស់ ឬសន្តិភាព គេនិយមប្រើពាក្យ..*អហិង្សា ឬធម៌អហិង្សា*..

៣. គោលដៅនៃធម៌អហិង្សា គឺ..*ស្វែងរកសច្ចភាព*..បង្កើតយុត្តិធម៌ លទ្ធភាពដើម្បីសាមគ្គីភាព និងការបង្រួបបង្រួម

**II.** __សំនួរត្រិះរិះ__

☛ __សំនួរទី ១.__ តើធម៌អហិង្សាជាអ្វី ?

✍ __**ចម្លើយ**__ ជាទូទៅ ក្នុងការអប់រំអំពីការដោះស្រាយទំនាស់ ឬសន្តិភាព គេនិយមប្រើពាក្យ **អហិង្សា** ឬ**ធម៌អហិង្សា** ។ ធម៌អហិង្សាមកពីពាក្យ **ធម៌** និង **អហិង្សា** :

- **ធម៌** មានន័យថា ជាសភាវទ្រទ្រង់មនុស្ស សត្វលោក គឺបុណ្យបាប ការចម្រើន ការរិះគិតអ្វីៗដែលទ្រទ្រង់ធ្វើឱ្យមានភាពឋិតថេរ ។ល ។
- **អហិង្សា** គឺជាការមិនបៀតបៀនអ្នកដទៃ ឬ ធ្វើទុក្ខបុក .

ម្នេញអ្នកដទៃឱ្យមានការឈឺចាប់ និងវេទនាលំបាក ។

➢ **ធម៌អហិង្សា** គឺធម៌ទាំងឡាយណាដែលទ្រទ្រង់មនុស្សមិនឱ្យប្រព្រឹត្តអំពើហិង្សា មិនឱ្យបៀតបៀន ឬធ្វើទុក្ខបុកម្នេញអ្នកដទៃ និងមិនធ្វើឱ្យអ្នកដទៃមានការឈឺចាប់ទាំងផ្លូវចិត្ត ទាំងផ្លូវកាយ ។

*អ្នកអប់រំសន្តិភាព*បានកំណត់អត្ថន័យ**ធម៌អហិង្សា** ថាជាគោលការណ៍ ជាមាគ៌ានៃជីវិតសម្រាប់ផ្លាស់ប្តូរហើយបានចាត់ទុកថា មនុស្សជាអ្នកមានតម្លៃខ្ពស់បំផុតដែលមិនត្រូវរំលោភបំពាន ឬបំផ្លិចបំផ្លាញចំពោះរាងកាយ និងជីវិតអ្នកដទៃបានឡើយ ។

**គោលដៅ**នៃធម៌អហិង្សា គឺស្វែងរកសច្ចភាពបង្កើតយុត្តិធម៌ លទ្ធភាពដើម្បីសាមគ្គីភាព និង ការបង្រួបបង្រួម ។

**សំនួរទី ២. ចូរប្រៀបធៀបទស្សនៈអហិង្សារបស់ព្រះពុទ្ធ មហាត្មៈគន្ធី និងខុងជឺ ។**

**ចម្លើយ** ប្រៀបធៀបទស្សនៈអហិង្សារបស់ ព្រះពុទ្ធ មហាត្មៈគន្ធី និងខុងជឺ

**ក. ព្រះពុទ្ធសាសនា** បានចូលរួមបណ្តុះវប្បធម៌អហិង្សា

នៅក្នុងសង្គមយើងបច្ចុប្បន្ន គឺតាមរយៈធម្មទេសនា ផ្ដល់ឱវាទផ្សេងៗដូចជា ព្រះពុទ្ធទ្រង់សម្ដែងថា " មេត្តាជាបន្សារសម្រាប់ផ្សារភ្ជាប់ពិភពលោក " មានន័យថា គ្រួសារ ប្រទេសជាតិ និងពិភពលោកទាំងមូលផ្សារភ្ជាប់គ្នាជាសាច់ឈាមតែមួយដោយគ្មានប្រកាន់វណ្ណៈ ពូជសាសន៍ នោះពិតជាគ្មានសង្គ្រាម និងមានតែការស្រឡាញ់គ្នា ។ ព្រះពុទ្ធបានធ្វើធម្មទេសនា បង្ហាញពីបញ្ហា "ហេតុ" ដែលនាំឱ្យមាន "ទុក្ខ " និងវិធីសម្រាប់រំដោះទុក្ខ ។ ព្រះអង្គបានអប់រំមហាជន បុថុជ្ជនទាំងឡាយឱ្យដឹងច្បាស់ថា អំពើណាគួរប្រព្រឹត្ត អំពើណាគួរចៀសវាងទាំងកាយ វាចា និង ទាំងចិត្តតាមរយៈបញ្ញូសីល ពៀររំងាប់ដោយការមិនចងពៀរ ។ល ។

**១. មហាត្មៈគន្ធី** បានចូលរួមបណ្ដុះវប្បធម៌អហិង្សានៅក្នុងសង្គម គឺសកម្មភាពប្រឆាំងរបស់លោកចំពោះអំពើអយុត្តិធម៌ មិនប្រើកម្លាំងកាយទេ គឺប្រើកម្លាំងសីលធម៌ និងអំពើអហិង្សា ។ លោកបានណែនាំគេឱ្យប្រើមធ្យោបាយត្រជាក់ដើម្បីដោះស្រាយវិបត្តិផ្សេងៗ ទោះបីមានការចាប់ចង ឬការវាយ សំពងក៏ដោយ ។ បើអ្នកធ្វើអំពើហិង្សា សូមកុំប្រកាន់ខ្លួន កុំខ្ញិល ហើយត្រូវតែប្រយ័ត្នជានិច្ចចំពោះសេចក្ដី

ក្រោយដែលកើត មាននៅក្នុងសន្តានចិត្តរបស់អ្នក ។ លោកមិនឱ្យមនុស្សប្រើកម្លាំងកាយទេ ព្រោះវាជាអំពើបាប ប៉ុន្តែគេត្រូវប្រើបញ្ញាដើម្បី ដោះស្រាយវិបត្តិ ។

**គ. ខុងជឺ** ជាទស្សនវិទូមួយរូបនៃប្រទេសចិនដែលសម្បូរទៅដោយគុណធម៌ប្រចាំខ្លួន ។ គុណសម្បត្តិនៃទស្សនៈរបស់លោក គឺឱ្យតម្លៃទៅលើសប្បុរសធម៌ មនុស្សធម៌ និងយុត្តិធម៌ ។ ខុងជឺបានហាមមនុស្សមិនឱ្យធ្វើសង្គ្រាមជាដាច់ខាត ។ លោកមើលឃើញសង្គ្រាមជាប្រភពនៃអមនុស្សធម៌ ព្រោះវាកើតមានអំពើឃោរឃៅដូចជា ការកាប់ចាក់ ការធ្វើទារុណកម្ម ការបាញ់សម្លាប់គ្នាទៅវិញទៅមក ។

គុណធម៌របស់ខុងជឺសំដៅលើកទឹកចិត្ត មេត្តា ករុណា និងភាពត្រឹមត្រូវ ។ លោកថា មនុស្សម្នាក់ៗនៅក្នុងសង្គមសុទ្ធតែមានភារកិច្ចដែលគេគួរធ្វើ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេ ប្រកបដោយសីលធម៌ និងភាពត្រឹមត្រូវ ។ សកម្មភាពបែបនេះ ខុងជឺហៅថា " ករុណាធម៌ "

លោកបានផ្តល់ទស្សនៈថា " កុំធ្វើទៅលើអ្នកដទៃនូវអំពើអ្វីដែលអ្នកមិនចង់ឱ្យអ្នកដទៃធ្វើមកលើខ្លួនវិញ " ។

**<u>សំនួរទី ៣.</u> តើការប្រតិបត្តិធម៌អហិង្សាផ្តល់ប្រយោជន៍អ្វីខ្លះដល់បុគ្គល និងសង្គម ? ចូររកឧទាហរណ៍ ២**

ចម្លើយ ការរស់នៅក្នុងសង្គម ប្រសិនបើមនុស្សម្នាក់ៗ ជ្រើសរើសយកធម៌អហិង្សាមកដាក់ក្នុងខ្លួន គឺ នាំមកនូវផលប្រយោជន៍ដូចជា :

- មនុស្សអាចឈ្នះចិត្តខ្លួនឯងបាន ។
- បើចិត្តមនុស្សគ្រប់គ្នាមានធម៌អហិង្សា កាយ និងវាចាក៏មានធម៌អហិង្សាដែរ ។
- ការជ្រើសរើសយក ឬការប្រកាន់ខ្ជាប់ធម៌អហិង្សា គឺធ្វើឱ្យគ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោកទាំងមូលមានសុភាព មិនមានជម្លោះវាយប្រហារគ្នា មានសន្តិភាព ការគោរពគ្នាទៅវិញទៅមក ទទួលបានផលប្រយោជន៍គ្រប់យ៉ាងដូចជា ការគោរពជីវិតមនុស្ស ។
- កម្លាំងមនុស្ស សហប្រតិបត្តិការ មានការយោគយល់គ្នារវាងជនជាតិ និងជនជាតិ រវាងជាតិ និងជាតិ និងការយល់គ្នាជាអន្តរជាតិ ។

ជារួមបុគ្គលគ្រប់រូបដែលប្រកាន់ខ្ជាប់ធម៌អហិង្សា នឹងចូលរួមចំណែកធ្វើឱ្យសង្គមគ្រួសារប្រទេសជាតិមានការអភិវឌ្ឍគ្រប់ផ្នែក មានសន្តិភាពផ្លូវចិត្ត ផ្លូវកាយ សុភមង្គលដល់ជីវិតមនុស្សគ្រប់រូប ។

**សំនួរទី ៤.** ប្រសិនបើមាននរណាម្នាក់ប៉ុនប៉ងបង្ក អំពើហិង្សាមកលើអ្នក តើអ្នកត្រូវធ្វើដូចម្ដេច ?

**ចម្លើយ** ប្រសិនបើនរណាម្នាក់ប៉ុនប៉ងបង្ករអំពើហិង្សាមកលើខ្ញុំ ខ្ញុំត្រូវរកវិធីដោះស្រាយដោយសន្តិវិធី និងត្រូវមានគំនិតអធ្យាស្រ័យ ចេះយោគយល់ មានចិត្តមេត្តា ករុណា ដោយបោះបង់ការប្រកាន់គំនុំទុកផងដែរ ដើម្បីកុំឱ្យកើតមានអំពើហិង្សា ។

**សំនួរទី ៥.** ចូររៀបចំផលិតសម្ភារៈ ដើម្បីធ្វើយុទ្ធនាការប្រឆាំងនឹងអំពើហិង្សា ។

**ចម្លើយ** ការរៀបចំផលិតសម្ភារៈ ដើម្បីធ្វើយុទ្ធនាការប្រឆាំងនឹងអំពើហិង្សា មាន :

- ធ្វើគំនូរបោះរូបភាពផ្សេងៗទាក់ទងនឹងការប្រឆាំងអំពើហិង្សា
- រៀបចំសរសេរពាក្យស្លោក ដែលមានខ្លឹមសារអប់រំមិនឱ្យប្រព្រឹត្តអំពើហិង្សា ឬផលវិបាកនៃអំពើហិង្សា
- ប្រើប្រព័ន្ធឃោសនសព្ទផ្សព្វផ្សាយអប់រំប្រឆាំងនឹងអំពើហិង្សា

- ចែកខិតប័ណ្ណព័ត៌មានស្តីពីការអប់រំមិនឱ្យធ្វើអំពើហិង្សា និងរូបភាពស្តីពីផលវិបាកនៃអំពើហិង្សា
- ចុះព័ត៌មានតាមការសែត ទស្សនាវដ្តី ឬពោមទូរទស្សន៍ ស្តីពីការអប់រំមិនឱ្យប្រព្រឹត្តអំពើហិង្សា ...។

**<u>សំនួរទី ៦.</u> តើការផ្សព្វផ្សាយធម៌អហិង្សានៅកម្ពុជាបច្ចុប្បន្ន ធ្វើឡើងតាមរយៈខ្លះ ?**

**<u>ចម្លើយ</u>** ការផ្សព្វផ្សាយធម៌អហិង្សានៅកម្ពុជាបច្ចុប្បន្នធ្វើឡើងតាមរយៈកម្មវិធីអប់រំមួយចំនួន ដូចជា ទូរទស្សន៍ វិទ្យុ កាសែត ទស្សនាវដ្តី ការបិទផ្សាយរូបភាពនៅតាមដងផ្លូវដោយគំនូរផាត់ពណ៌ផ្ទាំងធំៗ ឬខិតប័ណ្ណផ្សេងៗ និងជាពិសេសផ្សព្វផ្សាយនៅពេលមានការប្រារព្ធពិធីបុណ្យជាតិផ្សេងៗ ក្នុងប្រទេសរបស់យើងដើម្បីឱ្យប្រជាជនបានយល់ច្បាស់ពីធម៌អហិង្សាដើម្បីធ្វើខ្លួនក្លាយជាពលរដ្ឋល្អ ។

**<u>សំនួរទី ៧.</u> តើព្រះពុទ្ធសាសនាបានចូលរួមបណ្តុះវប្បធម៌អហិង្សាដូចម្តេចខ្លះនៅក្នុងសង្គមយើងបច្ចុប្បន្ន?**

**<u>ចម្លើយ</u>** ព្រះពុទ្ធសាសនា បានចូលរួមបណ្តុះវប្បធម៌អហិង្សា

នៅក្នុងសង្គមយើងបច្ចុប្បន្ន គឺតាមរយៈធម្មទេសនា ផ្តល់ឱវាទផ្សេងៗដូចជា ព្រះពុទ្ធទ្រង់សម្តែងថា " មេត្តាជាបន្ទារសម្រាប់ផ្សារភ្ជាប់ពិភពលោក " មានន័យថា គ្រួសារ ប្រទេសជាតិ និងពិភពលោកទាំងមូលផ្សារភ្ជាប់គ្នាជាសាច់ឈាមតែមួយដោយគ្មានប្រកាន់វណ្ណៈ ពូជសាសន៍ នោះពិតជាគ្មានសង្គ្រាម និងមានតែការស្រឡាញ់គ្នា ។ ព្រះពុទ្ធបានធ្វើធម៌ទេសនា បង្ហាញពីបញ្ហា "ហេតុ" ដែលនាំឱ្យមាន "ទុក្ខ " និងវិធីសម្រាប់រំដោះទុក្ខ ។ ព្រះអង្គបានអប់រំមហាជន បុថុជ្ជនទាំងឡាយឱ្យដឹង ច្បាស់ថា អំពើណាគួរប្រព្រឹត្ត អំពើណាគួរចៀសវាង ទាំងកាយ វាចា និងទាំងចិត្តតាមរយៈបញ្ញសីល ពៀររំងាប់ដោយការមិនចងពៀរ ។ល ។

**<u>សំនួរទី ៨.</u> តើធម៌អហិង្សា ឬការមិនបៀតបៀនជាអ្វី? ដើម្បីឱ្យសង្គមមនុស្សមានសន្តិសុខពេញលេញ តើបុគ្គលម្នាក់ៗត្រូវប្រតិបត្តិគោលការណ៍នៃធម៌អហិង្សាដូចម្តេចខ្លះ ?**

**<u>ចម្លើយ</u>** ធម៌អហិង្សា ឬការមិនបៀតបៀន គឺជាអំពើផ្តល់សេចក្តីសុខដ៏ឧត្តម ។ សង្គមមនុស្សនឹងបានសុខសន្តិភាពពេញលេញ ប្រសិនបើបុគ្គលម្នាក់ៗ ប្រតិបត្តិតាមគោល

ការណ៍នៃធម៌អហិង្សាដូចខាងក្រោម :

**១. ប្រកាន់ខ្ជាប់នូវសេចក្ដីស្ងប់ខាងផ្លូវកាយ និងខាងផ្លូវចិត្ត** គឺការរួបរួមជាមួយគ្នាដោយសុខដុមរមនា មិនបៀតបៀនគ្នា មិនព្យាបាទ ឈ្នានីសគ្នា ពោលគឺការរស់នៅដោយគន្លងធម៌ ប្រកបដោយចិត្ត មេត្តា ករុណា មុទិតា ឧបេក្ខា និង គ្មានការលោភលន់កេងប្រវ័ញ្ច ។

**២. ខន្តី ឬសេចក្ដីអត់ធន់** គឺជាឱសថទប់ទល់នឹងពាក្យតិះដៀល និងការឈ្លោះប្រកែកគ្នា ។ បុគ្គលដែលប្រកបដោយសេចក្ដីអត់ធន់នឹងទទួលបានមិត្តល្អ បានកិត្តិយស និងសុភមង្គល ។ ជនដែលចេះអត់ឱន តែងតែមានការស្រឡាញ់រាប់អានពីអ្នកដទៃជានិច្ច ។

**៣. ប្រព្រឹត្តតែអំពើល្អ លះបង់គំនិតគុំកួនដែលមាននៅក្នុងចិត្ត** ពោលគឺ ពៀររំងាប់ដោយការមិនចងពៀរ ហើយមានតែសេចក្ដីស្រឡាញ់ទេដែលជួយមនុស្សឱ្យរួចផុតពីសំអប់ និងកំហឹងបាន ។ ការរស់នៅប្រកបដោយចិត្តមេត្តា ករុណា និង នាំមកនូវសុភមង្គលជានិច្ចនិរន្តរ៍ ។

☛ **<u>សំនួរទី ៩.</u> តើខុងជឺ ជានរណា ? តើគុណសម្បត្តិនៃទស្សនៈរបស់លោកគឺជាអ្វី ?ចំណែកគុណធម៌របស់លោកវិញដូចម្ដេចដែរ ?**

**ចម្លើយ ខុងជឺ** ជាទស្សនវិទូមួយរូបនៃប្រទេសចិនដែលសម្បូរទៅដោយគុណធម៌ប្រចាំខ្លួន។ គុណសម្បត្តិនៃទស្សនៈរបស់លោក គឺឱ្យតម្លៃទៅលើសប្បុរសធម៌ មនុស្សធម៌ និងយុត្តិធម៌ ។ គុណធម៌របស់ខុងជឺ សំដៅលើកទឹកចិត្ត មេត្តាករុណា និងភាពត្រឹមត្រូវ ។



# ពៀររំងាប់ដោយការមិនចងពៀរ !

# មេរៀនទី៤ : សច្ចធម៌

## I. *ចូរបំពេញល្បះឱ្យបានត្រឹមត្រូវ :*

១. ហេតុដែលនាំឱ្យមានទុក្ខ គឺ..***តណ្ហា***.. និង..***អវិជ្ជា*** ..។

## II. សំនួរត្រិះរិះ

**សំនួរទី ១.** តើសច្ចធម៌ជាអ្វី ?

**ចម្លើយ** សច្ចធម៌មកពីពាក្យ **សច្ច + ធម៌**

- **សច្ចៈ** គឺសេចក្តីពិត ដំណើរទៀង ទៀងទាត់ ដំណើរទៀងត្រង់ ការណ៍មែនប្រាកដ ។ ឧទាហរណ៍ : កាន់សច្ចៈ គឺកាន់សេចក្តីពិត ពាក្យសច្ចៈ គឺពាក្យពិត មានសច្ចៈ គឺមានសេចក្តីទៀងត្រង់ ។
- **ធម៌ ឬធម្មៈ** ជាសភាវទ្រទ្រង់សត្វលោក គឺបុណ្យ សុចរិត ហេតុ សភាព ការច្រើន ការរិះគិត ការប្រៀនប្រដៅ និងអ្វីៗដែលទ្រទ្រង់ធ្វើឱ្យឋិតថេរ ជាដំបូន្មានផ្តល់ឱ្យមនុស្សក្នុងការរំដោះខ្លួនចេញពីទុក្ខ ដើម្បីលើកស្ទួយតម្លៃមនុស្ស ។

➤**សច្ចធម៌** សំដៅទៅលើគុណភាពពិតប្រាកដ មិនបន្លំក្លែងក្លាយ ទៀងត្រង់ ឥតល្អៀង អ្វីដែលប្រាកដមែន ជាក់

ស្ដែងមិនភូតកុហក ។ សច្ចធម៌ ជាបញ្ញត្តិមួយយ៉ាងល្បីល្បាញដែលបានសង្ខេបខ្លឹមសារនៃពុទ្ធលទ្ធិតាំងពីលទ្ធិសាសនានេះបានចាប់កំណើតមកម្ល៉េះ និងជាធម៌អះអាងពីអ្វីដែលមានពិត ឬសច្ចៈ និងអះអាងពីអ្វីដែលត្រូវហាមមិនឱ្យប្រព្រឹត្ត ។

**<u>សំនួរទី ២.</u> តើការប្រកាន់ខ្ជាប់សច្ចធម៌បានផ្ដល់ផលអ្វីខ្លះ ?**

**<u>ចម្លើយ</u>** ការប្រកាន់ខ្ជាប់សច្ចធម៌ គឺការជួយខ្លួនឯង និងសង្គម ។ ផលនៃការប្រកាន់យកសច្ចធម៌មាន :

- មិនធ្លាក់ខ្លួនក្នុងផ្លូវខុស
- មិនមានសេចក្ដីភ័យខ្លាច ឬក្ដីអន្តរាយ
- មិនមានអ្នកជវៃទេតួះតិដៀល
- មានកិត្តិយស និងកេរ្ដិ៍ឈ្មោះល្អ
- មានស្មារតីនឹងនរ
- មានសេចក្ដីសុខទាំងនៅពេលបច្ចុប្បន្ន ទាំងក្នុងពេលអនាគត
- មានសាមគ្គីរឹងមាំ និងយូរអង្វែង
- កំចាត់បង់នូវក្ដីកង្វល់ ព្រោះមនុស្សប្រកាន់យកសច្ចធម៌

តែងតែមាននៅជុំវិញដោយមនុស្សល្អ
- ទទួលបានត្រឡប់មកវិញនូវសច្ចធម៌
- សំអាតចិត្តបានស្អាតបរិសុទ្ធ ។ល ។

**<u>សំនួរទី ៣.</u> តើទុក្ខសច្ចៈមានន័យដូចម្តេច ? រក ឧទាហរណ៍ ១ តើគេមានវិធី ឬ មាគ៌ាអ្វីខ្លះដើម្បី លុបបំបាត់ទុក្ខ ?**

**<u>ចម្លើយ</u> ទុក្ខសច្ចៈ** គឺអ្វីៗទាំងអស់តែងមានទុក្ខ ។ ទុក្ខជាសេចក្តីពិតដែលត្រូវតែកើតមានដល់មនុស្សគ្រប់រូបដោយមិនអាចចៀសផុតឡើយ គ្រាន់តែខុសគ្នានៅត្រង់អ្នកខ្លះមានទុក្ខតិច អ្នកខ្លះមានទុក្ខច្រើន ។ **ឧទាហរណ៍** ធម្មជាតិរបស់មនុស្សគ្រប់រូបតែងជួបនូវការ **កើត ចាស់ ឈឺ ស្លាប់** ដែលគេហៅថា វដ្តជីវិត ។

គេអាចមានវិធី ឬ មាគ៌ាដើម្បីលុបបំបាត់ទុក្ខ ឬផ្លូវទៅកាន់និពាន្ទ ដែលជាឋានរលត់ទុក្ខរបស់ព្រះពុទ្ធជាម្ចាស់ (មគ្គអរិយសច្ចៈ) ហៅថា **អដ្ឋង្គិកមគ្គ** (អាត់ ថាំង គិ កាក់ មាក់) : មាន ៨ គឺ :

- **សម្មាទិដ្ឋិ** (សាំ ម៉ា ទិត ថិ) : ការយល់ឃើញត្រូវ ។
- **សម្មាសង្កប្ប** (សាំ ម៉ា សង់ កាប់ ប៉ាក់) : ការត្រិះរិះ

ត្រូវ ។

- **សម្មាវាចា**( សាំ ម៉ា វា ចា ) : ពាក្យសំដីត្រូវ ។
- **សម្មាកម្មន្ត**( សាំ ម៉ា កាំ ម៉ាន់ តាក់ ) : ការងារត្រឹមត្រូវ ។
- **សម្មាអាជីវៈ**( សាំ ម៉ា អា ជី វាក់ ) : ចិញ្ចឹមជីវិតត្រូវ។
- **សម្មាវាយាមៈ**( សាំ ម៉ា វា យាម ម៉ាក់ ) : ការព្យាយាមក្នុងផ្លូវត្រូវ ។
- **សម្មាសតិ**( សាំ ម៉ា សតិ ) : ការភ្ញាក់រលឹកត្រឹមត្រូវ ។
- **សម្មាសមាធិ**( សាំ ម៉ា សាក់ ម៉ា ធិ ) : ការតាំងចិត្តត្រឹមត្រូវ ។

☛ **<u>សំនួរទី ៤.</u> តើការពោលពាក្យមិនពិត គ្មានសច្ចៈមានឥទ្ធិពលដូចម្ដេចខ្លះក្នុងចំណងមិត្តភាព ការប្រកបការងារផ្សេងៗ និងការជំនុំជម្រះក្ដីដល់ជនជាប់ចោទនៅតុលាការ ?**

✍ **<u>ចម្លើយ</u>** ការពោលពាក្យមិនពិត គ្មានសច្ចៈមានឥទ្ធិពលទាក់ទងក្នុងចំណងមិត្តភាព និងការប្រកបការងារផ្សេងៗ

និងការជំនុំជម្រះក្តីដល់ជនជាប់ចោទនៅតុលាការ

ដូចជា :

+ ចំណងមិត្តភាព និងការប្រកបការងារផ្សេងៗ

- ធ្លាក់ខ្លួនក្នុងផ្លូវខុស

- គ្មានកិត្តិយស និងកេរ្តិ៍ឈ្មោះមិនល្អ

- មានសេចក្តីភ័យខ្លាច ឬអន្តរាយនៅថ្ងៃអនាគត

- គ្មានភាពជឿទុកចិត្តគ្នា ទៅវិញទៅមក

- មានភាពរើសអើង

- គិតតែពីប្រយោជន៍ផ្ទាល់ខ្លួន

- លែងមានទំនាក់ទំនងរវាងគ្នា និងគ្នា

+ ការជំនុំជម្រះក្តី ដល់ជនជាប់ចោទនៅតុលាការ

- ធ្វើឱ្យអ្នកប្រព្រឹត្តអំពើរវាក្រក់បែរជាគ្មានទោស

- ធ្វើឱ្យមានអំពើអយុត្តិធម៌ក្នុងប្រព័ន្ធតុលាការ

- ធ្វើឱ្យមានអំពើពុករលួយ ស្ញកប៉ាន់ក្នុងប្រព័ន្ធតុលាការ

។ល។

<u>សំនួរទី ៥.</u> ចូរបង្ហាញសកម្មភាពរបស់អ្នកក្នុងពេល

កន្លងមកដែលសកម្មភាពទាំងនោះទាក់ទងនឹងសច្ចធម៌ង

✍ **ចម្លើយ** សកម្មភាពរបស់ខ្ញុំ ក្នុងពេលកន្លងមកដែលទាក់ទង និងសច្ចធម៌នោះ :

- គោរពពេលវេលា
- ប្រព្រឹត្តអំពើល្អ
- និយាយពាក្យពិត មិនកុហក
- គោរពកិច្ចព្រមព្រៀង ការសន្យា ... ។ល។

☛ **សំនួរទី ៦. តើអរិយសច្ចធម៌មានប៉ុន្មាន ? អ្វីខ្លះ ? ចូររៀបរាប់ចំណុចនីមួយៗ ?**

✍ **ចម្លើយ** **អរិយសច្ចៈ**មាន ៤ **យ៉ាង** គឺ :

**១. ទុក្ខសច្ចៈ** គឺអ្វីៗទាំងអស់តែងមានទុក្ខ ។ ទុក្ខជាសេចក្ដីពិត ដែលត្រូវតែកើតមានដល់មនុស្សគ្រប់រូបដោយមិនអាចចៀសផុតឡើយ គ្រាន់តែខុសគ្នានៅត្រង់អ្នកខ្លះមានទុក្ខតិច អ្នកខ្លះមានទុក្ខច្រើន ។

**២. សមុទយសច្ចៈ** ទុក្ខជាសេចក្ដីពិតដែលកើតឡើងមកពីហេតុពិតប្រាកដ ។ ហេតុដែលនាំឱ្យមានទុក្ខ គឺ តណ្ហា និង អវិជ្ជា ។

៣. **និរោធសច្ចៈ** គឺការរួចស្រឡះពីទុក្ខ ឬការលុបបំបាត់ទុក្ខ។ សច្ចធម៌ទី ៣ នេះ គឺការយល់ដឹងថា បើមនុស្សបន្ថយឬរំលត់លោភៈ ទោសៈ និងមោហៈបាន នោះទុក្ខនឹងត្រូវបានបញ្ចប់ផងដែរ ។

៤. **មគ្គសច្ចៈ** គឺជាមាគ៌ា ឬមធ្យោបាយនាំឱ្យផុតទុក្ខជាសេចក្ដីពិត ។ ទុក្ខអាចរំលត់បានតាមមាគ៌ាទាំង៨យ៉ាងរបស់ព្រះពុទ្ធ ។ ទាំងនេះជាសច្ចធម៌ពិតនៃលោកធាតុ ទាំងឡាយដែលមានអត្ថិភាពនៅលើលោកនេះ ។ អ្វីៗទាំងអស់សុទ្ធតែប្រែប្រួលពីទម្រង់មួយ ទៅទម្រង់មួយដែលគេឱ្យឈ្មោះថា **អនត្តា** ។

**សំនួរទី ៧. ហេតុអ្វីបានជាគេលើកយកពាក្យ " សច្ចៈ និងសច្ចធម៌ " មកប្រើ ?**

**ចម្លើយ** ការលើកយកពាក្យ " **សច្ចៈ** និង **សច្ចធម៌** " មកប្រើនេះ ក្នុងបំណងឱ្យមនុស្សគ្រប់រូបយល់ដឹង និងប្រកាន់ខ្ជាប់ សច្ចធម៌នៅក្នុងស្មារតីរបស់ខ្លួន ។ បច្ចុប្បន្នសច្ចធម៌នៅតែជាគោលការណ៍មួយយ៉ាងសំខាន់នៅក្នុងការកំណត់ស្មារតី ចិត្តគំនិត និងសកម្មភាពរបស់មនុស្សដែលរស់នៅក្នុងសង្គមនីមួយៗ ។

**សំនួរទី ៨.** ព្រះពុទ្ធទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញាណ ៗ តើព្រះអង្គទ្រង់ត្រាស់ដឹងអ្វីខ្លះ ?

**ចម្លើយ** ព្រះពុទ្ធទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញាណ គឺ អរិយសច្ចៈ បួន មាន :

- **ទុក្ខសច្ចៈ** : ភាវៈទាំងអស់បណ្តាលអោយមានទុក្ខ ។
- **សមុទយសច្ចៈ** : ប្រភពនៃទុក្ខ គឺអវិជ្ជា និងតណ្ហា ។
- **និរោធសច្ចៈ** : ឋាន ដែលជាទីរំលត់ទុក្ខ គឺព្រះនិព្វាន ។
- **មគ្គសច្ចៈ** : ផ្លូវ ដែលព្រះពុទ្ធអង្គរកឃើញទៅកាន់និព្វាន

**សំនួរទី ៩.** តើទុក្ខធំៗទាំង ៤ យ៉ាងក្នុងព្រះពុទ្ធសាសនាមានអ្វីខ្លះ ?

**ចម្លើយ** ទុក្ខធំៗទាំងមាន ៤ យ៉ាងនៅក្នុងព្រះពុទ្ធសាសនា គឺ :

- **ជាតិទុក្ខ** គឺទុក្ខព្រោះមានកំណើត( តាំងពីនៅក្នុងផ្ទៃម្តាយម្ល៉េះ )។
- **ព្យាធិទុក្ខ** គឺទុក្ខព្រោះមានជម្ងឺផ្សេងៗមកបៀតបៀន
- **ជរាទុក្ខ** គឺទុក្ខព្រោះចាស់គ្រាំគ្រា ទ្រុឌទ្រោម ។
- **មរណទុក្ខ** គឺទុក្ខព្រោះស្លាប់ ( មានការចុកចាប់ ឬ ពិបាកខ្លាំងនៅពេលជិតស្លាប់ ) ។

# មេរៀនទី៥ : សេរីភាព

## I. សំនួរត្រិះរិះ

**សំនួរទី ១. ដូចម្តេចហៅថា សេរីភាព ?**

**ចម្លើយ** **សេរីភាព** ជាអ្វីដែលមនុស្សគ្រប់រូបប្រាថ្នាចង់បានគ្រប់គ្នា ។

- សេចក្តីប្រកាសអំពីសិទ្ធិមនុស្សនៅឆ្នាំ 1789 របស់ប្រទេសបារាំង បានឱ្យនិយមន័យ**សេរីភាព** ថាជាអំណាច ឬ សិទ្ធិក្នុងការបំពេញសកម្មភាពអ្វីមួយ ដែលមិនឱ្យធ្វើខូចខាតដល់ប្រយោជន៍អ្នកដទៃ ។
- បើតាមវចនានុក្រមខ្មែរ **សេរីភាព** មានន័យថាអំណាចដែលអាចធ្វើអ្វីបានតាមអំពើចិត្ត ប៉ុន្តែស្ថិតក្រោមច្បាប់ ។
- ឯលោក**កាល់ម៉ាក់** បានពោលថា សេរីភាព គឺជាការទទួលស្គាល់ ការគោរព និងការបំពេញដោយម៉ត់ចត់នូវតួនាទី និងភារកិច្ចរបស់ខ្លួន ។

➢ដូច្នេះ**សេរីភាព** គឺជាអំណាចក្នុងការធ្វើអ្វីបាន កុំឱ្យតែប៉ះពាល់ដល់សិទ្ធិអ្នកដទៃ ។ តាមន័យនេះ **សេរីភាព** សម្គាល់ បាននូវភាពធ្វើអ្វីៗ បានតាមចិត្តដោយគ្មានការ

បង្ខិតបង្ខំ ទោះបីក្នុងផ្លូវគំនិតក្តី ជំនឿក្តី និង សកម្មភាព ប្រែបសព្វយ៉ាងក្តី អាចធ្វើបានតាមចិត្ត ឱ្យតែស្ថិតក្នុងក្រប ខ័ណ្ឌច្បាប់កំណត់ ។

**<u>សំនួរទី ២.</u> ប្រៀបធៀបទស្សនៈរបស់ទស្សនវិទូមួយ ចំនួនទាក់ទងនឹងសេរីភាព ?**

**<u>ចម្លើយ</u>** ទស្សនៈរបស់ទស្សនវិទូជាច្រើនបានបកស្រាយ អំពីសេរីភាពដូចខាងក្រោម :

. **ហ្សង់ ហ្សាក់រូសូ** (Jean Jacque Rausseau ) បាន និយាយថា មនុស្សខុសពីសត្វត្រង់មនុស្សមានសមត្ថភាព ក្នុងការជ្រើសរើសយកសកម្មភាពទាំងឡាយណា ដែលគេ អាចធ្វើបានមកអនុវត្ត ។

. **ដេ កាត** (Descart) សេរីភាព គឺស្ថិតនៅត្រង់ការទទួល ស្គាល់ការពិត ព្រោះជនគ្មានសេរីភាពពុំហ៊ានទទួលស្គាល់ ការពិតទេ ឃើញអាក្រក់ថា ល្អ ឃើញស ថាខ្មៅ ឃើញ បាប ថាបុណ្យ ។

. **បូ ស៊ុយអេ** សេរីភាព ជាសិទ្ធិធ្វើអ្វីៗដែលច្បាប់អនុញ្ញាត ឱ្យធ្វើ ។

. **អាល់ ប៊ែកាមុស** (Alber Camus) យល់ថាសេរីភាព

គឺជាការភ្ញាក់ខ្លួន ដោយដឹងថាជីវិតរបស់យើងទាំងអស់គ្នាសព្វថ្ងៃ គឺជាជីវិតឥតន័យ ហេតុនេះយើងត្រូវធ្វើខ្លួនដើម្បីរកន័យពិតឱ្យជីវិតមានន័យ ។

. **ស្យង់ ប៉ូលសាត្រ** (**Jean Paul Sartre**) សេរីភាព គឺភាពធ្វើអ្វីៗដោយគ្មានលក្ខខណ្ឌ ។ ក្នុងន័យនេះលោកឱ្យមនុស្សមានសេរីភាពស្មើគ្នាដោយមិនគិតពីវណ្ណៈឬមុខងាររបស់អ្នកតូច ឬអ្នកធំ អ្នកមានបុណ្យសក្តិ អ្នកក្រ ឬអ្នកមានឡើយ ។ បើអ្នកចង់ប្រកបមុខរបរណាមួយដែលអ្នកយល់ថានឹងបានធ្វើឱ្យជីវិតរបស់អ្នកមានសេចក្តីសុខក៏ស្រេចតែអ្នក ហើយអ្នកចង់គោរព ឬមានជំនឿលើសាសនាណាក៏គ្មាននរណាហាមឃាត់ដែរ ព្រោះនេះជាសិទ្ធិសេរីភាពរបស់អ្នក តែសេរីភាពទាំងអស់នេះត្រូវសមស្របទៅតាមច្បាប់សង្គម ។

**<u>សំនួរទី ៣.</u> ហេតុអ្វីបានជាមនុស្សត្រូវការសេរីភាព?**

**<u>ចម្លើយ</u>** បានជាមនុស្សយើងត្រូវការសេរីភាព ព្រោះ :

- ចង់បង្ហាញពីឥស្សរភាពរបស់ខ្លួន ការបញ្ជាក់ឱ្យឃើញពីខ្លួនឯង
- ចង់បង្ហាញពីតម្លៃជាមនុស្ស

- ចង់ធ្វើអ្វីៗតាមឆន្ទៈរបស់ខ្លួន ដែលស្របទៅនឹងច្បាប់សង្គម
- សេរីភាព ជាឧបករណ៍ដ៏សំខាន់មួយក្នុងការប្រឆាំងនឹងការរំលោភសិទ្ធិ ។

**សំនួរទី ៤.** **តើការប្រើសេរីភាពដោយខ្វះការទទួលខុសត្រូវ នឹងនាំឱ្យមានផលអាក្រក់អ្វីខ្លះដល់មនុស្ស និងសង្គម ?**

**ចម្លើយ** ការប្រើសេរីភាពដោយខ្វះការទទួលខុសត្រូវ នឹងនាំឱ្យមានផលអាក្រក់ដល់មនុស្ស និងសង្គមដូចជា អាចឱ្យមនុស្សប្រើប្រាស់សេរីភាពរបស់ខ្លួនហួសដែនច្បាប់កំណត់ដែលធ្វើឱ្យអ្នកនោះក្លាយជាមនុស្សដែលរំលោភច្បាប់ រំលោភសិទ្ធិអ្នកដទៃ និងធ្វើឱ្យសង្គមមានភាពអនាធិបតេយ្យ បក្សពួកនិយម និងធ្វើឱ្យសង្គមគ្មានសន្តិសុខសេរីភាព ។

**សំនួរទី ៥.** **ចូរអ្នកឆ្លុះបញ្ចាំងពីការប្រើប្រាស់សេរីភាពរបស់អ្នកកន្លងមក តើមានភាពត្រឹមត្រូវ និងស្របច្បាប់ ឬទេ ?**

**ចម្លើយ** ប្រើប្រាស់សេរីភាពរបស់ខ្ញុំកន្លងមកមានភាពត្រឹមត្រូវ និងស្របច្បាប់ ព្រោះក្នុងនាមខ្ញុំជាសិស្សមួយរូបដោយការប្រើប្រាស់សេរីភាពរបស់ខ្ញុំត្រឹមត្រូវតែក្នុងការបញ្ចេញមតិ ការជួបជុំគ្នាក្នុងការសិក្សាក្នុងសហគមន៍ដែលខ្ញុំរស់នៅដើម្បីផ្លាស់ប្តូរនូវចំណេះដឹងគ្នាទៅវិញទៅមកតែប៉ុណ្ណោះ ។

**សំនួរទី ៦. តើសេរីភាពចែកចេញជាប៉ុន្មានប្រភេទ? អ្វីខ្លះ ?**

**ចម្លើយ** តាមទស្សនៈមួយចំនួនស្តីពីសេរីភាព គេបានបែងចែកសេរីភាពជា ៤ យ៉ាងតាមប្រភេទដូចខាងក្រោម :

**១. សេរីភាពធម្មជាតិ គឺ**

. គ្មានការគំរាមកំហែង និងការបង្ខិតបង្ខំពីអ្នកដទៃ

. អាចធ្វើអ្វីៗបានតាមធម្មជាតិ ឬតាមឆន្ទៈរបស់មនុស្សម្នាក់ៗ

. គ្មានឧបសគ្គមករារាំងមនសិការរបស់គេម្នាក់ៗ និងធ្វើកិច្ចការដោយសេរី

**២. សេរីភាពពលរដ្ឋ :** ប្រជាពលរដ្ឋម្នាក់ៗមានសេរីភាពធ្វើអ្វីៗបានគ្រប់យ៉ាងតាមចិត្តប្រាថ្នារបស់ខ្លួន ដោយច្បាប់

អនុញ្ញាត ។ ការអនុវត្តច្បាប់ ត្រូវមានភាពយុត្តិធម៌ និង ប្រជាធិបតេយ្យ ។

៣. **សេរីភាពនយោបាយ :** ពលរដ្ឋម្នាក់ៗមានសេរីភាពក្នុង ការធ្វើនយោបាយ ឱ្យតែនយោបាយនោះ អាចធ្វើឱ្យប្រ ជាពលរដ្ឋបានសេចក្តីសុខចម្រើន សម្បូរសប្បាយក្នុង ស្ថានភាពមួយដ៏ប្រសើរ ។ សេរីភាពនយោបាយឋិតនៅ លើការអនុញ្ញាតឱ្យប្រជាពលរដ្ឋបានជួបប្រជុំគ្នា អាច បង្កើតសមាគមមានសិទ្ធិបញ្ចេញមតិយោបល់ និងសិទ្ធិ សរសេរអត្ថបទ ។ល ។

៤. **សេរីភាពសេដ្ឋកិច្ច :** ពលរដ្ឋម្នាក់ៗមានសេរីភាពប្រកប វិជ្ជាជីវៈ បានតាមចំណូលចិត្តរបស់ខ្លួន ។

ប្រជាពលរដ្ឋគ្រប់រូបមានសេរីភាពគ្រប់បែបយ៉ាង ប៉ុន្តែស្ថិតនៅក្នុងរង្វង់ច្បាប់ ។ ប្រសិនបើគេប្រើសេរីភាព ហួសព្រំដែនច្បាប់កំណត់ នោះនឹងមានឈ្មោះថា ជាអ្នក រំលោភច្បាប់ រំលោភលើសិទ្ធិ និងការកិច្ចតួនាទីរបស់ • អ្នកដទៃ នឹងនាំឱ្យកើតមានភាពអនាធិបតេយ្យ បក្សពួក និយម អំណាចផ្តាច់ការ និងធ្វើឱ្យសង្គមគ្មានសន្តិសុខ និងអស្ថិរភាព ។

# មេរៀនទី៦ : ឯករាជភាព

## I. សំនួរទ្រឹស្ដី

☛ <u>សំនួរទី ១.</u> តើពាក្យឯករាជភាព ឬឯករាជ្យមានន័យដូចម្ដេច ?

✍ <u>ចម្លើយ</u> ឯករាជភាព ឬឯករាជ្យ ជាពាក្យដែលមនុស្សគ្រប់រូបចាត់ទុកថាជាពាក្យមានអត្ថន័យសំខាន់ ហើយទាក់ទងទៅនឹងការ ទាមទារចង់បានរបស់មនុស្សគ្រប់រូប និងប្រទេសនីមួយៗនៅលើពិភពលោក ។

☛ <u>សំនួរទី ២.</u> តើបុគ្គលមានឯករាជ្យ និងបុគ្គលគ្មានឯករាជ្យខុសគ្នាដូចម្ដេច ?

✍ <u>ចម្លើយ</u> អ្នកបានឯករាជភាព គឺអ្នកដែលមិននៅក្រោមចំណុះអ្នកដទៃ ហើយមានសិទ្ធិសេរីភាពពេញលេញ អាចធ្វើអ្វីៗដែលគេត្រូវធ្វើ ឱ្យតែទង្វើនោះមិនប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃ ហើយស្ថិតនៅក្នុងក្របខ័ណ្ឌច្បាប់ ។

បុគ្គលដែលមានឯករាជភាព គឺបុគ្គលមានសិទ្ធិសេរីភាពពេញលេញក្នុងការសម្រេចចិត្តធ្វើអ្វីមួយដោយខ្លួនឯង ដោយមិនស្ថិតនៅក្រោមឥទ្ធិពលនៃអ្នកដទៃ ។ តម្រូវ

ការជាសំខាន់ គឺគេចង់បានសេរីភាព និងជ្រើសរើសផ្លូវមួយតាមបំណងប្រាថ្នារបស់គេដោយគ្មានអ្នកណាបង្ខិតបង្ខំ ។ ឧទាហរណ៍ : ទោះជាកសិករក្តី ពាណិជ្ជករក្តី បើគាត់មានឯករាជភាព គាត់អាច ដាំដំណាំអ្វី ប្រកបមុខរបរអ្វី តាមបំណងចំណូលចិត្តរបស់គាត់ ឱ្យតែមុខរបរនោះស្របច្បាប់ និងមិនប៉ះពាល់ដល់ផលប្រយោជន៍អ្នកដទៃ។

**<u>សំនួរទី ៣.</u> បង្ហាញលក្ខណៈខុសគ្នារវាងតុលាការមានឯករាជ្យភាព និងតុលាការគ្មានឯករាជ្យ ?**

**<u>ចម្លើយ</u>** ភាពខុសគ្នារវាងតុលាការមានឯករាជ្យភាព និងតុលាការគ្មានឯករាជ្យ

**ក. តុលាការមានឯករាជ្យភាព** គឺ :

- មិននៅក្រោមឥទ្ធិពលនៃស្ថាប័ន ឬបុគ្គលមានអំណាចណាម្នាក់ឡើយ ។
- ការជម្រះក្តីដោយសុចរិត យុត្តិធម៌ ឥតលំអៀង និងហ៊ានធ្វើសេចក្តីសម្រេចដោយឯករាជ្យពិតៗ ។
- មិនទទួលឥទ្ធិពល ឬបទបញ្ជាពីអ្នកដទៃ ហើយមានសិទ្ធិសេរីភាពក្នុងការសម្រេចធ្វើអ្វីមួយ ។
- កាត់ក្តីតាមគតិយុត្តិធម៌ ផ្អែកលើហេតុការណ៍ ដែលមាន

នៅចំពោះមុខ ។

- មិនចំណុះអំណាចនីតិប្រតិបត្តិ នីតិបញ្ញត្តិ ឬ ក្រោមភាគីនយោបាយណាមួយឡើយ
- ជាអ្នកសុចរិត និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញមុខងារក្នុងតុលាការ ។
- រក្សា ***អនាគតិ*** វៀរចាកអគតិទាំង ៤ យ៉ាង គឺឆន្ទាគតិ (លំអៀងព្រោះការស្រឡាញ់) ទោសាគតិ (លំអៀងព្រោះស្អប់) មោហាគតិ (លំអៀងព្រោះវង្វេង) និងភយាគតិ (លំអៀងព្រោះការភ័យខ្លាច) ។

**ខ- តុលាការគ្មានឯករាជ្យភាព** គឺ មានលក្ខណៈផ្ទុយគ្នា ពីចំណុច **ក** ខាងលើ ។

**__សំនួរទី ៤.__ ហេតុអ្វីបានជាអំណាចតុលាការត្រូវតែជាអំណាចឯករាជ្យ ?**

**__ចម្លើយ__** បានជាអំណាចតុលាការត្រូវតែ ជាអំណាចឯករាជ្យ ព្រោះ :

- គេចង់បានភាពយុត្តិធម៌មួយពីការកាត់ក្តីដោយត្រឹមត្រូវ
- ដើម្បីការពារសិទ្ធិសេរីភាព និងករណីយកិច្ចរបស់ប្រជាពលរដ្ឋដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ

- ដើម្បីរក្សាការពារសណ្តាប់ធ្នាប់ សន្តិសុខសាធារណៈ
- ដើម្បីរក្សាការពារ សុវត្ថិភាពផ្លូវកាយ និងផ្លូវចិត្តជូនដល់ប្រជាពលរដ្ឋ
- ដើម្បីទប់ស្កាត់ មិនអោយសិទ្ធិរបស់បុគ្គលម្នាក់ប្រើហួសព្រំដែនដែលទៅរំលោភដល់សិទ្ធិអ្នកដទៃ
- ដើម្បីផ្តល់យុត្តិធម៌ដល់ប្រជារាស្ត្រ ធានាដល់ការអនុវត្តច្បាប់អោយមានប្រសិទ្ធភាព

ប្រសិនបើតុលាការគ្មានឯករាជ្យ យុត្តិធម៌ប្រជារាស្ត្រគ្មានជំនឿលើច្បាប់ ហើយប្រាកដជារិះរកមធ្យោបាយផ្ទាល់ខ្លួនដោយមិនពឹងលើច្បាប់ ដែលអាចនាំអោយមានបញ្ហាអស្ថិរភាពសង្គម ។

**សំនួរទី ៥. ហេតុអ្វីបានជាមនុស្សម្នាក់ៗ ប្រទេសនីមួយៗតែងតែទាមទារចង់បានឯករាជភាព ?**

**ចម្លើយ** បានជាមនុស្សម្នាក់ៗ ប្រទេសនីមួយៗតែងតែទាមទារចង់បានឯករាជភាព ព្រោះ ការមានឯករាជភាពអាចមានលទ្ធភាពជួយខ្លួនឯងផង និងជួយដល់សង្គមផង ។ ការមានឯករាជ្យគឺ មនុស្ស

រស់នៅមានសេរីភាពពេញលេញទាំងក្នុងការគិត ទាំងក្នុង

ការប្រកបមុខរបរផ្សេងៗដទៃទៀត ។

- រស់នៅជាមនុស្សមានកិត្តិយស មានភាពថ្លៃថ្នូរ និងគ្មានការគាបសង្កត់ពីអ្នកដទៃ ។
- មានសេរីភាពក្នុងការកសាងសុភមង្គលដោយខ្លួនឯង មិនពឹងពាក់អ្នកដទៃ គឺខ្លួនទីពឹងខ្លួន ។
- រស់នៅដោយស្ងប់ចិត្ត មិនខ្វាយខ្វល់ មិនខ្លាចពីឥទ្ធិពលខាងក្រៅ ។

ការមានឯករាជភាពនេះជាការប្រសើរត្រង់ថា អ្វីៗដែលយើងធ្វើ គឺយើងជាអ្នកទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ។

**សំនួរទី ៦.** តើរដ្ឋឯករាជ្យ ជារដ្ឋដូចម្ដេច ?

**ចម្លើយ** រដ្ឋឯករាជ្យ គឺរដ្ឋមានអធិបតេយ្យភាពពេញលេញ រដ្ឋមិនចំណុះរដ្ឋដទៃ និងមានស្វ័យភាពខាងនយោបាយ សេដ្ឋកិច្ច ។ល ។

**សំនួរទី ៧.** ដើម្បីឱ្យមានឈ្មោះថាតុលាការឯករាជ ឬ តុលាការល្អ ត្រូវបញ្ចៀសនូវអគតិប៉ុន្មានយ៉ាង? អ្វីខ្លះ ?

**ចម្លើយ** តុលាការត្រូវសម្រេចរឿងក្ដីទាំងអស់ដោយ

ឯករាជ្យ និងមិនលំអៀង ជាពិសេសផ្អែកលើអង្គហេតុ ដែលបានត្រួតពិនិត្យ យ៉ាងម៉ត់ចត់ និងអង្គច្បាប់ដែលត្រូវយកមកអនុវត្ត ។ តុលាការឯករាជត្រូវជៀសវាងការកាត់ក្តីដោយអគតិ ៤ យ៉ាង គឺ

១. **ឆន្ទាគតិ** : វៀរចាកនូវការលំអៀងព្រោះ សេចក្តីស្រឡាញ់ ។

២. **ទោសាគតិ** : វៀរចាកនូវការលំអៀងព្រោះ សេចក្តីស្អប់ ។

៣. **មោហាគតិ** : វៀរចាកនូវការលំអៀងព្រោះ សេចក្តីល្ងង់ វង្វេង មិនយល់ច្បាស់ពីខ្លួនឯង ។

៤. **ភយាគតិ** : វៀរចាកនូវការលំអៀងព្រោះ សេចក្តីភ័យខ្លាច ។



តុល្យភាពសិទ្ធិនិងការទទួលខុសត្រូវ

មេរៀនទី៧ : ការវិនិច្ឆ័យ

## I. សំនួរត្រិះរិះ

**សំនួរទី ១. ដូចម្តេចហៅថា ការវិនិច្ឆ័យ ?**

**ចម្លើយ** ការវិនិច្ឆ័យ ជាការវិភាគ ពិចារណាល្អិតល្អន់ ការពិនិត្យមើលឱ្យឃើញពិត ដំណើរពិចារណា ការជំនុំជម្រះសេចក្តី ការកាត់សេចក្តីដោយផ្អែកលើច្បាប់ បទដ្ឋានវប្បធម៌ សីលធម៌ ការទទួលខុសត្រូវនៃអំពើរបស់មនុស្ស ។

ឧទាហរណ៍: ការវិនិច្ឆ័យរបស់តុលាការអំពីទោសទណ្ឌអ្វីមួយ គឺបានឆ្លងកាត់ការស៊ើបអង្កេត ស៊ើបសួរ ជំនុំជម្រះ និងធ្វើការកាត់សេចក្តី ។

**សំនួរទី ២. ដូចម្តេចហៅថា ប្រធានវិស័យភាព ? វត្ថុវិស័យភាព ?**

**ចម្លើយ** **ប្រធានវិស័យភាព ឬគេហៅថា ការវិនិច្ឆ័យតាមបែបអត្តនោម័ត** ជាការវិនិច្ឆ័យរបស់បុគ្គលទៅលើស្ថានភាព វត្ថុ ឬបាតុភូតដែលខ្លួនកំពុងជួបប្រទះ ។

- **វត្ថុវិស័យភាព ឬគេហៅថា ការវិនិច្ឆ័យតាមបែបបរានុម័ត** ជាការវិនិច្ឆ័យរបស់បុគ្គលផ្អែកតាមតថភាព ដោយស្រប

តាមគុណសម្បត្តិពិត តម្លៃពិតរបស់វត្ថុ ឬស្ថានភាពដែលជួបប្រទះ ។ ម្យ៉ាងទៀត **ការវិនិច្ឆ័យតាមបែបវត្ថុវិស័យ**ភាព ជាការវិនិច្ឆ័យ ដែលមានលក្ខណៈសកល គឺជាពិភព ឬ តថភាពខាងក្រៅមានអត្ថិភាពឯករាជ្យពីគំនិតរបស់យើង ។

**សំនួរទី ៣.** **ចូរប្រៀបធៀប ការវិនិច្ឆ័យតាមបែបប្រធានវិស័យភាព និងតាមបែបវត្ថុវិស័យភាព ។**

**ចម្លើយ** ប្រៀបធៀប ការវិនិច្ឆ័យតាមបែបប្រធានវិស័យភាព និងតាមបែបវត្ថុវិស័យភាព

- **ប្រធានវិស័យភាព ឬគេហៅថា ការវិនិច្ឆ័យតាមបែបអត្តនោម័ត** ជាការវិនិច្ឆ័យរបស់បុគ្គលទៅលើស្ថានភាពវត្ថុ ឬបាតុភូតដែលខ្លួនកំពុងជួបប្រទះ ។
- **វត្ថុវិស័យភាព ឬគេហៅថា ការវិនិច្ឆ័យតាមបែបបរានុម័ត** ជាការវិនិច្ឆ័យរបស់បុគ្គលផ្អែកតាមតថភាព ដោយស្របតាមគុណសម្បត្តិពិត តម្លៃពិតរបស់វត្ថុ ឬស្ថានភាពដែលជួបប្រទះ ។ ម្យ៉ាងទៀត **ការវិនិច្ឆ័យតាមបែបវត្ថុវិស័យ**ភាព ជាការវិនិច្ឆ័យ ដែលមានលក្ខណៈសកល គឺជាពិភព ឬ តថភាពខាងក្រៅមានអត្ថិភាពឯករាជ្យពីគំនិតរបស់យើង ។

**សំនួរទី ៤.** តើអ្វីជាការវិនិច្ឆ័យដោយគតិ និងដោយអគតិ ?

**ចម្លើយ** . ការវិនិច្ឆ័យដោយគតិ គឺជាការវិនិច្ឆ័យធ្វើងថ្លែង ដឹងខុស ដឹងត្រូវ ដឹងស្រាល ដឹងធ្ងន់ ស្របតាមតថភាពជាក់ស្តែង ប្រកបដោយសុជនៈពិតប្រាកដក្នុងការធ្វើឱ្យអ្វីដែលខ្លួនវិនិច្ឆ័យនោះមានការរីកចម្រើន ។

. ការវិនិច្ឆ័យដោយអគតិ គឺជាការវិនិច្ឆ័យមិនស្របទៅនឹងស្ថានភាពពិតជាក់ស្តែង មិនបានគិតពិចារណាត្រឹមត្រូវ ធ្វើការវិនិច្ឆ័យខុសពីសីលធម៌សង្គម ។

**សំនួរទី ៥.** ចូរពន្យល់ពីផលនៃការវិនិច្ឆ័យដោយគតិ និងអគតិ ៗ

**ចម្លើយ** . ផលនៃការវិនិច្ឆ័យដោយគតិ មានធ្វើឱ្យមនុស្សយល់ដឹងអំពីអំពើល្អ និងអំពើអាក្រក់ យល់អំពីករណីកិច្ច យល់អំពីសិទ្ធិ ច្បាប់ និងការយល់អំពីទំនួលខុសត្រូវជាដើម។

. ផលនៃការវិនិច្ឆ័យដោយអគតិ បានផ្តល់ឱ្យមនុស្សក្លាយជាមនុស្សអត្តទត្តភាព មានមោទភាពលើខ្លួនឯង មានការក្រអឺតក្រទម ចិត្តរឹងរូសប្រណែន មើលងាយអ្នកដទៃ

បង្កើតភាពក្រេវក្រោធពីអ្នកជុំវិញខ្លួន និងរមែងនាំបុគ្គលនោះឱ្យទទួលទុក្ខវេទនា កម្មពៀរមិនចេះចប់ ធ្វើឱ្យភាពស្ងប់ស្ងាត់របស់ខ្លួនក្លាយជាកំហឹង និងរស់នៅក្នុងភាពឯកោ ។

**សំនួរទី ៦. តើមានវិធីណាខ្លះក្នុងការជួយយើង ដើម្បីធ្វើការវិនិច្ឆ័យឱ្យបានត្រឹមត្រូវ ?**

**ចម្លើយ** ដើម្បីធ្វើការវិនិច្ឆ័យ ឱ្យបានត្រឹមត្រូវយើងត្រូវ :

- ពិចារណាឆ្លុះបញ្ចាំងឱ្យបានច្បាស់លាស់អំពីវត្ថុ ឬធាតុភូតដែលយើងត្រូវវិនិច្ឆ័យ
- ពឹងផ្អែកលើបទពិសោធន៍ និងចំណេះដឹង
- យល់ដឹងអំពីអំពើល្អ ឬអាក្រក់ដឹងពីករណីកិច្ចការយល់អំពីសិទ្ធិ ច្បាប់ និងការទទួលខុសត្រូវ
- ត្រូវមានព្រហ្មវិហារធម៌ក្នុងខ្លួនព្រោះជាផ្លូវនាំទៅរកការវិនិច្ឆ័យបានត្រឹមត្រូវ ។

# មេរៀនទី៨ : ការអធ្យាស្រ័យ និងការសណ្ដោស

## I. សំនួរត្រិះរិះ

**សំនួរទី ១.** **តើការអធ្យាស្រ័យមានន័យដូចម្ដេច ?**

**ចម្លើយ** **ការអធ្យាស្រ័យ** គឺការគោរពគ្នា យោគយល់ ការអត់ឱនគ្នា តាមរយៈយល់ចិត្តគ្នាទៅវិញទៅមកទាំងកាយ វាចា ទាំងចិត្ត ។

**សំនួរទី ២.** **តើកន្លងមកអ្នកធ្លាប់បានអធ្យាស្រ័យឱ្យអ្នកដទៃដែរឬទេ ? ចូររៀបរាប់អំពីហេតុការណ៍នោះ។ ប្រសិនបើយើងគ្មានការអធ្យាស្រ័យទេ តើយើងនឹងជួបបញ្ហាអ្វីខ្លះ ?**

**ចម្លើយ** កន្លងមកខ្ញុំធ្លាប់បានអធ្យាស្រ័យឱ្យអ្នកដទៃ ដូចជា :

- ការដើរបុកគ្នាដោយអចេតនានៅកន្លែងចង្អៀត ពេលបុណ្យអុំទូក ឬការបាញ់កាំជ្រួចជាដើម
- គ្រោះថ្នាក់ចរាចរបន្តិចបន្តួច ខូចខាតរបស់របរ (ដោយអចេតនា)
- ការគេទូរស័ព្ទចូលដោយច្រឡំលេខ
- ការជិះម៉ូតូ ឬរថយន្តសាចទឹកប៉ះខ្ញុំដោយអចេតនា ។ល។

**<u>សំនួរទី ៣.</u> តើការប្រកាន់ចិត្តអធ្យាស្រ័យចំពោះអ្នកដទៃ នាំមកផលប្រយោជន៍អ្វីខ្លះដល់ខ្លួនឯង គ្រួសារ និងសង្គម ?**

**<u>ចម្លើយ</u>** ការប្រកាន់ចិត្តអធ្យាស្រ័យចំពោះអ្នកដទៃ នាំមកនូវផលប្រយោជន៍ដល់ខ្លួនឯង គ្រួសារ និងសង្គម ដូចតទៅ :

**ក. ចំពោះខ្លួនផ្ទាល់ :**

- មានកិត្តិយស សេចក្ដីថ្លៃថ្នូរ និងមានតម្លៃជាមនុស្ស
- មានភាពទំនាក់ទំនងល្អជាមួយអ្នកដទៃ មានមិត្តភក្ដិច្រើន
- ធូរស្បើយក្នុងចិត្ត ស្រឡះខ្លួន មិនអំពុលចំពោះចិត្តខ្លួន
- បង្ហាញពីចិត្តមេត្តា ករុណារបស់ខ្លួន
- គ្មានជម្លោះ និងមានសុខសាន្ត
- ងាយស្រួលរកការងារធ្វើ មានមនុស្សជួយយកយោង
- ជាមនុស្សពោរពេញដោយក្ដីរីករាយ ។

ខ. ចំពោះគ្រួសារ :

- មានកិត្តិយស សេចក្ដីថ្លៃថ្នូរ និងមានតម្លៃក្នុងគ្រួសារ
- មានភាពទំនាក់ទំនងល្អជាមួយអ្នកដទៃ មានមិត្តភក្ដិ

ច្រើន ញាតិជិតខាងច្រើន
- គ្រួសារមានសុភមង្គល រស់នៅដោយសុខដុមរមនា
- គ្មានអំពើហិង្សាក្នុងគ្រួសារ
- មានភាពរីករាយនៅក្នុងគ្រួសារ ។

**គ. ចំពោះសង្គម :**
- បានបណ្ដុះនូវវប្បធម៌សន្តិភាព គ្មានជម្លោះ គ្មានអំពើហិង្សាក្នុងគ្រួសារ
- ប្រទេសជាតិមានការរីកចម្រើន ។

**សំនួរទី ៤. ដូចម្ដេចហៅថា ការសន្ដោស ?**

**ចម្លើយ** ការសន្ដោស គឺជាសេចក្ដីត្រេកអរពេញចិត្ត ចំពោះវត្ថុដែលជារបស់ខ្លួនមាន របស់ដែលខ្លួនរកបាន របស់ទ្រព្យរកបានដោយ វិធីត្រឹមត្រូវតាមសមត្ថភាព ។

ការសន្ដោស គឺការត្រេកអរពេញចិត្ត នឹងរបស់ដែលខ្លួនគួរបាន គឺបានដោយអាជីវកម្មសុចរិត ត្រឹមត្រូវ តែមិនឱ្យត្រេកអរចំពោះរបស់ដែលមកមិនប្រកបដោយធម៌ ឬដោយអំពើទុច្ចរិតនោះឡើយ ។

**សំនួរទី ៥. តើការប្រកាន់ចិត្តសន្ដោសនាំមកផលប្រយោជន៍អ្វីខ្លះដល់ខ្លួនឯង គ្រួសារ និងសង្គម ?**

**ចម្លើយ** ការប្រកាន់ធម៌អធ្យាស្រ័យ និងធម៌សន្តោស គឺនាំមកនូវផលប្រយោជន៍ដល់ខ្លួនឯង គ្រួសារ និងសង្គម :

- ធ្វើឱ្យយើងត្រេកអរពេញចិត្ត នឹងសម្បត្តិខ្លួនមាន និងសម្បត្តិដែលរកបានមកដោយសុចរិត ។
- ធ្វើឱ្យយើងចេះគិតមើលថា សម្បត្តិណាដែលគួរត្រេកអរ និងសម្បត្តិណាដែលមិនគួរត្រេកអរ ។
- ធ្វើឱ្យយើងមានចិត្តស្ងប់ដោយគ្មានវិប្បដិសារី ។
- ធ្វើឱ្យយើងអាចកាត់បន្ថយសត្រូវ និងបង្កើនមិត្ត ។
- មានឈ្មោះថា ជាអ្នកធ្វើប្រយោជន៍ឱ្យដល់ខ្លួនផង និងដល់សង្គមផង ។
- អាចធ្វើឱ្យយើងមានសេចក្តីស្ងប់ក្នុងចិត្ត មិនមួម៉ៅហើយក៏អាចធ្វើឱ្យអ្នកដទៃ ដែលមានទំនាក់ទំនងជាមួយនឹងយើងក៏បានសេចក្តីសុខដែរ ។

ជាពិសេសគ្រួសារជួបនឹងសុភមង្គល សុខដុមរមនា ហើយសង្គមជាតិក៏មានការរីកចម្រើនដែរ ។

**សំនួរទី ៦** លោក ឡាហ្វុងតែន បានពោលថា "មនុស្សយើងអធ្យាស្រ័យឱ្យខ្លួនយើងគ្រប់កំហុសនាំង

ឡាយក៏ប៉ុន្តែមិនចូលចិត្តអធ្យាស្រ័យកំហុសឱ្យអ្នកដទៃឡើយ "។ ចូរពន្យល់ទស្សនៈនេះ ព្រមទាំងលើកឧទាហរណ៍ ជាក់ស្តែងដែលកើតមាននៅក្នុងសង្គម ។

**<u>ចម្លើយ</u>** ឡាហ្វុងតែនកវីបារាំង (1621-1695 នៃគ.ស) បាននិយាយថា "មនុស្សយើងអធ្យាស្រ័យឱ្យខ្លួនយើងគ្រប់កំហុសទាំងឡាយ ក៏ប៉ុន្តែមិនចូលចិត្តអធ្យាស្រ័យកំហុសឱ្យអ្នកដទៃឡើយ "។ ទស្សនៈនេះដូចគ្នានឹងកំណាព្យរបស់ខ្មែរថា "ទោសគេតូចសោកសល់ រមិលយល់ប៉ុនទាំងភ្នំ" ។ ដូចនេះបើយើងអធ្យាស្រ័យឱ្យខ្លួនយើងបាន យើងគួរតែអធ្យាស្រ័យដល់អ្នកដទៃផង ទើបជាសេចក្តីសុខ ព្រោះថាបើយើងឱ្យសុខដល់គេ គេនឹងសុខដល់យើងវិញ ។

**<u>សំនួរទី ៧.</u> តើការអធ្យាស្រ័យ និងការសន្តោសមានន័យដូចម្តេច ?**

**<u>ចម្លើយ</u>** ការអធ្យាស្រ័យ +ការសន្តោស

- **ការអធ្យាស្រ័យ** គឺការគោរពគ្នា យោគយល់ ការអត់ឱនគ្នាតាមរយៈយល់ចិត្តគ្នាទេវិញទៅមកទាំងកាយ វាចា ទាំងចិត្ត ។

- ការសន្តោស ជាធម៌ដែលមនុស្សគ្រប់រូប គ្រប់វណ្ណៈ ប្រតិបត្តិបាន ដើម្បីឈានទៅរកសុខសន្តិភាព និងការអភិវឌ្ឍដល់មនុស្សគ្រប់រូប។

➢ ការអធ្យាស្រ័យ និង ការសន្តោស គឺជាគុណធម៌ដ៏ឧត្តមដែលមនុសគ្រប់រូបត្រូវប្រកាន់យកទុកជាមាគ៌ាដ៏ប្រសើរឆ្ពោះទៅរកសេចក្តីសុខក្នុង ការរស់នៅ ។ ការអធ្យាស្រ័យ ការសន្តោស គឺការបន្ធន់ចិត្ត និងមិនប្រកាន់ទោសចំពោះខ្លួនឯងផង ចំពោះអ្នកដទៃផង ។

**<u>សំនួរទី ៨.</u> តើមនុស្សដែលចេះប្រកាន់ធម៌សន្តោសជាមនុស្សបែបណា ?**

**<u>ចម្លើយ</u>** មនុស្សដែលប្រកាន់ធម៌សន្តោស គឺមនុស្សនោះដែល :

- ចេះស្វែងរកទ្រព្យក្នុងផ្លូវល្អ
- មានការព្យាយាមខិតខំរកទ្រព្យ
- ចេះគ្រប់គ្រងរក្សាទ្រព្យ
- ចេះស្គាល់ប្រមាណក្នុងការចាយវាយ ។

**<u>សំនួរទី ៩.</u> តើអ្វីទៅជាធម៌សន្តោស ?**

**<u>ចម្លើយ</u>** ធម៌សន្តោស គឺការត្រេកអរពេញចិត្ត នឹងទ្រព្យ

ដែលជារបស់ខ្លួនមាន ទ្រព្យដែលខ្លួនរកបាននឹងទ្រព្យ ដែលគួរដល់ខ្លួន ។ ការលួចប្លន់ ឬការធ្វើចោរកម្មទាំងឡាយដែលមានសព្វថ្ងៃនេះ ក៏ព្រោះតែមានមនុស្សគ្មានធម៌សន្តោសនេះឯង ។

**សំនួរទី ១០.ខុងជឺជានរណា ? លោកបានពោលថា "កុំធ្វើ ទៅលើអ្នកដទៃនូវអំពើអ្វីដែលមិនចង់ឱ្យអ្នកដទៃធ្វើមកលើខ្លួនវិញ" ? ចូរពន្យល់ទស្សនៈនេះ ព្រមទាំងលើកឧទាហរណ៍ ជាក់ស្តែងដែលកើតមាននៅក្នុងសង្គម ?**

**ចម្លើយ** ខុងជឺជាទស្សនវិទូចិន (551-479 មុន គ.ស ) បានផ្តល់ទស្សនៈថា "កុំធ្វើ ទៅលើអ្នកដទៃនូវអំពើអ្វីដែលមិនចង់ឱ្យអ្នកដទៃធ្វើមកលើខ្លួនវិញ" ។ គាត់បានអះអាងថា "មនុស្សដែលមានគុណធម៌ពិតមានបំណងបង្កើតខ្លួនឯងដែរ " ។ ទស្សនៈរបស់ ខុងជឺ សុទ្ធតែបង្ហាញដល់មនុស្សគ្រប់រូបឱ្យមានការអត់ធ្មត់ ចេះអត់ឱនឬអាធ្យាស្រ័យឱ្យគ្នាទៅវិញទៅមក មិនឈ្លោះទាស់ទែងគ្នា ពោលគឺយកធម៌អហឹង្សាតបទៅនឹងហិង្សា ដើម្បីឱ្យសង្គមបានសេចក្តីសុខ និងមានការរីកចម្រើន ។ កាល

ណាមនុស្សម្នាក់ៗ ជ្រើសរើសយកធម៌អហិ
អធ្យាស្រ័យមកដាក់ក្នុងចិត្ត មនុស្សអាចឈ្នះ
ភ្លើនរបស់ខ្លួនបាន ពេលនោះ នឹងកើតមាន
ពោរពេញទៅដោយភាពរុងរឿង និងសុខស

**សំនួរទី ១១.តើមហាត្មៈគន្ធីជានរណា ? 
ពោលថា"ចិត្តភ្លើងពុំអាចរំលត់ដោយចិត្ត
តែគេត្រូវយកចិត្តទឹកទៅរំលត់ចិត្តភ្លើង"
ចូរពន្យល់ទស្សនៈនេះ ព្រមទាំងលើកឧទ
ជាក់ស្តែងដែលកើតមាននៅក្នុងសង្គម ខ្**

**ចម្លើយ** មហាត្មៈគន្ធីទស្សនវិទូឥណ្ឌា (1869-1
គ.ស) បានផ្តល់ យោបល់ថា "ចិត្តភ្លើងពុំអា
ដោយចិត្តភ្លើងបានទេ តែគេត្រូវយកចិត្តទឹកទ
ភ្លើង" ។ ចំណុចនេះមានន័យថា បើ មានទំនា
យើងត្រូវប្រើធម៌អហិង្សា ឬធម៌អធ្យាស្រ័យ 
គ្នា ទើបអាចបង្រ្កាកំហឹង ឬទោសៈរបស់មនុ
ដូចពាក្យស្លោកខ្មែរថា "កុំប្រើកំហឹងទល់នឹងកំ

**សំនួរទី ១២. តើពីសាឈទីត្សុទ្បាជានរណា
បានពោលថា"ការសងសឹកជាមួយ និងមនុស**

បំពានមកលើរូបយើង គឺយើងដាក់ខ្លួនយើងឱ្យស្មើនឹងសត្រូវ" ។ ចូរពន្យល់ទស្សនៈនេះ ព្រមទាំងលើកឧទាហរណ៍ ជាក់ស្តែងដែលកើតមាននៅក្នុងសង្គម ។

**<u>ចម្លើយ</u> ពីសាណូនីកូឡា**ជាងចម្លាក់អ៊ីតាលី បានពោលថា "ការសងសឹកជាមួយ និងមនុស្សដែលបំពានមកលើរូបយើង គឺយើងដាក់ខ្លួន យើងអោយស្មើនឹងសត្រូវ" ។ បើយើងអធ្យាស្រ័យឱ្យគេ គឺយើងលើស្ទួយខ្លួនយើងឱ្យខ្ពស់ជាងគេ។ ការអធ្យាស្រ័យចំពោះខ្លួន ឯង ហើយតឹងតែងចំពោះអ្នកដទៃ គឺជាកំហុសតែមួយដូចគ្នា ។ ចំណុចនេះមានន័យថា រវាងការសងសឹក និងការអធ្យាស្រ័យ យើងគួរជ្រើសរើសយកការអធ្យាស្រ័យប្រសើរជាង ។


ព្រះពោធិសត្វ លោកេស្វរៈ


អវលោកេស្វរៈ


ព្រះពោធិសត្វ ប្រជ្ញាបារមិតា

# មេរៀនទី៦ : សុចរិតធម៌

## I. សំនួរត្រិះរិះ

**សំនួរទី ១. ដូចម្តេចហៅថា សុចរិតធម៌ ?**

**ចម្លើយ** សុចរិតធម៌មានន័យថា ការប្រព្រឹត្តល្អ ការប្រព្រឹត្តដោយស្មោះត្រង់ ការប្រព្រឹត្តដោយបរិសុទ្ធ និងត្រឹមត្រូវ។ ឧទាហរណ៍ មុខរបរសុចរិតជាមុខរបរត្រឹមត្រូវ បរិសុទ្ធ ស្របតាមច្បាប់ សីលធម៌ និងទំនៀមទម្លាប់ប្រពៃណីច្បាប់របស់សង្គម ។

សុចរិតធម៌ សំដៅលើការប្រកាន់ខ្ជាប់នូវការប្រព្រឹត្តត្រឹមត្រូវ ឬ ការប្រកបមុខរបរចិញ្ចឹមជីវិតដោយបរិសុទ្ធតាមគន្លងធម៌ ស្រប តាមច្បាប់របស់សង្គមហើយមិនធ្វើឱ្យអ្នកដទៃរងការឈឺចាប់ ការខូចខាតផលប្រយោជន៍ ពេលវេលា ឬទទួលរងគ្រោះថ្នាក់ដោយ សារតែទង្វើ និងមុខរបររបស់ខ្លួន ។

**សំនួរទី ២. តើមុខរបរសុចរិត និងមុខរបរទុច្ចរិតមានលក្ខណៈខុសគ្នាដូចម្តេចខ្លះ ? ចូរលើកឧទាហរណ៍បញ្ជាក់ ?**

ឃ នៅក្នុងជីវិតប្រចាំថ្ងៃ មនុស្សម្នាក់ៗមានសកម្ម
ផ្សេងគ្នា ដើម្បីប្រកបរបរចិញ្ចឹមជីវិតទៅតាមចំណង់
លចិត្ត សមត្ថភាព មុខរបរស្របច្បាប់និងសុចរិត
ត្រូវ តែទន្ទឹមនឹងនោះក៏មានមនុស្សមួយចំនួនមិនមាន
ច្បាស់លាស់ ឬមានមុខរបរមិនសុចរិត ឬជាមុខ
នត្រឹមត្រូវ ដូជារកស៊ីល្បែងភ្នាល់ ជួញដូរមនុស្ស
រគ្រឿងញៀនដែលជាអំពើរទុច្ចរិតផ្ទុយនឹងច្បាប់
។

**៣. តើសកម្មភាពមនុស្សមានលក្ខណៈដូច
ទើបគេអាចចាត់ទុកថា ជាសកម្មភាពសុចរិត
ុស្សសុចរិត ?**

ឃ សកម្មភាពមនុស្សដែលចាត់ទុកជាសកម្មភាព
លុះត្រាតែសកម្មភាពដែលមនុស្សប្រព្រឹត្តចេញ
ទ្ធតែអំពើត្រឹមត្រូវ មិនប្រព្រឹត្តអំពើអាក្រក់ទាំងពួង
ោះត្រង់ជានិច្ច ។

**៤. តើមនុស្សដែលប្រកាន់ខ្ជាប់សុចរិតធម៌
បបានផលប្រយោជន៍អ្វីខ្លះ ?**

✍ <u>ចម្លើយ</u> មនុស្សដែលប្រកាន់ខ្ជាប់សុចរិតធម៌ នឹងទទួលបានផលប្រយោជន៍ដូចជា ៖

- រស់នៅមានសុវត្ថិភាព សុភមង្គល រីកចម្រើន និងថ្លៃថ្នូរ
- គ្មានការត្អូញត្អែរពីអ្នកដទៃ
- មានកេរ្តិ៍ឈ្មោះល្អថាជាមនុស្សសុចរិត មានមិត្តភក្តិមនុស្សនៅជុំវិញខ្លួនស្រឡាញ់រាប់អានច្រើន
- គ្មានការព្យាបាទ គុំគួនពីអ្នកដទៃ
- មានសុភមង្គលក្នុងគ្រួសារ សហគមន៍និងសង្គមមានសន្តិភាព
- តែងបានទទួលត្រឡប់មកវិញអំពើប្រកបដោយសុចរិតធម៌ ។ល។

☛ <u>**សំនួរទី ៥.**</u> **គេថាព្រេងវាសនា ឬជោគជ័យរបស់មនុស្សមិនមែនបានមកពីការប្រទានរបស់ទេវតានោះទេ តែវាបានមកពីការធ្វើការងារ ប្រកបដោយសុចរិតធម៌ ? ចូរបកស្រាយ ។**

✍ <u>ចម្លើយ</u> ព្រោះថាមនុស្សម្នាក់ៗ កើតមកមិនមែនចាំតែទេវតាប្រទានទូវសំណាង ឬ ភាពជោគជ័យមកដល់ខ្លួននោះទេ មនុស្សត្រូវ ប្រកាន់សុចរិតធម៌ ១០យ៉ាងដើម្បី

ក្លាយជាមនុស្សជោគជ័យជាមិនខានដូចនេះ ទើបមានពាក្យមួយបានពោលថាប្រសិនបើ គ្មានសមត្ថភាពនេះទេក៏គ្មានសំណាងដែរ ។

**សំនួរទី ៦. តើព្រះពុទ្ធសាសនាបានអប់រំមនុស្សឱ្យប្រកាន់សុចរិតធម៌ដូចម្ដេចខ្លះ ?**

**ចម្លើយ** ព្រះពុទ្ធបានមានពុទ្ធដីកាថា "មនុស្សទាំងឡាយគួរកុំប្រព្រឹត្តអំពើណាដែលមិនគប្បីដល់អ្នកដទៃឱ្យសោះ បើយើងមិនចង់ឱ្យគេប្រ ព្រឹត្តអំពើនោះមកលើខ្លួនយើងវិញ" ។ មនុស្សទាំងអស់ត្រូវតែប្រព្រឹត្តអំពើល្អ អំពើសុចរិត ។ អំពើសុចរិតធម៌ ១០ យ៉ាង ឬ កុសលកម្មបថ ១០ប្រការ ។

\+ កាយសុចរិតមានបីប្រភេទ :

- មិនកាប់សម្លាប់ជីវិតមនុស្ស និងសត្វ (បាណាតិបាតា វេរមណី)
- មិនលួចទ្រព្យសម្បត្តិអ្នកដទៃ (អទិន្នាទានា វេរមណី)
- មិនសហាយស្មន់ជាមួយប្រពន្ធ ប្ដីនិងកូនគេ (កាមេសុមិចារាក វេរមណី) ។

\+ វាចាសុចរិតមានបួនប្រការ

- មិនភូតកុហកឆបោកអ្នកដទៃ (មុសាវាទា វេរមណី)
- មិនញុះញង់បំបែកបំបាក់អ្នកដទៃ (បិសុណាវាចាយ វេរមណី)
- មិនពោលពាក្យទ្រគោះបោះបោក ឬជេរប្រទេចផ្តាសាអ្នកដទៃ (ផរុសាយ វាចាយ វេរមណី)
- មិនពោលពាក្យរាយមាយឥតប្រយោជន៍ (សម្ផប្បលាបា វេរមណី) ។

\+ មនោសុចរិតមានបីប្រការ

- មិនមានចិត្តសម្លឹងរំពៃចង់បានទ្រព្យសម្បត្តិអ្នកដទៃ ( អភិជ្ឈា )
- មិនមានចិត្តគំនុំគុំកួន ឬមិនមានគំនិតព្យាបាទអ្នកដទៃ ( អព្យាបាទោ )
- មិនមានគំនិតយល់ឃើញត្រូវពិតតាមច្បាប់របស់សង្គមសីលធម៌ (សម្មាទិដ្ឋិ )

អ្នកដែលបានប្រកាន់ខ្ជាប់អំពើសុចរិតធម៌ ១០ យ៉ាងនេះនឹងបានសេចក្តីសុខ និង សេចក្តីសុខចម្រើន ។

**<u>សំនួរទី ៧.</u> ចូរសិក្សាប្រៀបធៀបឧស្សាហ៍នៈកុសលកម្មបថ និងអកុសលកម្មបថក្នុងព្រះពុទ្ធសាសនា ?**

**ចម្លើយ** ប្រៀបធៀបទស្សនៈកុសលកម្មបថ និងអកុសលកម្មបថក្នុងព្រះពុទ្ធសាសនា ។

+ **ទស្សនៈកុសលកម្មបថ** ប្រៀនប្រដៅឱ្យមនុស្សប្រព្រឹត្តនូវអំពើល្អ ១០ យ៉ាង គឺដោយកាយ វាចា ចិត្ត គឺ មានកាយសុចរិត ៣ វចីសុចរតិ ៤ នឹងមនោសុចរិត ៣ ។

+ **ទស្សនៈអកុសលកម្មបថ** បានប្រៀនប្រដៅ និងតម្រង់ទិសឱ្យមនុស្សដែលមិនបានប្រព្រឹត្តនូវអំពើល្អ ១០ យ៉ាង គឺដោយ កាយ វាចា ចិត្ត គឺមានកាយ សុចរិត ៣ វចីសុចរិត ៤ នឹងមនោសុចរិត ៣ ឱ្យវិលមករកផ្លូវល្អតែប៉ុណ្ណោះ

**សំនួរទី ៨.** **តើមនុស្សដែលប្រកាន់ខ្ជាប់សុចរិតធម៌ជាបុគ្គលដូចម្តេច ?**

**ចម្លើយ** មនុស្សដែលប្រកាន់យកសុចរិតធម៌ គឺចូលចិត្តប្រព្រឹត្ត ឬធ្វើអ្វីៗ មិនវៀចវេរ មិនលំអៀង និងដោយស្មោះត្រង់ ។

**សំនួរទី ៩.** **ដើម្បីពង្រីកមាគ៌ាសន្តិភាព និងសុភមង្គលជាសកលឱ្យកាន់តែប្រសើរ តើព្រះពុទ្ធទ្រង់បានអប់រំ**

មនុស្សដូចម្ដេចខ្លះ ?

**ចម្លើយ** ព្រះសម្មាសម្ពុទ្ធទ្រង់បានអប់រំទូន្មានដល់មនុស្ស ទាំងអស់ឱ្យប្រកាន់ខ្ជាប់កុសលកម្មបថ ១០ប្រការ ឬអំពើ សុចរិតធម៌ ១០យ៉ាង គឺ ការប្រព្រឹត្តល្អ ១០ យ៉ាង របស់ ព្រះពុទ្ធសាសនា ដោយកាយ វាចា ចិត្ត គឺមានកាយ សុចរិត ៣ វចីសុចរតិ ៤ និងមនោសុចរិត ៣ ។

**សំនួរទី ១០.** ព្រះសម្មាសម្ពុទ្ធទ្រង់បានទូន្មានថា មនុស្ស គ្រប់រូបគប្បីចិញ្ចឹមជីវិតឱ្យបានត្រឹមត្រូវ មានអាជីព ត្រឹមត្រូវ ឬ មុខរបរ សុចរិត ហើយចៀរចាកការ ចិញ្ចឹមជីវិតខុស មានជំនួញទាំង ៥ប្រការ តើជំនួញ នោះមានអ្វីខ្លះ ?

**ចម្លើយ** គឺជំនួញសាស្ត្រាវុធ ជំនួញមនុស្ស ជំនួញសត្វដែល គេពិឃាតយកសាច់ ជំនួញទឹកស្រវឹង និងជំនួញថ្នាំពុល។ ការចិញ្ចឹមជីវិតដោយបរិសុទ្ធដោយបរិសុទ្ធប្រកបដោយ សីល គឺអាជីវកម្មត្រឹមត្រូវដែលមិនឱ្យអ្នកដទៃក្ដៅក្រហាយ ដោយសារមុខរបររបស់ខ្លួន ឈ្មោះថាមុខរបរសុចរិត ។

***** [illegible] *****

# មេរៀនទី១០ : តម្លាភាព

## I. សំនួរត្រិះរិះ

☛ <u>សំនួរទី ១.</u> ដូចម្ដេចហៅថា តម្លាភាព ? ចូររកឧទាហរណ៍បញ្ជាក់ ?

✍ <u>ចម្លើយ</u> ដែលហៅថា **តម្លាភាព** ជាការបើកចំហ ការស្មោះត្រង់គ្មានការលាក់លៀមដោយបង្កលក្ខណៈឱ្យមានការចូលរួមដ៏សុទ្ធចិត្ត និងរីករាយក្នុងគ្រប់ទិដ្ឋភាពជីវភាពសង្គម នយោបាយ សេដ្ឋកិច្ច និងវប្បធម៌ ។

☛ <u>សំនួរទី ២.</u> ចូរបង្ហាញពីសកម្មភាពផ្សេងៗដែលប្រកបដោយតម្លាភាព ?

✍ <u>ចម្លើយ</u> សកម្មភាពផ្សេងៗដែលប្រកបដោយតម្លាភាព គឺ :

- ការនិយាយពិត និយាយត្រង់
- ការគោរពសិទ្ធិ
- ការមិនរើសអើង មិននិយមបក្សពួក
- មិនបោកបញ្ឆោត ប្រើល្បិចកល

- មិនមូលបង្កាច់ លាក់លៀម និងច្រណែនឈ្នានីសមិន ឃើញតែប្រយោជន៍ផ្ទាល់ខ្លួន និងការទទួលស្គាល់ការ ពិតនៅក្នុងគ្រប់សកម្មភាពទាំងអស់ពិសេសការស្គាល់ខ្លួន ឯងយ៉ាងច្បាស់លាស់ពីអ្វីដែលខ្លួនមាន អ្វីដែលជាចំណុច ខ្លាំង និងចំណុចខ្សោយ ។ ជាទូទៅតម្លាភាពអាចលូត លាស់បាន តែនៅក្នុងសង្គមដែលមានការគោរពសិទ្ធិ មនុស្សមានការ ដឹកនាំសង្គមតាមបែបលទ្ធិប្រជាធិប តេយ្យ មានយុត្តិធម៌ និងប្រកបដោយសីលធម៌ខ្ពស់ ។

**សំនួរទី ៣. តើការងារប្រកបដោយតម្លាភាពមាន ប្រយោជន៍ដូចម្តេចខ្លះ ?**

**ចម្លើយ** ការងារប្រកបដោយតម្លាភាពមានប្រយោជន៍ ដូចជា :

- មានការជឿទុកចិត្តគ្នា
- មានមនសិការជាតិ ហ៊ានលាតត្រដាងការពិត
- មានទំនាក់ទំនងល្អ ការគោរពសិទ្ធិគ្នា
- មានការអភិវឌ្ឍន៍ឆាប់រហ័ស និងមានសន្តិភាព

- មានការសហការគ្នាបានល្អ
- មិនមានបក្សពួកនិយម ឬញាតិនិយម
- មានស្មារតីសាមគ្គីភាព
- មិនបំពានលើសិទ្ធិ និងទ្រព្យអ្នកដទៃ
- មានសេចក្តីក្លាហានក្នុងការទទួលខុសត្រូវ
- មិនមានគំនិតលាក់លៀម
- មានការយកចិត្តទុកដាក់ចំពោះអ្នកដទៃ ក៏ដូចជាចំពោះខ្លួន ។

**សំនួរទី ៤.** នៅក្នុងសកម្មភាពជីវភាព តើប្អូនធ្លាប់ជួបប្រទះការងារប្រកបដោយតម្លាភាពអ្វីខ្លះ ? ចូររៀបរាប់ ។

**ចម្លើយ** ការងារប្រកបដោយតម្លាភាពដែលខ្ញុំធ្លាប់ជួបប្រទះនៅក្នុងសហគមន៍ មានការជួសជុលផ្លូវលំមួយខ្សែ ដោយពេលនោះ សមាជិកក្រុមនីមួយៗ មានឆន្ទៈមុះមុត មានការជឿជាក់ក្នុងការបំពេញការងារ និងជាពិសេសគ្មានការរើសអើងរវាងអ្នកមាន និងអ្នកក្រ ... ។

<u>**សំនួរទី ៥.**</u> **តើប្អូនត្រូវធ្វើដូចម្តេច ដើម្បីឱ្យការងារដែលប្អូនបានចូលរួម ប្រកបដោយតម្លាភាព ?**

<u>**ចម្លើយ**</u> ដើម្បីឱ្យការងារដែលនោះមានតម្លាភាព ខ្ញុំត្រូវមានឆន្ទៈក្នុងការអប់រំចិត្ត ការកសាងចិត្តឱ្យមានភាពស្មោះត្រង់មិនលំអៀង មិនរើសអើង ... ។

<u>**សំនួរទី ៦.**</u> **ចូរសិក្សាស្រាវជ្រាវ លើប្រធានបទមួយដែលបានលើកឡើងថា " សង្គមដែលគ្មានតម្លាភាព និងអភិបាលកិច្ចល្អ នោះនឹងធ្វើឱ្យសង្គមមិនអាចឈានទៅរកការអភិវឌ្ឍបានឡើយ " ។**

<u>**ចម្លើយ**</u> តាមការស្រាវជ្រាវបានឱ្យដឹងថានៅពេលសង្គមគ្មានតម្លាភាព វាធ្វើឱ្យមានភាពមិនស្មោះត្រង់ ការស៊ីសំណូក ពុករលួយនៅក្នុងសង្គម ដែលជាហេតុធ្វើឱ្យមានការបាត់បង់ថវិកាជាតិ វាជាហេតុផលដែលធ្វើឱ្យសង្គមគ្មានការអភិវឌ្ឍ ។ ជាពិសេសធ្វើឱ្យអភិបាលកិច្ចក្នុងសង្គមមិនអាចប្រព្រឹត្តទៅបានល្អ និង មិនអាចឈានទៅរកការអភិវឌ្ឍបានឡើយ ។

# មេរៀនទី១១ : សាមគ្គីធម៌

## I. សំនួរត្រិះរិះ

☛ **សំនួរទី ១. តើពាក្យសាមគ្គី និងសាមគ្គីធម៌មានន័យដូចម្ដេច ?**

✍ ចម្លើយ - ពាក្យ**សាមគ្គី** មានន័យថា គឺជាតម្លៃមួយដែលតម្រូវឱ្យបុគ្គលម្នាក់ៗនៅក្នុងគ្រួសារ ក្រុម សហគមន៍ ឬសង្គមចេះរួបរួមគ្នាបំពេញកិច្ចការ គ្រប់បែបយ៉ាងដោយការព្យាយាម ស្មោះត្រង់ យោគយល់ និង អធ្យាស្រ័យគ្នាទៅវិញទៅមក ។ សាមគ្គី គឺជាការព្រមព្រៀងគ្នា ឬការស្រុះស្រួលគ្នា ។

- **សាមគ្គីធម៌** មានន័យថា ជាច្បាប់ ឬលក្ខខណ្ឌសម្រាប់ប្រតិបត្តិឱ្យមានការព្រមព្រៀងគ្នា ឬ សាមគ្គីគ្នា ។

☛ **សំនួរទី ២. "សាមគ្គីជាកម្លាំង និងជាចង្កឹះមួយបាច់គេកាច់មិនបាក់ " តើពំនោលនេះមានន័យដូចម្ដេចខ្លះ ?**

**ចម្លើយ** ពន្យល់ពាក្យស្លោក "សាមគ្គីជាកម្លាំង និងជាបង្គោលមួយចាក់ គេកាច់មិនបាក់" ។

ជាការពិតណាស់ការប្រកបរបរអ្វីមួយលុះត្រាតែមានការសហការគ្នា រួបរួមគ្នាជាធ្លុងមួយទើបការងារអ្វីៗបានសម្រេចជោគជ័យដោយរលូនប្រៀបបានជាកម្លាំងមហាសាល មិនមានសត្រូវណាមើលងាយឡើយ និងទទួលបានកេរ្តិ៍ឈ្មោះ និងកិត្តិយសល្អប្រពៃ។ ប៉ុន្តែបើគ្មានការរួបរួមគ្នានោះទេ ការងារអ្វីក៏ដោយ ក៏មិនអាចទទួលបានជោគជ័យដែរ ។ ជាក់ស្តែងនៅពេលក្រុមមួយគ្មានសាមគ្គីភាពគ្នានោះ ក្រុមនោះមិនអាចទទួលបានជោគជ័យឡើយ។

**សំណួរទី ៣.** តើអ្នកត្រូវធ្វើដូចម្តេចខ្លះ ដើម្បីឱ្យចំណងសាមគ្គីមានភាពរឹងមាំ និងយូរអង្វែង ?

**ចម្លើយ** ដើម្បីឱ្យចំណងសាមគ្គីមានភាពរឹងមាំ និងយូរអង្វែង យើងត្រូវប្រកាន់វិធី ៦ យ៉ាង ។

១. ការជឿ និងការអត់ឱន

២. ការអភ័យទោស និងការស្មោះត្រង់

៣. ការមិនប្រកាន់ ឬ មិនរើសអើង

៤. ការមិនច្រណែនឈ្នានីស

៥. ការស្មោះត្រង់ទៅវិញទៅមក

៦. ការពិចារណារកហេតុផលតាមផ្លូវល្អ ។

**<u>សំនួរទី ៤.</u> ចូរបង្ហាញអំពីសមិទ្ធផលដែលកើតឡើងពីការសាមគ្គីគ្នា ?**

<u>**ចម្លើយ**</u> សមិទ្ធផលដែលបានកើតឡើងពីការសាមគ្គីគ្នាគឺ :

- ការរីកចម្រើនឆាប់រហ័ស ទទួលបានជោគជ័យដោយងាយ និងការចំណេញពេលវេលា
- ការពារផលប្រយោជន៍សមិទ្ធផល បានឋិតថេរគង់វង្ស
- ការបង្កើតបានសមិទ្ធផលកាន់តែច្រើនឡើងថែមទៀត
- បុគ្គលម្នាក់ៗនឹងទទួលបានផលប្រយោជន៍គ្រប់បែបយ៉ាង
- គ្រួសារ សហគមន៍ សង្គម-មានកម្លាំងកាន់តែរឹងមាំ មានកិត្តិយស កេរ្តិ៍ឈ្មោះ និងមិនមានសត្រូវណាម្នាក់ងាយឡើយ
- បុគ្គលម្នាក់ៗបានបំពេញកិច្ចការដែលត្រូវធ្វើតាមតួនាទីរៀងៗខ្លួន ដោយមិនមើលបំណាំគ្នា
- ការឯកភាពគ្នាជាធ្លុងមួយ គ្មានការប្រឆាំង ឬ ជំទាស់ដែលនាំឱ្យសង្គមបាក់បែក ។

**សំនួរទី ៥. ហេតុអ្វីបានជាមនុស្សម្នាក់ៗត្រូវការសាមគ្គី ? តើការមានសាមគ្គីនឹងផ្តល់ផលប្រយោជន៍អ្វីខ្លះដល់សង្គម ?**

**ចម្លើយ** បានជាមនុស្សម្នាក់ៗត្រូវការសាមគ្គី ព្រោះមនុស្សម្នាក់ៗតែងមានបំណងប្រាថ្នាចង់បានសេចក្តីសុខ និងការរីកចម្រើន ។ ដើម្បីសម្រេចបំណងប្រាថ្នានេះ មនុស្សគ្រប់រូបតែងរកមធ្យោបាយ ការសម្រេចចិត្ត ក៏បំពេញភារកិច្ចផ្សេងៗពីគ្នា ។ ប៉ុន្តែកិច្ចការធំៗមួយចំនួនគេមិនអាចបំពេញតែម្នាក់ឯង ឬមនុស្សពីរ បីនាក់បានលុះត្រាតែមានការចូលរួម ឬ ការរួមសាមគ្គីទាំងកាយទាំងចិត្តរបស់មនុស្សភាគច្រើន ទើបអាចសម្រេចចិត្តកិច្ចការនោះដោយជោគជ័យ ព្រោះសាមគ្គីជាកត្តាកំណើជ័យជំនះគ្រប់បែបយ៉ាង ។

ការមានសាមគ្គីនឹងផ្តល់ផលប្រយោជន៍ដល់សង្គមជាតិខ្មែរ គឺ :

- មានការរីកចម្រើនគ្រប់ផ្នែក គ្រប់វិស័យ រីកចម្រើនយ៉ាងឆាប់រហ័ស
- គ្មានសត្រូវមាក់ងាយ គ្មានអ្នកណាអាចរំលោភលើបូរណ

ភាពបាន

- ឯកភាពជាធ្លុងមួយ គ្មានការប្រឆាំង និងជំទាស់
- មិនមានការមើលបំណាំគ្នា ស្រុះស្រួលគ្នាធ្វើទាំងព្រម
- ការពារផលប្រយោជន៍ដែលបានមកពីការសាមគ្គី
- បំបាត់នូវភាពក្រីក្រក្នុងប្រទេស ។

**<u>សំនួរទី ៦.</u> ចូរពន្យល់ពីពាក្យស្លោកមួយថា "សាមគ្គីរស់ បែកបាក់សាមគ្គីស្លាប់ " ។**

**<u>ចម្លើយ</u>** ពន្យល់ពាក្យស្លោក "សាមគ្គីរស់ បែកបាក់សាមគ្គី

• ស្លាប់ "

ពាក្យសាមគ្គី បានដល់ភាពនៃការស្រុះស្រួលគ្នា មូលមតិគ្នាជាធ្លុងមួយ ទាំងព្រម ។ រីឯពាក្យ រស់ មានន័យថា ការមានដង្ហើម មានជីវិត ឬភាពនៅស្ថិតស្ថេរយូរអង្វែង។

សរុបមក សាមគ្គីរស់ មានន័យថា ការធ្វើអ្វីមួយដោយមានការស្រុះស្រួលគ្នាជាធ្លុងមួយ ដើម្បីទៅដល់ការរួម សម្រេចបាននូវគោលជ័យ នាំមកនូវការ[illegible] មានជីវិតយូរអង្វែង ។ ផ្ទុយទៅវិញ ប្រសិនបើគ្មានការសាមគ្គីនោះទេ នោះកិច្ចការអ្វីៗជួបតែការបរាជ័យ និងនាំមកនូវសេចក្តីវិនាសអន្តរាយ បែកបាក់ សត្រូវមើល

ងាយ ។

ជារួមមកក្នុងនាមជាមនុស្សគ្រប់រូបយ៉េងត្រូវរស់នៅដោយមានការសាមគ្គីភាពគ្នា ស្រុះស្រួលគ្នា មិនត្រូវបង្កជម្លោះ ឬ ការបែកបាក់គ្នា នាំឱ្យសត្រូវមើលងាយ នោះនឹងឈានដល់សេចក្តីវិនាសអន្តរាយ ។

**<u>សំនួរទី ៧.</u> តើសាមគ្គីភាព ជាអ្វី ? សាមគ្គីរស់ ជាអ្វី?**

**<u>ចម្លើយ</u>** . **សាមគ្គីភាព** គឺជាបែបបទ ឬរបៀបនៃការព្រមព្រៀងគ្នា ។

. **សាមគ្គីរស់** គឺជារសនៃសាមគ្គីមានន័យថាការព្រមព្រៀងគ្នាដោយការពេញចិត្ត និងការស្រឡាញ់រាប់អានគ្នាទៅវិញទៅមក ។



## ? សំណួរបញ្ចប់ជំពូក ១

*គូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយដែលត្រឹមត្រូវ*

ារកើតមានសេចក្តី លោភៈ ទោសៈ មោហៈ នឹងនាំទៅ

កសេចក្តីទុក្ខសេចក្តីវិនាស ។

]ក. មហាម៉ត □ខ. ដេម៉ូគ្រីត ☑គ. ព្រះពុទ្ធសមណគោតម

]ឃ. សូក្រាត ។

ាកប្បកិរិយារបស់បុគ្គលម្នាក់ដែលមិនទទួលឥទ្ធិពល ឬ

ទបញ្ជាពីនរណាម្នាក់ ហើយមានសិទ្ធិសេរីភាពក្នុងការ

រម្រេចធ្វើអ្វីមួយ គេហៅថាមនុស្សមាន :

]ក. សេរីភាព □ខ. តម្លាភាព ☑គ. ឯករាជ្យភាព

]ឃ. សច្ចភាព ។

ៅពេលដែលនរណាម្នាក់មិនបានធ្វើអ្វីមួយតាមការសន្យា

របស់ខ្លួន ខ្ញុំនឹង :

]ក. បង្ហាញការមិនសប្បាយចិត្ត ☑ខ. សួររកមូលហេតុ

]គ. យល់ព្រម[redacted]យគ្មាននិយាយអ្វី

]ឃ. មានការអធ្យាស្រ័យ ។

**ផ្គូផ្គងពាក្យក្នុងប្រអប់ ផ្នែក ក ទៅនឹងអត្ថន័យផ្នែក ខ ឱ្យបានត្រឹមត្រូវ**

| ក | ខ | ចម្លើយ |
|---|---|---|
| ១. មានចិត្តស្រឡាញ់រាប់អាន ចង់ឱ្យគេបានសុខ | ក. ឧបេក្ខា | ១.> ឃ |
| ២. មានចិត្តអាណិតអាសូរ ដោយគ្មានប្រណែនឈ្នានីស | ខ. មុទិតា | ២.> ច |
| ៣. អបអរសាទរចំពោះសេចក្តីសុខរបស់អ្នកដទៃ | គ. មុសា | ៣.> ខ |
| ៤. ប្រកាន់ចិត្តអព្យាក្រឹតឥតលំអៀង | ឃ. មេត្តា | ៤.> ក |
| | ង. កតវេទិតា | |
| | ច. ករុណា | |

III. បំពេញល្បះចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

១. ការចេះដឹងគុណ និងទទួលស្គាល់គុណបំណាច់ដ៏ធំធេងដល់មុព្វការីជនមាន មាតាបិតាជាដើមដែលបានធ្វើចំពោះបុត្រធីតា គេហៅថា..***កតញ្ញូតាធម៌***..។

២. ការបង្ហាញភាពស្មោះត្រង់ គ្មានការលាក់លៀម ហើយហ៊ាននិយាយជាចំហពីកំហុសរបស់ខ្លួនគឺជា..***តម្លាភាព***..។

IV. គេថាតម្លៃរបស់មនុស្សមិនមែនស្ថិតនៅលើការអួតអាងទេ គឺស្ថិតនៅលើសមត្ថភាពការងារ ។ ចូរពន្យល់ ។

✍ <u>**ចម្លើយ**</u> ពំនោលនេះមានន័យថា ការប្រតិបត្តិការងាររបស់មនុស្សគ្រប់រូបត្រូវពឹងផ្អែកលើសមត្ថភាពជាធំ មិនមែន ការអួតអាងនោះទេ ។ ប្រសិនបើមនុស្សគ្មាន

សមត្ថភាពបានពិសោធន៍ឧបនិស្ស័យជំនាញផ្ទាល់ក្នុងការងារនោះទេ មនុស្សមិនអាចសម្រេចការងារនោះឡើយ ការប្រតិបត្តិការងារនិមួយៗមិនមែនងាយត្រឹមតែ និយាយថាអាចធ្វើបានក៏អាចធ្វើបាននោះទេសំខាន់គឺស្ថិតនៅលើសមត្ថភាពជាក់ស្តែង ។

V. ចូរឡើងរាប់និពីរវត្ថុពីរដែលមានតម្លៃជាងគេបំផុតនៅក្នុងជីវិតរបស់អ្នក ? ចូរបញ្ជាក់ពីមូលហេតុ ?

**ចម្លើយ** វត្ថុពីរដែលមានតម្លៃជាងគេបំផុតនៅក្នុងជីវិតរបស់ខ្ញុំ គឺ :

- សុខភាព : ព្រោះសុខភាពជាកត្តាចំបងបំផុតនៅក្នុងជីវិតជីវិតមនុស្ស ប្រសិនបើមានសុខភាពមិនល្អនោះ យើងមិនអាចធ្វើអ្វីបានទេ ទោះមានប្រាក់ ទ្រព្យសម្បត្តិរបៀបយ៉ាងណាក៏ដោយ ហើយនឹងត្រូវវិនាសដោយសារតែខ្លួនមានជម្ងឺ ។ ចុងបញ្ចប់ធ្វើឱ្យខ្លួនមិនអាចមើលអ្វីៗនៅខាងមុខបានច្បាស់លាស់ មិនអាចសម្រេចបំណង ឬ គោលដៅនៃជីវិតរបស់ខ្លួនបាន និងអាចឈានដល់សេចក្ដីស្លាប់បាត់បង់ជីវិត ។

ដូច្នេះ យើងគ្រប់គ្នាជាមនុស្សត្រូវធ្វើយ៉ាងណាកុំឱ្យខ្លួនយើងមានជម្ងឺ ព្រោះវាជាផលខាតនៃជីវិតយើងគ្រប់ៗគ្នា ។

- កិត្តិយស : មនុស្សទាំងអស់ត្រូវការកិត្តិយសបន្ទាប់ពីមានសុខភាពល្អ រាងកាយមាំមួន និងមានទ្រព្យសម្បត្តិហើយក្តី ។ មនុស្សប្រសិនបើរស់គ្មានកិត្តិយសនោះ មិនស្មើនឹងសត្វផង ។

ដូច្នេះ ត្រូវធ្វើយ៉ាងណាដើម្បីឱ្យមានកិត្តិយស កេរ្តិ៍ឈ្មោះល្អប្រពៃ ព្រោះប្រសិនបើកិត្តិយសយើងល្អ ទោះយើងស្លាប់ទៅហើយក៏ដោយ ក៏នៅតែមានកិត្តិយស កេរ្តិ៍ឈ្មោះ គេនឹករលឹកហៅរកហាក់បីដូចជានៅរស់ដដែល។

✡ ជំពូក II : វប្បធម៌សន្តិភាព ✡

# មេរៀនទី១ : ប្រវត្តិកំណើតសាសនា

## I. ធំរង់មិន (Q.C.M)

### *ក. ចូរគូសសញ្ញា✓ ក្នុងប្រអប់ខាងមុខចម្លើយដែលត្រឹមត្រូវមានតែមួយគត់ :*

១. ក្នុងចំណោមសាសនាទាំងឡាយខាងក្រោម តើសាសនាណាមួយដែលមានកំណើតមុនគេលើពិភពលោក ?

☑ ព្រាហ្មណ៍សាសនា ☐ ពុទ្ធសាសនា

☐ គ្រិស្តសាសនា ☐ អ៊ីស្លាមសាសនា

២. ពុទ្ធសាសនាហីនយាន មានឥទ្ធិពលតែក្នុង :

☐ ប្រទេសចិន ☐ ប្រទេសជប៉ុន

☑ ប្រទេសកម្ពុជា ☐ ប្រទេសវៀតណាម

៣. គ្រិស្តសាសនា ផ្អែកលើគម្ពីរ :

☑ ប៊ីប ☐ គូអាន ☐ ព្រះត្រៃបិដក ☐ ត្រៃវេទ

៤. ឥស្លាមសាសនា ផ្អែកលើគម្ពីរ :

☐ ប៊ីប ☑ គូអាន ☐ ព្រះត្រៃបិដក ☐ ត្រៃវេទ

៥. ព្រះរតនត្រ័យ រួមមាន :

☐ព្រះព្រហ្ម ព្រះវិស្ណុ ព្រះសិវៈ

☑ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ

☐ព្រះវិន័យ ព្រះសូត្រ ព្រះអភិធម្ម

៦. ឥស្លាមសាសនា មានដើមកំណើតនៅប្រទេស :

☐ឥណ្ឌូនេស៊ី ☑អារាប៊ីសាអូឌីត ☐ស៊ីរី

៧. ព្រះពុទ្ធសាសនា មានមូលដ្ឋានផ្អែកលើគម្ពីរ :

☐ត្រៃវេទ ☑ព្រះត្រៃបិដក ☐ប៊ីប ☐គូអាន

៨. ព្រះពុទ្ធសាសនា មានកំនើតតាំងពី :

☐ស.វទី២មុនគ.ស ☑ស.វ ទី៦ មុនគ.ស

៩. តើពិធីបុណ្យណាមួយ ដែលរំលឹកដល់ការប្រសូត្រ ការត្រាស់ដឹង និងការចូលបរិនិព្វានរបស់ព្រះពុទ្ធ ?

☑ពិសាខបូជា ☐ពុទ្ធបូជា ☐មាឃបូជា

១០. តើពិធីបុណ្យកឋិនទាន មានរយៈពេលប៉ុន្មានថ្ងៃ ?

☐3 ថ្ងៃ ☐15 ថ្ងៃ ☑29 ថ្ងៃ ☐30 ថ្ងៃ

១១. ពុទ្ធសករាជ(ព.ស) កើតមុនគ្រឹស្តសករាជចំនួន :

☐345ឆ្នាំ ☐435ឆ្នាំ ☑543ឆ្នាំ ☐352ឆ្នាំ

១២. គ្រឹស្តសករាជ(គ.ស) កើតក្រោយពុទ្ធសករាជ

(ព.ស) ចំនួន :

☐ 345 ឆ្នាំ ☐ 435 ឆ្នាំ ☑ 543 ឆ្នាំ ☐ 352 ឆ្នាំ

១៣. ពុទ្ធសករាជ(ព.ស) កើតមុនគ្រិស្តសករាជចំនួន :

☐ 345 ឆ្នាំ ☐ 435 ឆ្នាំ ☑ 543 ឆ្នាំ ☐ 352 ឆ្នាំ

១៤. ព្រះពុទ្ធទ្រង់ប្រសូត្រ នៅមុនគ្រិស្តសករាជ ចំនួន :

☐ 345 ឆ្នាំ ☐ 435 ឆ្នាំ ☐ 543 ឆ្នាំ ☑ 624 ឆ្នាំ

១៥. មហាសករាជ កើតក្រោយពុទ្ធសករាជចំនួន :

☐ 345 ឆ្នាំ ☐ 435 ឆ្នាំ ☑ 621 ឆ្នាំ ☐ 762 ឆ្នាំ

១៦. ក្នុងចំនោមសាសនាខាងក្រោមនេះ តើសាសនាណា ដែលជាសាសនារបស់រដ្ឋ ?

☐ សាសនាគ្រិស្ត ☐ សាសនាអ៊ិស្លាម

☑ សាសនាព្រះពុទ្ធ ☐ សាសនាតៅ

១៧. គ្រិស្តរាជត្រូវបានបង្កើតឡើងនៅពេលដែលព្រះយេស៊ូទ្រង់ :

☐ អស់ជីវិត ☑ ប្រសូត្រ ☐ សាងផ្នួស

១៨. ពុទ្ធសករាជត្រូវបានបង្កើតឡើងចាប់តាំងពីពេល ដែលព្រះពុទ្ធទ្រង់ :

☐ ប្រសូត្រ ☐ សាងផ្នួស ☑ បរិនិព្វាន ☐ ត្រាស់ដឹង

១៩. តើស្ថាប័នណា ដែលបានបកប្រែគម្ពីរព្រះត្រៃ

បិតក ?

☐ ក្រសួងអប់រំ យុវជន និងកីឡា

☐ ក្រសួងព្រះបរមរាជវាំង

☑ ពុទ្ធសាសនបណ្ឌិត្យ

**២០.** និកាយហីនយាន គោរពប្រតិបត្តិតាម :

☐ អាចរិយវាទ ☑ ពុទ្ធវាទ ☐ វេទនិយម

**២១.** និកាយមហាយាន គោរពប្រតិបត្តិតាមលទ្ធិ :

☑ អាចរិយវាទ ☐ ពុទ្ធវាទ ☐ វេទនិយម

**២២.** ក្នុងចំនោមប្រទេសខាងក្រោមនេះ ប្រទេសដែលនិយមកាន់ពុទ្ធសាសនានិកាយហីនយាន គឺ :

☐ ជប៉ុន ☑ មីយ៉ាន់ម៉ា ☐ ទីបេ ☐ ឥណ្ឌូនេស៊ី

គ. <u>*ចូរបំពេញឃ្លាខាងក្រោមឲ្យបានត្រឹមត្រូវ :*</u>

១. ព្រះពុទ្ធសាសនាមានកំណើតនៅប្រទេស...*ឥណ្ឌា*...។

២. ព្រះពុទ្ធសាសនា បានចូលមកប្រតិស្ឋាននៅក្នុងប្រទេសកម្ពុជានៅ...*សតវត្សទី ៦ នៃ*......ក្នុងរាជព្រះបាទ...*ស្រីមារៈ ឬ ព្រាហ្មណ៍ខោណ្ឌិ*......*ពុទ្ធសករាជ ៨*(គ.ស ២៤៣)។

៣. ព្រះសិទ្ធត្ថបានចេញទៅសាងផ្នួសនៅក្នុងវេលានៃយប់...*ពេលពេញបូណ៌មី* ......



សុ.ចិ.ពុ.លិ !

*ឆ្នាំថោះ* ក្នុងជន្មាយុ..*២៩ ព្រះវស្សា*..។

៤. ព្រះពុទ្ធបានត្រាស់ដឹងនៅថ្ងៃ..*ពុធ ១៥ កើត ពេញបូរមី ខែពិសាខ ឆ្នាំ រកា*..ក្នុងជន្មាយុ*៣៥ វស្សា*

៥. ព្រះពុទ្ធចូលបរិនិព្វាននៅថ្ងៃ..*អង្គារ ១៥កើត ពេញបូរមី ខែពិសាខ ឆ្នាំម្សាញ់ (៥៤៣មុនគ.ស)* ក្នុងព្រះជន្ម ...*៨០ វស្សា*...។

៦. អ៊ីស្លាម សាសនាបានត្រូវគេគោរពប្រតិបត្តិច្រើនជាងគេនៅក្នុងប្រទេស..*ឥណ្ឌូនេស៊ី*..។

៧. ពុទ្ធសាសនា បែកចេញទៅជានិកាយធំៗពីរ តាំងពី..*ចុងសតវត្សទី ២*..នៃពុទ្ធសករាជរៀងមក

៨. ព្រះពុទ្ធសាសនាថេរវាទបែកចេញជាពីរនិកាយ គឺ.*គណៈមហានិកាយ*..និងគណៈធម្មយុត្តិកនិកាយ

៩. ឥស្លាមសាសនាមានដើមកំណើតនៅប្រទេស ..*អារ៉ាប៊ីសាអ៊ូឌីត*..។

១០. ព្រះពុទ្ធសាសនាបានកំណត់យកថ្ងៃទី ១៥ កើត ខែពិសាខជាថ្ងៃ " *បុណ្យពិសាខបូជា* " គឺជាថ្ងៃដែលរំលឹកដល់កាលដែលទ្រង់ ប្រសូត្រ ត្រាស់ដឹង និងចូលបរិនិព្វាន ។

១១. គេបានកំណត់យកថ្ងៃទី..*២៥*..ខែ..*ធ្នូ*..ជាថ្ងៃ

បុណ្យសម្រាប់សាសនាគ្រិស្ត ឬ ជាថ្ងៃកំណើត យេស៊ូគ្រិស្ត ហៅថាបុណ្យណូអែល (Noel ) ។

## II. សំនួររំលឹក

**សំនួរទី ១.** **តើជំនឿលើវត្ថុស័ក្តិសិទ្ធិ និងជំនឿសាសនាកើតឡើងយ៉ាងដូចម្តេច ?**

**ចម្លើយ** ជំនឿលើវត្ថុស័ក្តិសិទ្ធិ និងជំនឿសាសនាកើតឡើងនៅពេលដែលមនុស្សមានសេចក្តីត្រូវការសេចក្តីសង្ស័យ ហើយសំខាន់ជាងគេនៅពេលដែលមានសេចក្តីភ័យខ្លាចតក់ស្លុតនៅចំពោះមុខអានុភាពនៃអធិធម្មជាតិ ឬ វត្ថុស័ក្តិសិទ្ធិ ។

**សំនួរទី ២.** **ចំពោះអ្នក តើនិយមន័យសាសនាមួយណាដែលអ្នកយល់ថាមានលក្ខណៈត្រឹមត្រូវ ? ចូរបង្ហាញហេតុផល ។**

**ចម្លើយ** និយមន័យរបស់សាសនាទាំងអស់នៅក្នុងមេរៀននេះ សុទ្ធតែត្រឹមត្រូវ ប៉ុន្តែ និយមន័យដែលខ្ញុំគិតថាត្រឹមត្រូវជាងនោះ គឺនិយមន័យរបស់**ព្រះគ្រូមុនីសោភ័ណ**

គោរពនៅដោយលោកឱ្យនិយមន័យសាសនាថា គឺ មនុស្សធម៌ និងជាយុត្តិធម៌ ឬ ជាវិន័យដែលជាបទបញ្ញត្តិ ដូចានេះប្រសិនបើមនុស្សប្រតិបត្តិតាមនិយមន័យនេះ និង នាំឱ្យមនុស្សទទួលបានភាពសុខសាន្តក្នុងជីវិត ។

**សំណួរទី ៣.** ប្រជាជនខ្មែរគោរពច្រើនជំនឿលើសេលម់ គោរព ព្រះពុទ្ធសាសនា ។ តើព្រះពុទ្ធសាសនាមានលក្ខណៈ សំខាន់អ្វីខ្លះដែលនាំឱ្យប្រជាជនខ្មែរគោរពប្រតិបត្តិ ?

**ចម្លើយ** លក្ខណៈសំខាន់ដែលនាំឱ្យប្រជាជនខ្មែរគោរព ប្រតិបត្តិព្រោះ :

- ជាសាសនារបស់[illegible]
- ជាសាសនាដែលមានហេតុផលរៀនប្រដៅមនុស្សឱ្យ [illegible]លើកម្ម និងផល
- [illegible]នាំឱ្យប្រព្រឹត្តតែអំពើល្អ សុចរិត ។

**សំណួរទី ៤.** [illegible]

របស់ខ្មែរ តាំងពីកើតរហូតដល់ស្លាប់ ៗ តើពាក្យនោល នេះមានន័យដូចម្ដេច ?

**ចម្លើយ** មានន័យថាជនជាតិខ្មែរគ្រប់រូបបានគោរព និង អនុវត្តតាមការអប់រំរបស់ពុទ្ធសាសនា ដោយហេតុថា ទទួលបានសេចក្ដីសុខ សុខសាន្ត ទើបជនជាតិខ្មែរ ប្រតិបត្តិតាម ។

**សំនួរទី ៥. ចូរនិយាយពីដើមកំណើតសាសនាឥស្លាម ៗ**

**ចម្លើយ** សាសនាឥស្លាមកើតឡើងនៅក្នុងផែនដីអារ៉ាប់ ដោយ ឋាររមេដឹកនាំម្នាក់ឈ្មោះមហាម៉ត( **Mahomat** ) រស់នៅទីក្រុង ឡាម៉ិច( **La Mecque** ) នៃប្រទេស អារ៉ាប៊ី ។ ពាក្យថាឥស្លាមជាឈ្មោះជំនឿចំពោះព្រះ អល់ឡោះ **(Allah)** ។

**សំនួរទី ៦. តើពាក្យថា ម៉ូស្លីម មានន័យដូចម្ដេច ?**

**ចម្លើយ** ពាក្យថាម៉ូស្លីមជាឈ្មោះនៃអ្នកកាន់លិទ្ធិឥស្លាម ។ គេបានជឿប្រាកថា ព្រះអល់ឡោះបានចាត់មហាម៉ាត់ដែល ជា ព្យាការី ឱ្យមកប្រកាសលទ្ធិឥស្លាមដល់ប្រជាជន ។ គម្ពីរធំរបស់សាសនាឥស្លាមឈ្មោះថាកូអាន **(Our'an)** ។

## ៥.២ មេរៀនទី២ : ស្ថាប័នព្រះសង្ឃ និងរដ្ឋ

### I. សំនួរត្រិះរិះ

☛ <u>សំនួរទី ១.</u> តើពុទ្ធសាសនាថេរវាទនាំចូលមកក្នុងប្រទេសកម្ពុជានៅពេលណា ?

✍ <u>ចម្លើយ</u> ពុទ្ធសាសនាថេរវាទនាំចូលមកក្នុងប្រទេសកម្ពុជាចាប់តាំងពីពុទ្ធ**សតវត្សទី ៣ នៃពុទ្ធសករាជ** ។

☛ <u>សំនួរទី ២.</u> តើព្រះពុទ្ធសាសនានៅកម្ពុជាមានប៉ុន្មាននិកាយ ? តើមាននិកាយអ្វីខ្លះ ?

✍ <u>ចម្លើយ</u> ព្រះពុទ្ធសាសនាថេរវាទបែកចេញជា**ពីរនិកាយ** គឺ.***គណៈមហានិកាយ***..និង គណៈធម្មយុត្តិកនិកាយ។

☛ <u>សំនួរទី ៣.</u> ហេតុអ្វីបានជាព្រះពុទ្ធសាសនានៅកម្ពុជាត្រូវបំបាត់ចោលនៅចន្លោះឆ្នាំ ១៩៧៥-១៩៧៩ ?

✍ <u>ចម្លើយ</u> បានជាព្រះពុទ្ធសាសនានៅកម្ពុជា ត្រូវបំបាត់ចោលនៅចន្លោះឆ្នាំ ១៩៧៥-១៩៧៩ ព្រោះថិតក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ (ប៉ុលពត ឬខ្មែរក្រហម) ។ គោលការណ៍របស់គេ គឺលុបបំបាត់ចោលសាសនាទាំងអស់នៅក្នុងប្រទេសកម្ពុជា ពួកវាបានបំផ្លាញចោលនូវវិហារ វត្តអារាម ផ្សឹកលោកសង្ឃជាដើម ។

**សំនួរទី ៤.** តើគណៈសង្ឃនាយកទាំងពីរគណៈមានតួនាទីដូចម្តេចខ្លះក្នុងព្រះពុទ្ធសាសនា ?

**ចម្លើយ** គណៈសង្ឃនាយកទាំងពីរគណៈមានតួនាទីគ្រប់គ្រងព្រះសង្ឃនៅទូទាំងប្រទេសកម្ពុជាទៅតាមគណៈដោយខ្លួន ពីគ្នាពុំបានចូលរួមជាមួយគ្នាទេ ។ ប៉ុន្តែបើមានការត្រូវដេញព្រះសង្ឃ ប្រកាស ឬព្រះសង្ឃបញ្ញត្តិជាសាធារណៈត្រូវរួបរួមជាមួយគ្នា មិនចំពោះនិកាយណាមួយទេ ។

**សំនួរទី ៥.** តើស្ថាប័នណាមានតួនាទីដឹកនាំគ្រប់គ្រងកិច្ចការសាសនា ?

**ចម្លើយ** ស្ថាប័នដែលមានតួនាទីដឹកនាំគ្រប់គ្រង កិច្ចការសាសនា គឺក្រសួងធម្មការ និងសាសនា ។

**សំនួរទី ៦.** ហេតុអ្វីបានជាប្រជាជនខ្មែរគោរពប្រតិបត្តិព្រះពុទ្ធសាសនាថេរវាទ ?

**ចម្លើយ** បានជាប្រជាជនខ្មែរគោរពប្រតិបត្តិព្រះពុទ្ធសាសនថេរវាទព្រោះគេយល់ថាអាចនឹងឱ្យពួកគេទីពឹង និង ជឿជាក់ថាអាចនាំពួកគេទៅរកសេចក្តីសុខបាន ។

**សំនួរទី ៧.** តើរាជរដ្ឋាភិបាលមានគោលនយោបាយ

**បែបណាខ្លះ ចំពោះពុទ្ធសាសនា និងសាសនាដទៃទៀតនៅកម្ពុជា ?**

**ចម្លើយ** ក្រោយពីឆ្នាំ ១៩៧៩ ក្រុមប្រឹក្សារណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានយកចិត្តទុកដាក់ផ្ដួចផ្ដើមរៀបចំពុទ្ធសាសនាឱ្យអតីតបព្វជិតបានបួសបន្តជីវិតពុទ្ធសាសនាជាថ្មីបន្តទៀត ។ ចាប់ពីពេលនោះមក ក្រុមប្រឹក្សារណសិរ្សសាមគ្គីសង្គ្រោះជាតិ កម្ពុជា ជាអ្នកដឹកនាំគ្រប់គ្រងដោយមានការនាយកដ្ឋានសាសនាជាសេនាធិការក្នុងអនុវត្តគោលនយោបាយចំពោះសាសនា ។ ផ្ដើមចេញពីសារៈសំខាន់ជាវិជ្ជមានរបស់ពុទ្ធសាសនាសម្រាប់កម្ពុជា និងស្ថានភាពសេដ្ឋកិច្ចនយោបាយរបស់ប្រទេសជាតិមានការវិវត្តទើបរដ្ឋាភិបាលនៃរដ្ឋកម្ពុជាបង្កើតឱ្យមានក្រសួងធម្មការ និងសាសនាឡើងវិញនៅឆ្នាំ ១៩៩២ ដោយទទួលខុស ត្រូវលើវិស័យបីជាសំខាន់វិស័យធម្មការ វិស័យពុទ្ធិកសិក្សា និងពុទ្ធសាសនបណ្ឌិត្យ ។ ការគ្រប់គ្រងបព្វជិតរាប់ម៉ឺនអង្គ ហើយក៏ជាភារកិច្ច និងការទទួលខុសត្រូវរបស់ក្រសួងធម្មការ និងសាសនា ។

**<u>សំនួរទី ៨</u> តើស្ថាប័នណា ដែលបានបកប្រែ**

គម្ពីរព្រះត្រៃបិតក ?នៅឆ្នាំណា ?មានសមាជិកបកប្រែប៉ុន្មាននាក់ ?

**ចម្លើយ** ស្ថាប័ន ដែលបានបកប្រែគម្ពីរព្រះត្រៃបិតក គឺពុទ្ធសាសនបណ្ឌិត្យ នៅឆ្នាំ **១៩២៩** មានសមាជិកបកប្រែប្រមាណ **៥០** នាក់។

**សំនួរទី ៩ តើព្រះពុទ្ធសាសនាមានកំណើតនៅប្រទេសណា ? នៅពេលណា ? ចែកចេញជាប៉ុន្មាននិកាយ ? អ្វីខ្លះ ? នៅពេលណា ? ហើយបានផ្សព្វផ្សាយទៅទិសខាងណាខ្លះនៃប្រទេសឥណ្ឌា ?តើប្រទេសណាខ្លះ និយមកាន់និកាយហីនយាន ហើយប្រទេសណាខ្លះ និយមកាន់និកាយមហាយាន ?**

**ចម្លើយ ក.** ព្រះពុទ្ធសាសនា មានកំណើតនៅប្រទេស **ឥណ្ឌា** ក្នុងសតវត្សទី 6 **មុនគ.ស** ។

**ខ.** ចែកចេញជា 2 **និកាយ** ឬ **លទ្ធិ** គឺ និកាយហីនយាន ឬ ថេរវាទ និងមហាយាន ឬ អាចរិយវាទនៅ**ចុងសតវត្សទី 2 នៃព.ស** ។

**គ.** និកាយហីនយាន បានផ្សព្វផ្សាយទៅទិសខាងត្បូង

នៃប្រទេសឥណ្ឌា រីឯនិកាយមហាយានវិញ បានផ្សព្វផ្សាយទៅទិសខាងជើង នៃប្រទេសឥណ្ឌា ។

ឃ- ប្រទេសនិយមកាន់ និកាយហីនយានច្រើនមាននៅ*អាស៊ីអាគ្នេយ៍* ដូចជា : ប្រទេស កម្ពុជា ថៃ ឡាវ មីយ៉ាន់ម៉ា ស្រីលង្កា ឥណ្ឌា នេប៉ាល់។ល។ រីឯ ប្រទេសនិយមកាន់និកាយមហាយានច្រើនមាននៅ*អាស៊ីបូព៌ា* ដូចជា : ប្រទេសចិន វៀតណាម ជប៉ុន ទីបេ ម៉ុងហ្គោល ។ល។



*ព្រះពោធិសត្វ លោកេស្វរៈ*



*អវលោកេស្វរៈ*



*ព្រះពោធិសត្វ ប្រជ្ញាបារមិតា*

## ៥.២ មេរៀនទី៣ : វត្តអារាម និងព្រះសង្ឃនៅកម្ពុជា

### I. សំណួរត្រិះរិះ

**សំនួរទី ១. តើវត្តអារាមមានន័យដូចម្ដេច ?
តើវត្តអារាមរីកចម្រើនដោយសារអ្វី ?**

**ចម្លើយ** វត្ត មានន័យថា ជាទីកន្លែងសម្រាប់គោរពបូជា ជាកន្លែងសម្រាប់ព្រះសង្ឃគង់នៅ ។ **វត្តអារាម** ជាទីកន្លែងស្ងប់ស្ងាត់ ត្រជាក់ត្រជុំ ស្អាតបរិសុទ្ធ ជាសួនឧទ្យានប្រកបដោយព្រឹក្សា និងជាទីស្នាក់អាស្រ័យរបស់អ្នកបួសអប់រំចិត្តជម្រះកិលេសតណ្ហា ដើម្បីកាត់ផ្ដាច់ការជាប់ជំពាក់នឹងជីវភាពរស់នៅរបស់មនុស្ស និងជាទីកន្លែងគោរពបូជា ធ្វើបុណ្យទានផ្សេងៗ ។

ខ. វត្តអារាមរីកចម្រើនដោយសារ :

- **ប្រជាជនខ្មែរ**ជាពិសេស**ពុទ្ធសាសនិក** មិនអាចរស់នៅដោយគ្មានពុទ្ធសាសនាបានទេ ។
- ប្រជាជនខ្មែរយល់ថាការកសាងវត្តអារាម និងទទួលបានកុសលជាបុណ្យនៅជាតិខាងមុខទៀត ។
- វត្តអារាមជាទីតាំងនៃព្រះពុទ្ធសាសនា ដែលជាទីពឹងពំនាក់របស់ប្រជាជនគ្រប់រូប ។

**សំនួរទី ២. ចូរពិពណ៌នាពិធីបំបួសនាគ ?**

**ចម្លើយ** ពិធីបំបួសនាគ

ពាក្យ "**នាគ**" មានន័យថា ប្រសើរ ចម្បង បិរសុទ្ធ ។

"**នាគ**" សំដៅបុគ្គលិកបុថុជ្ជនណាម្នាក់ដែលកើតមានសេចក្តីអៀនខ្មាស់ ខ្លាចបាប ហើយមានចិត្តជ្រះថ្លាទៅសាងផ្នួសក្នុងសំណាក់ព្រះពុទ្ធសាសនា ។ កុលបុត្រដែលបម្រុងខ្លួនចូលទៅ សាងផ្នួសជាសាមណេរនៅក្នុងព្រះពុទ្ធសាសនា ត្រូវបានទទួលនាមថាជា "**នាគ**" ។

អតីតកាល ពិធីនេះគេធ្វើចំនួនពីរថ្ងៃ ឬបីថ្ងៃតែបច្ចុប្បន្នពិធីនេះគេធ្វើត្រឹមតែមួយថ្ងៃប៉ុណ្ណោះ ។ ពិធីបុណ្យនេះគេអាចរៀបចំធ្វើនៅក្នុងវត្តក៏បាន ឬនៅតាមគេហដ្ឋានរបស់ដែលត្រូវបួសក៏បាន។ ក្រៅពីត្រៃចីវរ និងបរិក្ខារចាំបាច់ដទៃទៀត សម្រាប់អ្នកបួស គេឃើញមានការរៀបចំបាយសិធំមួយ ធ្វើអំពីដើមចេកដែលមានដប់ប្រាំបួនថ្នាក់។ បាយសីនេះរុំព័ទ្ធដោយ ធាងចេក និង មានសំពត់ហូលរុំពីក្រៅមួយជាន់ទៀត ។

គេរៀបចំក្បួនហែនាគចេញទៅវត្តនៅពេលព្រឹកដោយ

មានភ្លេងឆៃយាំ ឬភ្លេងពិណពាទ្យគំដរផង ។ នាគអាច ជិះសេះ ឬគោ និងមានអ្នកចាំងឆ័ត្រឱ្យ ព្រមទាំងហែហម ដោយម្ដាយទូលត្រៃចីវរ ឪពុកស្ពាយបាត្រ និងអ្នកកាន់ បរិក្ខាផ្សេងៗទៀត។ ជាទូទៅនាគស្លៀកហូល ពានាក្រមា ពណ៌ស ឆៀងលើស្មាឆ្វេង។ ក្បួនដង្ហែត្រូវប្រទក្សិណជុំវិញ ព្រះវិហារបីជុំទើបហែរចូល ដើម្បីសំដែងសេចក្ដីគោរព ចំពោះកុលបុត្រដែលបានចូលសាងផ្នួស ។ ពិធីនេះសន្មត់ ថាចប់ត្រឹមនេះ ហើយបន្តទៅទៀតនាគនេះនឹងត្រូវ បំបួសជាសាមណេរ ។

**<u>សំនួរទី ៣.</u> តើពិធីបំបួសជាសាមណេរ ភិក្ខុប្រព្រឹត្ត ទៅដូចម្ដេចខ្លះ ?**

**<u>ចម្លើយ</u>** ពិធីបំបួសជាសាមណេរ ភិក្ខុប្រព្រឹត្តទៅតាម ប្រពៃណីខ្មែរ ការបួសជាសាមណេរមានន័យថា បួសសង គុណម្ដាយ។ កាលសម័យដើមការបួសជាសាមណេរចាប់ ពីអាយុ ៧ ឆ្នាំ ប្រសិនបើក្មេងនោះនិយាយច្បាស់និងមាន ប្រាជ្ញា។ ប៉ុន្តែក្រោយមក អ្នកបួសមានអាយុចាប់ពី១២ឆ្នាំ ឬ ច្រើនជាងនេះ ព្រមទាំងមិនមានទោសកំហុសចំពោះ

វិន័យព្រះពុទ្ធសាសនា និងច្បាប់របស់ប្រទេស ។ មុននឹងបួសត្រូវមានបាត្រ ស្បង់ជីពរ (ត្រៃចីវរ)កោរសក់ កោរពុកមាត់ ពុកចង្កា កាត់ក្រចកឱ្យស្អាត។ ជាទូទៅការបួសជាសាមណេរ ត្រូវឆ្លងកាត់ ការបួសនាគជាមុនសិន ។

**<u>សំនួរទី ៤.</u> តើការបួសជាសាមណេរ និងការបួសជាភិក្ខុមានលក្ខណៈខុសគ្នាដូចម្ដេចខ្លះ ?**

**<u>ចម្លើយ</u>** ការបួសជាសាមណេរ និងការបួសជាភិក្ខុមានលក្ខណៈខុសគ្នា

+ **ការបួសជាសាមណេរ :**

- កាលសម័យដើមការបួសនេះគេមិនកំណត់អាយុទេ បើពីសម័យពុទ្ធកាល ការបួសជាសាមណេរ ចាប់ពីអាយុ៧ ឆ្នាំ ប្រសិនបើក្មេងនោះនិយាយច្បាប់ និងមានប្រាជ្ញា ។ ប៉ុន្តែក្រោយមក អ្នកបួសមានអាយុចាប់ពី ១២ឆ្នាំ ឬ ច្រើនជាងនេះរហូតដល់ ៨០ ឆ្នាំក៏បាន ។
- អ្នកបួសជាសាមណេរត្រូវរក្សាសីល ១០ និង សេខិយវត្ត ៧៥ ឱ្យបានខ្ជាប់ខ្ជួន ។
- ការបួសជាសាមណេរ មានន័យថា បួសសងគុណម្ដាយ

- ជាទូទៅការបួសជាសាមណេរ ត្រូវឆ្លងកាត់ ការបួសនាគជាមុនសិន ។

\+ **ការបួសជាភិក្ខុ :**

- មានអាយុយ៉ាងតិច ២១ ឆ្នាំ ឡើងទៅ
- ត្រូវរក្សាសីល៤ ហៅថា **ចតុបារិសុទ្ធិសីល**
- បាតិមោក្ខសំវរ សង្រួមតាមសិក្ខាបទ ២២៧
- ឥន្ទ្រីយសំវរ សង្រួមឥន្ទ្រីយ៦
- អាជីវបារិសុទ្ធី ចិញ្ចឹមជីវិតតាមគន្លងសេចក្តីបរិសុទ្ធ
- បច្ចយសន្និសិត្ស ពិចារណាសិន សឹមបរិភោគបច្ច័យ៤ ។
- ការបួសជាភិក្ខុមានន័យថាបួសសងគុណឪពុក ។

**<u>សំនួរទី ៥.</u> ហេតុអ្វីបានជាប្រជាជនខ្មែរមួយចំនួនចង់ឱ្យកូនប្រុសសាងផ្នួស ?**

**<u>ចម្លើយ</u>** បានជាប្រជាជនខ្មែរមួយចំនួន ចង់ឱ្យកូនប្រុសសាងផ្នួសព្រោះ ក្នុងព្រះពុទ្ធសាសនាអ្នកដែលបានបួសជាមនុស្សល្អ ដឹងខុសត្រូវ ជាមនុស្សស្អាតបរិសុទ្ធ និងអាចស្វែងរកសេចក្តីស្ងប់ចិត្ត តាមរយៈការសង្រួមកាយ វាចា ចិត្ត ដោយអាស្រ័យតាមធម៌វិន័យ ។

**<u>សំនួរទី ៦.</u> តើវត្តអារាមរបស់ព្រះពុទ្ធសាសនានៅ**

## កម្ពុជាមាននាទីសំខាន់អ្វីខ្លះចំពោះសង្គមជាតិ ?

**ចម្លើយ** វត្តអារាមរបស់ព្រះពុទ្ធសាសនានៅកម្ពុជាមាននាទីសំខាន់ចំពោះសង្គមជាតិដូចជា :

**ក. ផ្នែកអប់រំ :**

- អប់រំមនុស្សឱ្យប្រព្រឹត្តតែអំពើល្អ
- ជាថ្នាលបណ្តុះនូវចំណេះដឹង និងជំនាញវិជ្ជាជីវៈ
- ផ្តល់ជាកន្លែងស្ងប់ស្ងាត់រំងាប់ចិត្ត
- ឃ្លាំងចំណេះដឹង ជាបណ្ណាល័យ ជាសារមន្ទីរវប្បធម៌ អក្សរសាស្ត្រជាតិ ។

**ខ. ផ្នែកវប្បធម៌ :**

- រក្សា និង ផ្ទុកនូវសម្បត្តិវប្បធម៌របស់ជាតិ
- រក្សាប្រពៃណី និងទំនៀមទម្លាប់ជាតិ
- កន្លែងបណ្តុះសីលធម៌ គុណធម៌ និងបណ្តុះពូជនៃបុណ្យកុសល
- កន្លែងពឹងពាក់នៃអ្នកភ័យខ្លាចនឹងសេចក្តីស្លាប់ ស្អប់ខ្ពើមអំពើបាប និងអ្នកចង់កសាងអំពើល្អ
- ជាកន្លែងធ្វើបុណ្យទានផ្សេងៗដូចជា បុណ្យកឋិន បុណ្យ

ភ្ជុំបិណ្ឌ បុណ្យមាឃបូជា បុណ្យចូលឆ្នាំ ។

**គ. ផ្នែកសង្គមកិច្ច និងសុខាភិបាល :**

- ជាកន្លែងពឹងពាក់នៃអ្នកភ័យខ្លាច អ្នកក្រខ្សត់
- ជាមន្ទីរពេទ្យព្យាបាលផ្លូវចិត្ត
- កន្លែងស្ងប់រំងាប់ចិត្តឱ្យផុតកង្វល់ក្នុងជីវិត
- ជាវណ្ណៅកប់ចោលទំនាស់ ជម្លោះ និង ជាកន្លែងដែលមនុស្សទាំងអស់មានភាពស្មើគ្នា
- ជួយឧបត្ថម្ភជនក្រីក្រ និងកុមារកំព្រា
- ជួយកសាងហេដ្ឋារចនាសម្ព័ន្ធជាតិដូចជា ផ្លូវ សាលារៀន អណ្ដូងទឹក..។

**ឃ. ផ្នែកសេដ្ឋកិច្ច បរិស្ថាន :**

- បណ្ដុះវិជ្ជាជីវៈដល់និសិត្ស ក្មេងវត្តឱ្យចេះរកប្រាក់តាមវយៈចំណេះដឹងរបស់ពួកគេ( ធ្វើតុ ទូ កៅអី ...)
- ជួយថែរក្សា និងដាំកូនឈើ (បំបួសដើមឈើ )...។ល។

## ៥.១ មេរៀនទី៤ : ភាពជាបព្វជិតក្នុងព្រះពុទ្ធសាសនាថេរវាទ

### I. សំនួរត្រិះរិះ

☛ **សំនួរទី ១. តើមានលក្ខណៈខុសគ្នាដូចម្តេចខ្លះរវាងបព្វជិត និងគ្រហស្ថ ?**

✍ **ចម្លើយ** លក្ខណៈខុសគ្នារវាងបុព្វជិត និង គ្រហស្ថ :

**ក. បុព្វជិត** ត្រូវរក្សាសីល ៤ គឺ ចតុប្បារិសុទ្ធិសីល ដែលរួមមាន បាតិមោក្ខ សំវរសីល ឥន្ទ្រីយ សំវរសីល អាជីវបារិសុទ្ធិសីល បច្ច័យសន្និស្សិតសីល និងត្រូវគ្រងចីវរ ។

**ខ. ចំណែកឯគ្រហស្ថ**វិញគ្រាន់តែបំពេញនូវភាពត្រឹមត្រូវដោយកាយ វាចាជាដើម និង ប្រកបរបរចិញ្ចឹមជីវិតដោយត្រឹមត្រូវជារៀងរាល់ថ្ងៃតែប៉ុណ្ណោះ និងស្លៀកពាក់ធម្មតា ។

☛ **សំនួរទី ២. តើភិក្ខុសង្ឃមានតួនាទីក្នុងព្រះពុទ្ធសាសនា និងក្នុងសង្គមដូចម្តេចខ្លះ ?**

✍ **ចម្លើយ** ភិក្ខុសង្ឃមានតួនាទីក្នុងព្រះពុទ្ធសាសនា និងក្នុងសង្គមដូចជា :

- ជាគ្រូបង្រៀន ជាអ្នកអប់រំសីលធម៌ ចរិយាធម៌ និងជាអ្នករក្សាវប្បធម៌ សាសនាជាតិ ។
- ជាទីពឹង ទីរលឹករបស់ពុទ្ធបរិស័ទ ។
- ជាអ្នកដោះស្រាយទំនាស់ និងសម្រុះសម្រួល ដោយសន្តិវិធី អហិង្សា ។
- ជាអ្នកផ្តួចផ្តើមកសាងសាលារៀន ផ្លូវថ្នល់ ទីវត្ត..។
- ជាអ្នកស្វែងរកសន្តិភាព ដោយសន្តិវិធីជូនប្រទេសជាតិ និងជនរួមជាតិដូចជា ការ ធ្វើធម្មយាត្រាបួងសួងសុំសន្តិភាពជាដើម ។
- ជាអ្នកដោះស្រាយវិបត្តិផ្លូវចិត្តដល់អ្នកជួបវិបត្តិ ។
- ជាអ្នកថែរក្សា និងការពារលទ្ធិដែលមានចែងក្នុងព្រះពុទ្ធសាសនា ។
- ជាអ្នកប្រៀបប្រដៅអប់រំដឹកនាំពុទ្ធបរិស័ទឱ្យប្រព្រឹត្តិតែអំពើល្អតាមរយៈការទេសនា ។

**<u>សំនួរទី ៣.</u> តើជីវភាពប្រចាំថ្ងៃរបស់បព្វជិតក្នុងព្រះពុទ្ធសាសនាថេរវាទមានអ្វីខ្លះ ?**

**<u>ចម្លើយ</u>** ជីវភាពប្រចាំថ្ងៃរបស់បព្វជិតក្នុងព្រះពុទ្ធសាសនាថេរវាទ គឺពឹងផ្អែកលើកម្លាំងស្មុង ដើម្បីស្វែងរកចង្ហាន់

ពេលព្រឹកទ្រង់និមន្តបិណ្ឌបាត ពីម៉ោង ៦ ដល់ម៉ោង ១២ ថ្ងៃត្រង់ តែប៉ុណ្ណោះ ។

**សំនួរទី ៤.** ដើម្បីធ្វើខ្លួនឱ្យមានភាពបរិសុទ្ធក្នុងព្រះពុទ្ធសាសនា តើភិក្ខុនីត្រូវគោរពប្រតិបត្តិសិក្ខាបទអ្វីខ្លះ ?

**ចម្លើយ** ដើម្បីធ្វើខ្លួនឱ្យមានភាពបរិសុទ្ធក្នុងព្រះពុទ្ធសាសនា ភិក្ខុនីត្រូវគោរពប្រតិបត្តិសិក្ខាបទទាំង ៨ ប្រការដូចខាងក្រោម :

១. ភិក្ខុនីមិនត្រូវបណ្តែតបណ្តោយខ្លួនក្នុងមេថុនកម្ម (ការរួមភេទ) ។

២. ភិក្ខុនីមិនត្រូវលួចទ្រព្យសម្បត្តិគេ ។

៣. ភិក្ខុនីមិនត្រូវសម្លាប់សត្វ ។

៤. ភិក្ខុនីមិនត្រូវពោលពាក្យអួតអាងហួសពីការពិត ។

៥. ភិក្ខុនីមិនត្រូវបណ្តោយខ្លួនក្នុងការព្រមព្រៀងសេពកាមជាមួយបុរស ។

៦. ភិក្ខុនីមិនត្រូវលាក់កំបាំងធ្ងន់ធ្ងររបស់ភិក្ខុនីដទៃ ។

៧. ភិក្ខុនីមិនត្រូវទទួលយកការណែនាំរបស់ភិក្ខុដែលត្រូវសង្ឃព្យួរទោស ។

៨. ភិក្ខុនីមិនត្រូវរំលោភបំពានដោយចេតនា លើសិក្ខាបទទាំងឡាយដោយមានបំណងអាក្រក់ ។

·ទន្ទឹមនឹងសិក្ខាបទដូចបានរៀបរាប់ខាងលើ វិន័យបដិកបានបំភ្លឺច្បាស់ថា សិក្ខាបទខ្លះដែលកំណត់សម្រាប់ភិក្ខុនីដូចគ្នា និងសិក្ខាបទ កំណត់ឡើងសម្រាប់ភិក្ខុដែរ ។ សិក្ខាបទទាំងនោះមានដូចជា :

- ភិក្ខុនីមួយអង្គត្រូវមានបាត្រតែ ១ ។
- វត្ថុណាមួយផ្តល់ឱ្យភក្ខុនីសម្រាប់គោលដៅណាមួយគប្បីប្រើប្រាស់វត្ថុនោះសម្រាប់គោលដៅនោះ ។
- ភិក្ខុនីមិនត្រូវបោះវត្ថុសៅហ្មងនៅលើផ្លូវសាធារណៈ ឬក្នុងស្រែចំការទេ ។
- ភិក្ខុនីមិនត្រូវនិយាយជាមួយនរណាម្នាក់ក្នុងទីងងឹតកន្លែងកៀន ក្រោមពន្លឺព្រះចន្ទ ។
- ភិក្ខុនីពីរអង្គមិនត្រូវសឹងលើគ្រែជាមួយគ្នាទេ ។
- ភិក្ខុនីមិនត្រូវអង្គុយនៅចំពោះមុខភក្ខុដោយគ្មានការអនុញ្ញាតពីភក្ខុទេ ។
- ភិក្ខុនីមិនត្រូវចេញក្រៅនៅពេលយប់ ។ល។

ព្រះសម្មាសម្ពុទ្ធទ្រង់មានបន្ទូលថា កាលណាសិក្ខាបទសម្រាប់ភិក្ខុនីមានខ្លឹមសារដូចគ្នា និងសិក្ខាបទកំណត់

ឡើង សម្រាប់ភិក្ខុ ភិក្ខុនីគប្បីប្រតិបត្តិតាមសិក្ខាបទទាំងនោះ ។

**<u>សំនួរទី ៥.</u> តើភិក្ខុសង្ឃដែលបានប្រព្រឹត្តល្មើសនឹងសិក្ខាបទ"អករណីយកិច្ច ៤ យ៉ាងឬបារាជិក ៤ " ត្រូវមានទោសដូចម្តេច ?**

**<u>ចម្លើយ</u>** ភិក្ខុសង្ឃដែលបានប្រព្រឹត្តល្មើសនឹងសិក្ខាបទ "អករណីយកិច្ច ៤ យ៉ាងឬបារាជិក ៤ "ត្រូវមានទោស សិក្ខាបទ ឬវិន័យរបស់ព្រះសង្ឃប្រៀបបាននឹងច្បាប់រដ្ឋធម្មនុញ្ញនៃប្រទេសមួយសម្រាប់ឱ្យព្រះសង្ឃប្រតិបត្តិតាម ។ ផ្ទុយមកវិញបើព្រះភិក្ខុសង្ឃអង្គណាមួយប្រព្រឹត្តល្មើស និងសិក្ខាបទនេះនឹងត្រូវអាបត្តិ (ទោស) ។ បារាជិក ៤ ឬអករណីកិច្ច ៤ យ៉ាងដែលស្ថិតនៅក្នុងបាតិមោក្ខសំវរសីល គឺជាគរុកាបត្តិ ឬអាបត្តិធំដែលហៅថា "ទោសធ្ងន់បំផុត" ។ បើព្រះភិក្ខុសង្ឃអង្គណាដែលត្រូវអាបត្តិបារាជិកនេះ ព្រះសង្ឃនោះត្រូវតែលាចាកពីភាពជាបព្វជិតជាដាច់ខាត ព្រោះភិក្ខុនោះអស់ភាព

បរិសុទ្ធហើយមិនត្រូវនៅបន្លំខ្លួនជាភិក្ខុឱ្យពុទ្ធបរិស័ទបព្វជិតផងគ្នា គោរពបូជាឡើយ ព្រោះវានាំឱ្យមានទោសធ្ងន់ណាស់ ហើយនាំឱ្យអាប់ឱនដល់ព្រះពុទ្ធសាសនាផង។ ចំពោះភិក្ខុដែលត្រូវអាបត្តិ "សង្ឃាទិសេស"(ទោសស្រាលជាងបារាជិក) ត្រូវទទួលស្គាល់កំហុសរបស់ខ្លួន និងប្ដេជ្ញាកែខ្លួនតាមកម្រិតវិន័យ ដើម្បីបានភាពបរិសុទ្ធវិញ ។ ភិក្ខុដែលត្រូវអាបត្តិផ្សេងៗទៀត បន្ទាប់ពីសង្ឃាទិសេសត្រូវសំដែងអាបត្តិ (សារភាពទោស)តាមរយៈឧបោសថកម្មចំពោះមុខសង្ឃ ដើម្បីបានភាពបរិសុទ្ធឡើងវិញ ។

**<u>សំនួរទី ៦.</u> ក្នុងនាមជាពុទ្ធសាសនិកម្នាក់ តើអ្នកដឹកនាំជីវិតរបស់អ្នកដោយរបៀបណា ? តើអ្នកប្រកាន់វិន័យយ៉ាងណាខ្លះក្នុងជីវភាពប្រចាំថ្ងៃ ?**

**<u>ចម្លើយ</u>** ក្នុងនាមជាពុទ្ធសាសនិកមួយរូប ខ្ញុំនឹងដឹកនាំជីវិតរបស់ខ្ញុំតាមគន្លងផ្លូវត្រឹមត្រូវតាមពុទ្ធឱវាទ ដែលលោកបានអប់រំមនុស្សយើងឱ្យដើរក្នុងផ្លូវត្រូវ មិនឱ្យវៀចវេរព្រោះវានាំឱ្យវិនាស ឬ នាំឱ្យមានបាប ។

ដូច្នេះខ្ញុំត្រូវប្រកាន់ខ្ជាប់នូវវិន័យ :

- ប្រកបរបរសុចរិត មិនភូតកុហក់គេ មិនកិបកេងបោកប្រាស់អ្នកដទៃ
- ចេះជួយទុក្ខធុរៈ អាសាគេ និងចេះធ្វើសម្បទានដល់អ្នកក្រខ្សត់ ទុរគត..
- រក្សាសីល ៥ (បាណា អទិន្នា មុសា កាមេ និងសុរា)
- វៀរចាកនូវអគតិទាំង ៤ យ៉ាង គឺ ឆន្ទា ទោសោ មហោ និងភយាគតិ ។
- មានយុត្តិធម៌ចំពោះអ្នកដទៃ ។

☛ **សំនួរទី ៧. ប្រសិនបើព្រះសង្ឃប្រព្រឹត្តកំហុសឆ្គង តើមានផលវិបាកអ្វីខ្លះសម្រាប់សង្គម ?**

✍ **ចម្លើយ** ប្រសិនបើព្រះសង្ឃប្រព្រឹត្តកំហុសឆ្គងមានផលវិបាកដូចជា :

- ធ្វើឱ្យសង្គមជាតិអាប់អោន មិនរីកចម្រើនជាតិពិសេសធ្វើឱ្យមានការមាក់ងាយពីប្រជាជាតិដទៃ
- បាត់បង់ជំនឿសាសនាការគោរពពីពុទ្ធបរិស័ទ
- មនុស្សក្នុងសង្គមលែងឱ្យតម្លៃ និងគោរពវត្តអារាម ។

☛ **សំនួរទី ៨. តើអករណីយកិច្ចគឺជាអ្វី ?**

✍ **ចម្លើយ គឺកិច្ចដែលបព្វជិតមិនត្រូវធ្វើមាន ៤ ប្រការ**

- ការសេពមេថុនធម្ម (ការរួមភេទ)
- ការកាន់យកទ្រព្យសម្បត្តិដែលគេមិនបានប្រគេន
- ការសម្លាប់សត្វ
- ការពោលពាក្យអួតអាងអំពីគុណវិសេសដែលមិនមាននៅក្នុងខ្លួន ។

**សំនួរទី ៩. តើត្រៃសិក្ខាគឺជាអ្វី ?**

**ចម្លើយ** ត្រៃសិក្ខា គឺគុណធម៌ដែលបព្វជិតត្រូវសិក្សា និងប្រតិបត្តិមាន ៣ ប្រការគឺ :

-**សីល** គឺការសង្រួមកាយ វាចា ចិត្តដោយប្រពៃមានសីល ៥ សីល ៨ សីល ១០ និងអតិរេកសីល ឬចតុប្បារិសុទ្ធិសីល

-**សមាធិ** គឺការអប់រំចិត្តឱ្យស្ងប់រំងាប់តាមរយៈចម្រើនកម្មដ្ឋាន

-**បញ្ញា** គឺការពិចារណាបានឃើញ និងកំណត់ដឹងច្បាស់នូវភាពអនិច្ចំ ទុក្ខំ.អនត្តា ក្នុងសង្ខារធម៌ទាំងឡាយ គឺវិបស្សនាបញ្ញាដែលជាមូលដ្ឋានគ្រឹះនាំឱ្យសម្រេចមគ្គផលជាន់ខ្ពស់

**សំនួរទី ១០. តើសទ្ធាបទគឺជាអ្វី ?**

**ចម្លើយ** **សទ្ធាបទ** គឺវិន័យបញ្ញត្តិដែលព្រះសម្មាសម្ពុទ្ធទ្រង់ហាមដោយលើកឡើងជាប្រការ ឬមាត្រាមួយៗហៅ "សិក្ខាបទ" ។ ក្នុងបាតិមោក្ខសំវរសីលមានសិក្ខាបទទាំង

អស់ 227 គឺ បារាជិក ៤ សង្ឃាទិសេស 13 អនិយតៈ 2 និស្សគ្គិយបាចិត្តិយ : 30 សុទ្ធិកបាចិត្តិយ : 92 បាដិទេសនីយៈ 4 សេក្ខិយវត្ត 75 រួមទាំងអធិករណសមថៈ 7 ត្រូវជា 227

**សំនួរទី ១១. តើឥន្ទ្រីយសំវរសីលគឺជាអ្វី ?**

**ចម្លើយ** គឺការសង្រួមឥរិយាបថ ឬ សង្រួមអាយតនៈខាងក្នុងទាំង ៦ មានភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្ត ។

**សំនួរទី ១២. តើបច្ច័យសន្និស្សិតសីលគឺជាអ្វី ?**

**ចម្លើយ** គឺការធ្វើឱ្យបរិសុទ្ធតាមរយៈការប្រើប្រាស់បច្ច័យទាំង 4 មានចីវរ បិណ្ឌបាត សេនាសនៈ និង គិលានភេសជ្ជៈ ដោយពិចារណាជាមុនសិន មុននឹងប្រើប្រាស់បច្ច័យទាំងនេះ ។

**សំនួរទី ១៣. តើតួនាទីរបស់ភិក្ខុនីក្នុងព្រះពុទ្ធសាសនាមានអ្វីខ្លះ ?**

**ចម្លើយ** គឺការសិក្សា និង ការគោរពប្រតិបត្តិព្រះធម៌ព្រះវិន័យដែល ព្រះពុទ្ធទ្រង់បានបញ្ញត្តិទុកមក ទ្រទ្រង់លទ្ធិព្រះពុទ្ធសាសនា ឱ្យបានគង់វង្សយូរអង្វែង ។

# ជំ.2 មេរៀនទី៥ ព្រះពុទ្ធសាសនាមហាយាន

## I ចូរបំពេញល្បះឱ្យបានត្រឹមត្រូវ :

១. គ្រូអាចារ្យនៅក្នុងនិកាយមហាយាន បានបង្កើតគម្ពីរប្លែកពីគម្ពីរព្រះត្រៃបិដកដូចជា គម្ពីរ*សទ្ធម្មបុណ្ឌរីក* គម្ពីរ*លង្កាវតារសូត្រ*ជាដើម ហើយចារឹកជាភាសា*សំស្ក្រឹត* ទាំងអស់ ។

## II. សំនួរត្រិះរិះ

**សំនួរទី ១.** ចូរពណ៌នាលក្ខណៈនៃព្រះពុទ្ធសាសនាមហាយាន ?

**ចម្លើយ** លក្ខណៈនៃព្រះពុទ្ធសាសនាមហាយាន

- វិន័យធូរស្រាល
- គោរពព្រះពោធិសត្វឥអង្គពិសេសព្រះពោធិសត្វលោកេស្វរៈ ឬ លោកិតេស្វរៈ
- យានធំផ្ទុកសត្វលោកបានច្រើនឆ្ពោះទៅកាន់ឋានសួគ៌
- គោរពតាមអាចារ្យនិមួយៗគ១គ្នា (លទ្ធិអាចរិយវាទ)

- សិក្សាតាមគម្ពីរសទ្ធម្មបុណ្ឌរីក គម្ពីរលង្កាវតារសូត្រ ជាដើម ហើយចារឹកជាសំស្ក្រឹត ។

**សំនួរទី ២.** ចូររៀបរាប់ពីអត្ថិភាពរបស់ព្រះពុទ្ធសាសនាមហាយានក្នុងសង្គមខ្មែរ ?

**ចម្លើយ** ព្រះពុទ្ធសាសនានិកាយមហាយានមានអត្ថិភាព នៅក្នុងសង្គមខ្មែរតាមសម័យកាលជាបន្តបន្ទាប់ដូចខាងក្រោម :

- ក្នុងរជ្ជកាលព្រះបាទកនិស្កៈនៅប្រទេសឥណ្ឌា ព្រះពុទ្ធសាសនាមហាយានត្រូវផ្សព្វផ្សាយចេញជាពីរផ្លូវ គឺផ្លូវអាស៊ីកណ្ដាល និងចិនដែលផ្លូវនេះឧបត្ថម្ភដោយព្រះអង្គផ្ទាល់ ឯផ្លូវមួយទៀតឆ្ពោះទៅអាស៊ីអាគ្នេយ៍មិនមានអ្នកឧបត្ថម្ភទេ គឺផ្សព្វផ្សាយតាមសទ្ធារៀងៗខ្លួន និងតាមពួកអ្នកជំនួញ ។
- នៅសម័យបុរេប្រវត្តិសម័យនគរភ្នំ ប្រទេសខ្មែរយើងមិនទាន់មានលទ្ធិសាសនាមហាយាននៅឡើយទេ ។ នៅសម័យទាំងពីរ នេះ ប្រទេសខ្មែរបានទទួលយកវប្បធម៌ពុទ្ធសាសនាហីនយានសាសនាព្រាហ្មណ៍ ឬ ព្រហ្មញ្ញសាសនា ។ លទ្ធិព្រាហ្មញ្ញបាននាំចូលដោយ ព្រះបាទកៅ

ណ្ឌិន្យ ឬ ហ៊ុន ទៀន បន្ទាប់ពីបានរៀបអភិសេកជាមួយព្រះនាងលីវយី ហើយបានប្រកាសតាំងខ្លួនជាស្ដេច ព្រមទាំងរៀបចំទឹកដីខ្មែរតាមទស្សនៈឥណ្ឌា ។

ទោះបីជាមានការនាំចូលព្រហ្មញ្ញសាសនាក៏ដោយ ក៏សាសនាថេរវាទនៅតែមានការរីកចម្រើនដែរនៅក្នុងសម័យកាលនោះ ។

- នៅចុងសតវត្សទី ៧ នៃសម័យចេនឡា ព្រះពុទ្ធសាសនាមហាយានបានត្រូវនាំចូលមកផ្សព្វផ្សាយនៅប្រទេសខ្មែរ ហើយមានការលូតលាស់រហូតដល់សតវត្សទី ១៣ ដែលគេបានប្រទះឃើញមានរូបដិមាពោធិសត្វលោកេស្វរៈនៅក្រមួនស (កម្ពុជាក្រោម) និង នៅប្រាសាទតាកៀម (ខេត្តសៀមរាប) ។
- នៅចុងសតវត្សទី ៩ នៃសម័យមហានគរ ព្រះបាទសោវ័ន្នទី ១ បានឡើងសោយរាជ្យក្នុង គ.ស ៨៨៩ ហើយទ្រង់បានលើករាជ ធានីទៅនៅក្រុងយសោធបុរៈ គឺអង្គរធំសព្វថ្ងៃ ។ ព្រះអង្គកាន់ព្រាហ្មណ៍សាសនា និយមព្រះឥស្វរជាធំ ប៉ុន្តែព្រះអង្គបានសាងអាស្រមជាច្រើនកន្លែងសម្រាប់ឱ្យអ្នកកាន់សាសនាទាំងបីប្រភេទគឺ សាសនាហីនយាន ពុទ្ធសាសនាមហាយាន និងព្រាហ្មណ៍សាសនា

ព្រះអង្គ ទ្រង់បានទទួលស្គាល់ពុទ្ធសាសនាមហាយាន ជាផ្លូវការមុនដំបូងបង្អស់ក្នុងប្រវត្តិសាស្ត្រខ្មែរ ។

**<u>សំនួរទី ៣.</u> តើប្រជាជនខ្មែរភាគច្រើនគោរពពុទ្ធសាសនាមហាយាន ឬហីនយាន ? ព្រោះអ្វី ?**

**<u>ចម្លើយ</u>** ប្រជាជនខ្មែរភាគច្រើនគោរពពុទ្ធសាសនាហីនយាន ឬ ព្រះពុទ្ធសាសនាថេរវាទតាំងពីពុទ្ធសតវត្សទី៣ នៃពុទ្ធសករាជមកម្ល៉េះ ព្រោះព្រះពុទ្ធសាសនាថេរវាទនេះអាចឱ្យពួកគេជាទីពឹងពាក់ និងជឿជាក់ថាអាចនាំពួកគេទៅរកសេចក្តីសុខបាន ។

**<u>សំនួរទី ៤.</u> តើព្រះសង្ឃក្នុងសាសនាមហាយានមានលក្ខណៈដូចម្តេច ?**

**<u>ចម្លើយ</u>** ព្រះសង្ឃក្នុងសាសនាមហាយានមានលក្ខណៈ ដូចជា :

- ស្លៀកពាក់ដណ្តប់សំពត់ពណ៌លឿង
- មានតំណមមិនឆាន់គ្រឿង ស្រវឹង មិនសម្លាប់សត្វ មិនលួច មិនកុហក.. ។

**<u>សំនួរទី ៥.</u> តើនិកាយហីនយាន និងមហាយានមាន**

**លក្ខណៈខុសគ្នាដូចម្ដេចខ្លះ ?**

✍ **ចម្លើយ** លក្ខណៈខុសគ្នានៃ *និកាយហីនយាន* និង *មហាយាន* :

| **និកាយហីនយាន** | **និកាយមហាយាន** |
|---|---|
| - យានតូចផ្ទុកសត្វលោកបានតិច ។ | - យានធំផ្ទុកសត្វលោកបានច្រើន។ |
| - ឆ្ពោះទៅរកព្រះនិព្វាន | - ឆ្ពោះទៅកាន់ឋានសួគ៌ ។ |
| - គោរពព្រះពុទ្ធសមណគោតមតែ ១ អង្គគត់។ | - គោរពព្រះពោធិសត្វ៧អង្គ ពិសេសព្រះពោធិសត្វលោកកេស្វរៈ ។ |
| - គោរពគម្ពីរព្រះត្រៃបិដកតាមពុទ្ធោវាទ ។ | - គោរពតាមអាចារ្យនិមួយៗតៗគ្នា (លទ្ធិអាចរិយវាទ) |
| - វិន័យតឹងតែង ។ | - វិន័យធូរស្រាល ។ |

**សំនួរទី ៦.** **តើនៅក្នុងរជ្ជកាលស្ដេចអង្គណាដែលធ្វើឱ្យពុទ្ធសាសនាមហាយានរីកចម្រើនខ្លាំង ? ព្រោះអ្វី?**

✍ **ចម្លើយ** នៅសតវត្សទី ១៣ ព្រះពុទ្ធសាសនាមានការរីកចម្រើនលូតលាស់ជាងព្រាហ្មណ៍សាសនា ។ ព្រះបាទ **ជ័យវរ្ម័នទី ៧** ជាសាសនិក ដ៏ឆ្នើម ទ្រង់កាន់ព្រះពុទ្ធ

សាសនាមហាយាន គោរពព្រះពោធិសត្វលោកេស្វរៈ និងប្រាជ្ញាបារមិតា ។ ព្រះអង្គទ្រង់បានផ្លាស់ប្តូរប្រពៃណី ដែលធ្លាប់គោរពទេវរាជមកគោរពពុទ្ធរាជវិញ ។

**សំនួរទី ៧. តើព្រះពុទ្ធសាសនាមហាយានបានសាបរលាបពីទឹកដីមហានគរនៅពេលណា ?**

**ចម្លើយ** មកដល់ចុងសតវត្សទី ១៣ ព្រះពុទ្ធសាសនាមហាយានបានសាបរលាបពីទឹកដីមហានគរ និងមកដល់សតវត្សទី ១៤ ព្រាហ្មណ៍ សាសនាក៏បាត់បង់ថែមទៀត គឺនៅសល់តែពិធីបុណ្យខ្លះៗ ក្នុងរាជវាំងប៉ុណ្ណោះ ។ ចំណែកលើពុទ្ធសាសនាថេរវាទ ឬហីនយានក៏បានលូតលាស់ ដុះដាលរីកចម្រើនយ៉ាងខ្លាំងចាប់ពីចុងសតវត្សទី ១៣ រហូតមកដល់បច្ចុប្បន្ន ។

**សំនួរទី ៨. តើសាសានមហាយានចិនមាននិកាយអ្វីខ្លះ ?**

**ចម្លើយ** សាសានមហាយានចិនមាននិកាយ :

- និកាយមីឡឺ ឬព្រះសិអារ្យមេត្រី
- និកាយព្រះនាងគង់ស៊ីអ៊ឹម
- និកាយខុងម៉ឹង ។

**សំនួរទី ៩. ហេតុអ្វីបានជានិកាយមហាយានគោរពព្រះពោធិសត្វជាងព្រះពុទ្ធ ? តើពុទ្ធសាសនាមហាយាននៅក្នុងសង្គមខ្មែរកាលពីអតីតកាល គោរពព្រះពោធិសត្វអ្វីខ្លះ ?**

**ចម្លើយ** ព្រះពុទ្ធសាសនានិកាយមហាយានគោរពព្រះពោធិសត្វជាងព្រះពុទ្ធ ព្រោះពួកគេយល់ថាព្រះពុទ្ធចូលបរិព្វានហើយ មិនអាចទៅជួយឃិតយោង ឬដឹកនាំមនុស្សឱ្យទៅនិព្វានបានទេ មានតែព្រះពោធិសត្វទេទើបជួយបាន ដោយសារព្រះពោធិសត្វមិនទាន់បានត្រាស់ មិនទាន់ចូលនិព្វាន ។

ពុទ្ធសាសនាមហាយាននៅក្នុងសង្គមខ្មែរកាលពីអតីតកាល គោរពព្រះពោធិសត្វ ដូចជា : **លោកេស្វរៈ ឬ លោកិតេស្វរៈ មញ្ចុស្រី មៃត្រេយ ប្រាជ្ញាបារមិតា** ឯសាសនាមហាយាន*ចិន វៀតណាម* គោរព**ព្រះមីឡឺ ឬ ព្រះសិអារ្យមេត្រី ព្រះនាងគង់ស៊ីអ៊ីម** ។ ល។

# ៩.២ មេរៀនទី៦ : ភាពជាបព្វជិតក្នុងសាសនាគ្រិស្ត

## I. សំនួរត្រិះរិះ

☛ <u>សំនួរទី ១.</u> តើសាសនាគ្រិស្តមានដើមកំណើតនៅប្រទេសណា ?

✍ <u>ចម្លើយ</u> គ្រិស្តសាសនា មានដើមកំណើតនៅស៊ីរ (អ៊ីស្រាអែល )មានគម្ពីរប៊ីប ។

☛ <u>សំនួរទី ២.</u> តើសាសនាគ្រិស្តមានអត្ថិភាពនៅក្នុងប្រទេសកម្ពុជាតាំងពីពេលណាមក ?

✍ <u>ចម្លើយ</u> សាសនាគ្រិស្តមានអត្ថិភាពនៅក្នុងប្រទេសកម្ពុជា តាំងពីក្នុងកំឡុងសតវត្សទី ១៦ នៃ គ.ស តាមរយៈបេសកកម្មកាតូលិកព័រទុយហ្គាល់ និង អេស្ប៉ាញ ។

☛ <u>សំនួរទី ៣.</u> ចូររៀបរាប់ពីការបួស និងអត្ថន័យនៃការបួសនៅក្នុងសាសនាគ្រិស្ត ?

✍ <u>ចម្លើយ</u> ការបួស និងអត្ថន័យនៃការបួសនៅក្នុងសាសនាគ្រិស្ត :

**ក. ការបួស :** ដើម្បីបួសជាបូជាចារ្យនៅក្នុងនិកាយរ៉ូម៉ាំង

កាតូលិក បេក្ខសមណៈត្រូវមានអាយុយ៉ាងតិច ២៥ ឆ្នាំឡើងទៅ ហើយត្រូវតែទៅសិក្សាមុខវិជ្ជាទេវវិទ្យានៅមហាវិទ្យាល័យ ដែលមានរយៈពេល ៤ ឆ្នាំ ។

**ខ. អត្ថន័យ :** ដើម្បីជួយសង្គ្រោះ និង ដឹកនាំមនុស្សទៅរកព្រះបិតា ដែលជាអ្នកបង្កើតលោក ។

**<u>សំនួរទី ៤.</u> ហេតុអ្វីបានជានិកាយប្រូតេស្តង់ផ្តាច់ខ្លួនចេញពីនិកាយរ៉ូម៉ាំងកាតូលិក ?**

**<u>ចម្លើយ</u>** និកាយប្រូតេស្តង់មានន័យថា និកាយកែទម្រង់ ។ និកាយប្រូតេស្តង់ គឺជានិកាយមួយនៃសាសនាគ្រិស្តដែលបែកចេញពីនិកាយ រ៉ូម៉ាំងកាតូលិកក្នុងកំឡុង ព.ស២០៦០ គ.ស ១៥១៧ ដោយសារបព្វជិតជនជាតិ អាល្លឺម៉ង់ម្នាក់ឈ្មោះ លូថេរ (Luther) ជាអាចារ្យសាលាវិទ្យាល័យវត្តមួយនៅប្រទេសអាល្លឺម៉ង់ ។

មូលហេតុដែលនាំឱ្យមាននិកាយប្រូតេស្តង់នេះកើតឡើងមក ពីទោសនៃការប្រព្រឹត្តខុសប្រាសចាកពីគម្ពីរប៊ីបនៃគណៈសង្ឃជាអាទិ៍មានសម្តេចសង្ឃនៃក្រុងរ៉ូមជាដើម ។

**<u>សំនួរទី ៥.</u> តើអ្នកត្រូវធ្វើអ្វីខ្លះ ដើម្បីបង្ហាញថា**

អ្នកស្រឡាញ់មនុស្សជទែដូចស្រឡាញ់ខ្លួនឯង ?

**ចម្លើយ** ដើម្បីបង្ហាញថាខ្ញុំស្រឡាញ់ មនុស្សជទៃ ដូចស្រឡាញ់ខ្លួនឯងគឺ ខ្ញុំត្រូវ ចេះអត់ឱន យោគយល់អធ្យាស្រ័យ ចំពោះមនុស្សទាំងឡាយដែលនៅជុំវិញខ្លួនខ្ញុំ ។

**សំនួរទី ៦.** **តើគ្រិស្តសាសនាបានចូលរួមចំណែកដូចម្តេចខ្លះ ក្នុងការកសាងសង្គមសព្វថ្ងៃ ?**

**ចម្លើយ** គ្រិស្តសាសនាបានចូលរួមចំណែក ក្នុងការកសាងសង្គមសព្វថ្ងៃ ដូចជា :

- កសាងបាននូវធនធានមនុស្សល្អក្នុងសង្គម
- កសាងគ្រឹះស្ថានសិក្សា ឬ សាលាសាសនា
- ជួយអប់រំកូនក្មេងអនាថា ពិការ ដោយផ្តល់ជាថវិកា ឬ ផ្តល់វិជ្ជាជីវៈផ្សេងៗដល់ពួកគេជាដើម ។ល។

**សំនួរទី ៧.** **តើនៅក្នុងជំនឿ និងជីវភាពអ្នកបួសក្នុងសាសនាគ្រិស្ត គ្រិស្តបរិស័ទត្រូវប្រកាន់ខ្ជាប់ក្រឹត្យវិន័យ ១០ ប្រការដូចម្តេច ?**

**ចម្លើយ** ក្រឹត្យវិន័យទាំង ១០ប្រការមាន :

១.ត្រូវគោរពបូជាព្រះម្ចាស់សួគ៌ ២.មិនត្រូវផិតក្បត់

***** ***** 

៣.មិនត្រូវធ្លាក់រូបសម្រាប់ក្រាបសំពះសច្បស្បែ

៤.មិនត្រូវលួចយកទ្រព្យអ្នកដទៃ

៥.ត្រូវនឹកចាំពីថ្ងៃឈប់សម្រាក

៦.មិនត្រូវជាទីបន្ទាល់ក្លែងឱ្យសោះ

៧.ត្រូវគោរពប្រតិបត្តិឪពុកម្តាយ

៨.មិនត្រូវលោភលន់

៩.មិនត្រូវសម្លាប់មនុស្សឱ្យសោះ

១០.មិនត្រូវចេញព្រះនាមព្រះជាអសារឥតការឡើយ ។



# ៥.២ មេរៀនទី៧ : ភាពជាបព្វជិតក្នុងសាសនាឥស្លាម

## I. សំណួរត្រិះរិះ

**សំនួរទី ១. តើពាក្យឥស្លាមក្នុងភាសាអារ៉ាប់មានន័យដូចម្តេច ?**

**ចម្លើយ** ពាក្យឥស្លាមក្នុងភាសាអារ៉ាប់មានន័យថា ការគោរព ការស្ញូតបូត ការទទួលស្តាប់បង្គាប់ ការអោនលំទោន ការចាកផុតពីគ្រោះទាំងឡាយ ។

**សំនួរទី ២. ចូរបង្ហាញអំពីមូលហេតុនៃការកកើតសាសនាឥស្លាមនៅក្នុងប្រទេសកម្ពុជា ។**

**ចម្លើយ** មូលហេតុនៃការកកើតសាសនាឥស្លាមនៅក្នុងប្រទេសកម្ពុជា ។

សាសនាឥស្លាម បានចាប់បដិសន្ធិនៅក្នុងសង្គមខ្មែរ តាំងពីសតវត្សទី ១៥ មកម្ល៉េះ ដោយសារ :

- ដាយវៀត បានចូលទៅកាន់កាប់ និងតាំងទីលំនៅលើទឹកដីចាម ហើយបានសម្លាប់ និង បណ្តេញប្រជាជនចាមឱ្យចាកចោលមាតុភូមិរបស់ខ្លួន ។ ដាយវៀតបានច្បាំងវាយ

ដណ្តើមយកប្រទេសចាម្ប៉ានៅចុងសតវត្សទី ១៥ ។ ប្រជាជនចាមដែលធ្វើសង្គ្រាមចាញ់ដាយវៀត ខ្លះគាំទ្រសត្រូវ ខ្លះរត់ចូលព្រៃ ខ្លះចុះទូករត់ទៅនៅភីលីពីន ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ហើយខ្លះទៀតរត់ចូលមកសុំជ្រកកោននៅកម្ពុជា ។ នៅឆ្នាំ ១៦៩២ ក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី ៤ ជនជាតិចាម ៥ ០០០នាក់ដែលដាយវៀតបណ្តេញចេញពីមាតុភូមិបានមកសុំសិទ្ធិជ្រកកោននៅកម្ពុជា ។

- អ្នកជំនួញជនជាតិជ្វា ធ្វើដំណើរមកពីកោះជ្វាក្នុងប្រទេសឥណ្ឌូនេស៊ី ។ ពួកឈ្មួញទាំងនោះសុទ្ធតែជាបុរសដែលធ្វើដំណើរតាមសមុទ្រ រួចក៏បានរៀបការជាមួយស្ត្រីខ្មែរ និងរស់នៅលើទឹកដីខ្មែរ កើតបានជាកូនពូនជាចៅតរៀងមក ហើយនាំយកសាសនាមកជាមួយផង ។

**<u>សំនួរទី ៣.</u> ចូររៀបរាប់ពីការបួសក្នុងសាសនាឥស្លាម និងអត្ថន័យនៃការបួស ។**

<u>ចម្លើយ</u> - **ការបួសក្នុងសាសានាឥស្លាម** : សាសនាឥស្លាមពុំមានអ្នកបួសជាព្រះសង្ឃដូចសាសនាដទៃទេ ។ ឥស្លាមសាសនិកទាំងអស់ដែលជាអ្នកបួសនៅខែ "**រ៉ាម៉ាដន** " គឺមានអាយុចាប់ពី ១៥ ឆ្នាំឡើងទៅ ។

ការបួសក្នុងសាសនាឥស្លាម គឺជាការតម មិនបរិភោគចំណីអាហារ មិនផឹក មិនមើលគ្នាក្នុងផ្លូវស្នេហា ដោយចាប់គិតពីព្រលឹមស្រាងៗអរុណរះរហូតដល់ថ្ងៃលិច និងសូត្រធម៌ថ្វាយបង្គំដោយបែរមុខទៅរកទីក្រុងម៉ាក្កា ប្រកបដោយការគោរពប្រណិប័តន៍ចំពោះព្រះអល់ឡោះ ។

ពិធីបួសត្រូវបានចាប់ផ្ដើមឡើងនៅក្នុងពិធីបុណ្យរ៉ាម៉ាដនដែលមានរយៈពេលមួយខែជារៀងរាល់ឆ្នាំ ។ ពិធីបុណ្យរ៉ាម៉ាដនប្រព្រឹត្តឡើងក្នុងខែរ៉ាម៉ាដន ត្រូវនឹងខែច័ន្ទគតិ ទី៩ នៃប្រតិទិនឥស្លាមដោយពេលនេះសាសនិកឥស្លាមទាំងអស់ត្រូវតមពេញមួយខែក្នុងកំឡុងពេលថ្ងៃលើកលែងតែស្ត្រីមានគភ៌ មនុស្សមានជម្ងឺ និងចាស់ជរា អាចបរិភោគបាន ។

- អត្ថន័យនៃការបួស :

+ ការធ្វើតាម គោរពតាមបញ្ញារបស់ព្រះអល់ឡោះ ។

+ ការធ្វើឱ្យអ្នកបួសទាំងអស់បានដឹងពីរស់ជាតិនៃជីវិតរបស់អ្នកក្រីក្រអត់អាហារបរិភោគ ដើម្បីឱ្យអ្នកបួសចេះជួយគ្នា ចេះរំលែកគ្នាដើម្បីរស់ ។

+ ការទទួលផលបុណ្យទៅបរិលោក ព្រោះថានៅក្នុងឋានសួគ៌នៃសាសនាឥស្លាម មានប្រកទ្វាមួយឈ្មោះរ៉យ្យ៉ាន។

អ្នកដែលបានបួសនឹងបានទៅកាន់ឋានសួគ៌តាមច្រកទ្វា នោះ ។

+ ផ្នែកសតិអារម្មណ៍ ធ្វើឱ្យអ្នកបួសមានទម្លាប់ពង្រឹងគោលជំហរក្នុងការអត់ធ្មត់ ការពារ និងទប់ស្កាត់រាល់ការប្រព្រឹត្តិបទល្មើសផ្សេងៗ និងធ្វើឱ្យគេមានថាមពលខ្លាំងក្លាតាមរយៈការជឿ ការគោរពខ្លាច និងដើរតាមគន្លងធម៌របស់ព្រះអល់ឡោះ ។

+ ផ្នែកសង្គម ធ្វើឱ្យអ្នកបួសមានទម្លាប់គោរពច្បាប់ មានសាមគ្គីភាព ស្រឡាញ់យុត្តិធម៌ សមធម៌ មានសពេ្វតនាអានិតអាសូរ មានសុជីវធម៌ ជាពិសេសការពារសង្គមពីអំពើអាក្រក់ និងការខឹលខូច ។

+ សុខភាពឱ្យអ្នកបួសមានរៀងកាយមាំមួន សម្អាតកាកសំណល់អាក្រក់ចេញពីសរីរាង្គកាយដូចជា ក្នុងពោះវៀនក្រពះជាដើម ជាពិសេសកាត់បន្ថយសារធាតុខ្លាញ់ពីសរសៃឈាម និងសំបកខួរក្បាល ។

**សំនួរទី ៤.** តើអ្វីភាពខុសគ្នារវាងនិកាយស៊ុននីត និងនិកាយស៊ីអ៊ីត ?

**ចម្លើយ** ភាពខុសគ្នារវាងនិកាយស៊ុននីត និងនិកាយស៊ីអ៊ីត

**ក. និកាយស៊ុននីត** : គឺជានិកាយធំជាងគេក្នុងសាសនាឥស្លាម ។ ក្រុមនេះមានបំណងជ្រើសរើសមេដឹកនាំដែលជាអ្នកចេះដឹងខាងសាសនាឱ្យជំនួសមហាម៉ត ទោះបីអ្នកនោះមិនមែនជាសាច់ញាតិរបស់មហាម៉ត់ក៏ដោយ ។ សាសនិកឥស្លាមក្នុងនិកាយស៊ុននីត គោរពមេដឹកនាំដែលគេបានជ្រើសរើសឡើងទៅតាមក្រុមរបស់ពួកគេ ហៅថា **អ៊ីម៉ាំ** ។

**ខ. និកាយស៊ីអ៊ីត** : សាសនិកឥស្លាមក្នុងនិកាយស៊ីអ៊ីតមានជំនឿនិងទទួលស្គាល់ថាមានតែអាលី ដែលជាក្មួយរបស់មហាម៉ត់ត្រូវបានចាត់តាំង និងបញ្ជូនមកធ្វើជាព្យាការី (អ្នកនាំសារ) ដោយសារគេគិតថាម៉ះនតែមនុស្សក្នុងត្រកូលនេះទេតើបមានអំណាចទទួលមរតកពីមហាម៉តបាន ។ ក្នុងនិកាយស៊ីអ៊ីតមានសហធម្មិកដ៏មានអំណាចឬឥទ្ធិពលដែលត្រូវបានបង្កើតចាត់តាំងឡើងដោយព្រះជាម្ចាស់និងមានងារជា**អ៊ីម៉ាំ** មុឡា ឬ អាយ៉ាតុឡា ហើយមានឋានៈដូចជា សម្តេចសង្ឃ**ប៉ាប** ដែរ ។

<u>សំនួរទី ៥.</u> តើអ្នកយល់ដូចម្តេចចំពោះអ្នកប្រតិបត្តិសាសនាឥស្លាម ?

**ចម្លើយ** ចំពោះអ្នកប្រតិបត្តិសាសនាឥស្លាមខ្ញុំគិតថាត្រឹមត្រូវដែរ ហើយនេះជាសេរីភាពខាងជំនឿសាសនារបស់បុគ្គលម្នាក់ៗ ។ សាសនានិមួយៗតែងមានការអប់រំផ្សេងៗគ្នា ប៉ុន្តែផ្តោតទៅលើអំពើល្អជានិច្ច ។

**សំនួរទី ៦.** **ចូរសិក្សាស្រាវជ្រាវអំពីការអប់រំសីលធម៌របស់សាសនាឥស្លាម ?**

**ចម្លើយ** ការអប់រំសីលធម៌របស់សាសនាឥស្លាម :

- កុំឱ្យលួចទ្រព្យសម្បត្តិ ឬ កេងប្រវ័ញ្ច បោកបញ្ឆោតគេ
- កុំមុសាមួលបង្កាច់ តិះដៀល ព្យាបាទ ឬ ពោលពាក្យកុហក់គេឱ្យសោះ
- កុំលួចប្រពន្ធគេ
- កុំបរិភោគសាច់ជ្រូក
- កុំសម្លាប់ជីវិតមនុស្សល្អ ។

# ជ.2 មេរៀនទី៨ : ភាពជាបព្វជិតក្នុងសាសនាតៅ

## I. សំនួរត្រិះរិះ

**សំនួរទី ១.** តើសាសនាតៅ ជាសាសនារបស់ជនជាតិណា ? តើអ្នកណាជាអ្នកផ្ដួចផ្ដើមបង្កើតសាសនានេះ? ចូររៀបរាប់ ?

**ចម្លើយ** សាសនាតៅ ជាសាសនារបស់ជនជាតិ**ចិន** ។ អ្នកផ្ដួចផ្ដើមបង្កើតសាសនានេះគឺ ដោយមហាបុរសជនជាតិចិនមួយរូបមាននាមថា **ឡៅស៊ី** ។ សាសនានេះបានកើតឡើងនៅប្រទេសចិនក្នុងសម័យបន្តបន្ទាប់គ្នានឹងសម័យពុទ្ធកាលដែរ គឺប្រហែលនៅសតវត្សទី ៦ មុន គ.ស ។ អ្នកបង្កើតសាសនានេះមាននាមថា**ឡៅស៊ី** ដែលមានន័យថា គ្រូចាស់ ឬលោកម្ចាស់ ។

**សំនួរទី ២.** តើពួកតៅនិយមមានជំនឿលើលទ្ធិតៅដូចម្ដេចខ្លះ ?

**ចម្លើយ** លទ្ធិតៅ ជាលទ្ធិធម្មជាតិ ជឿធម្មជាតិ ឬជាធម្មជាតិ ឬជាលទ្ធិដែលមានទំនាក់ទំនងជាមួយធម្មជាតិ ។ តាមទ្រឹស្ដីលទ្ធិនេះលើកតៅ ជាអ្នកកសាងលោក ។ ពួកតៅនិយម

មានជំនឿថា តៅឱបក្រសោបអ្វីទាំងអស់ដែលកើតមាន នៅក្នុងលោកនេះ ពិសេសគឺការចាប់ផ្ដើមនៃចក្រវាឡ និង ការកើតនៃអព្ភូតហេតុ ដែលបានប្រមូលផ្ដុំអ្វីៗទាំងអស់ឱ្យ មានជីវិត ។ ឡៅស៊ឺបានកំណត់ទុកថា សព្វវត្ថុក្នុងលោកនេះ សុទ្ធតែកើតមកពីតៅទាំងអស់ ។ មនុស្សដែលកើតមកក្នុង លោកយើងនេះ គ្រាន់តែជាចំណែកមួយនៃតៅប៉ុណ្ណោះ ដូចគ្នាទៅនឹងវត្ថុឯទៀតដែរ គឺកើតឡើងពីតៅ ។

**សំនួរទី ៣. តើការអប់រំទូន្មានក្នុងសាសនាតៅមានអ្វី ខ្លះ ?**

**ចម្លើយ** ការអប់រំទូន្មានក្នុងសាសនាតៅមាន :

- អ្នកណាស្គាល់អ្នកដទៃ អ្នកនោះជាបណ្ឌិត តែអ្នកណាស្គាល់ ខ្លួនឯង អ្នកនោះជាអ្នកភ្ញាក់រលឹកហើយ ។
- អ្នកណាឈ្នះអ្នកដទៃ អ្នកនោះជាមនុស្សពូកែ តែអ្នកណា ឈ្នះខ្លួនឯង អ្នកនោះជាមនុស្សមានតេជះ ។
- អ្នកណាស្គាល់ប្រមាណ អ្នកនោះជាមនុស្សខ្ជាប់ខ្ជួន ។
- អ្នកណាកាលបើស្លាប់ហើយ នៅមានគេរំលឹកដល់ អ្នកនោះ ឈ្មោះថាគង់នៅឋិតថេររហូតដល់អាយុមេឃដី ។
- មិនមានបាបអ្វីធ្ងន់ធ្ងរស្មើនឹងបណ្ដោយខ្លួន ឱ្យធ្លាក់ទៅតាម សេចក្ដីប្រាថ្នាក្ដៅក្រហាយ មិនមានទុក្ខអ្វីធំជាងសេចក្ដីមិន

សណ្ដោស មិនមានវិបត្តិអ្វីអំណាចខ្លាំងក្រៃលែងជាងសេចក្ដីលោភ ។ ហេតុដូចនេះភាពជាអ្នកសណ្ដោសត្រូវស្គាល់ប្រមាណ ទើបជាសេចក្ដីល្អមដែលតាំងនៅវហូតកល្បវសាន ។

- គប្បីធ្វើល្អតបចំពោះអ្នកធ្វើល្អក្ដី ឬអ្នកដែលធ្វើអាក្រក់ក្ដី បើបានធ្វើដូចនេះគ្រប់ៗគ្នាមនុស្សក៏នឹងធ្វើល្អដល់គ្នានឹងគ្នា។ គប្បីស្មោះត្រង់ចំពោះអ្នកត្រង់ ឬគប្បីស្មោះត្រង់ចំពោះអ្នកដែលវៀចបើបានធ្វើដូចនេះគ្រប់ៗគ្នា មនុស្សទាំងអស់ក៏មានការស្មោះត្រង់នឹងគ្នាទៅវិញទៅមក ។

**<u>សំនួរទី ៤.</u> តើអ្នកបួសក្នុងសាសនាតៅត្រូវប្រកាន់ខ្ជាប់ក្រឹត្យវិន័យ និងមានជីវភាពដូចម្ដេចខ្លះ ?**

**<u>ចម្លើយ</u>** អ្នកបួសក្នុងសាសនាតៅត្រូវប្រកាន់ខ្ជាប់ក្រឹតវិន័យជាមូលដ្ឋានទាំងប្រាំ ដែលមានលក្ខណៈស្រដៀងនិង សីលប្រាំ របស់គ្រហស្ថក្នុងពុទ្ធសាសនាដែរចំណែកឯកជីវភាពវិញអ្នកបួលហាមមិនឱ្យបរិភាគសាច់ មិនផឹកស្រា និយាយភូតកុហកជាដើម។

**<u>សំនួរទី ៥.</u> នៅក្នុងសាសនាតៅ គេបានអប់រំថា "អ្នកណាស្គាល់អ្នកដទៃ អ្នកនោះជាបណ្ឌិត តែអ្នកណាស្គាល់ខ្លួនឯង អ្នកនោះជាអ្នកឆ្លាក់លើកហើយ "**

**ចូរអ្នកបកស្រាយគំនិតអប់រំនេះ ៗ**

**ចម្លើយ** នៅក្នុងសាសនាតៅ គេបានអប់រំថា

"អ្នកណាស្គាល់អ្នកដទៃ អ្នកនោះជាបណ្ឌិត តែអ្នកណាស្គាល់ខ្លួនឯង អ្នកនោះជាអ្នកភ្ញាក់រលឹកហើយ "

ជាការពិតណាស់គ្រប់មនុស្សទាំងអស់តែងយល់ខ្លួនឯងជាជាងអ្នកដទៃ ដូច្នេះរាល់ទង្វើផ្សេងៗតែងធ្វើដោយមិនគិតពីអារម្មណ៍ ឬផលប៉ះពាល់ដល់អ្នកដទៃ ប៉ុន្តែប្រសិនបើមនុស្សណាម្នាក់ស្គាល់អ្នកដទៃច្បាស់ ទាំងចិត្ត ទាំងកាយ យល់ដឹងពីប្រវត្តិរស់គេ ប្រពៃណីទំនៀមទម្លាប់ និងតម្លៃខាងស្មារតី នោះអ្នកនោះ ធ្វើអ្វីៗតែងគិតពីអ្នកដទៃ គឺផលប៉ះពាល់អារម្មណ៍ ឬ សិទ្ធិរបស់គេ ដូច្នេះគេអាចរស់នៅជាមួយអ្នកដទៃបានដោយសុខដុម ដោយសន្តិភាព ។

រីឯអ្នកណាស្គាល់ខ្លួន អ្នកនោះជាអ្នកភ្ញាក់រលឹកហើយ គឺជាការពិតណាស់ ព្រោះមនុស្សយើងម្នាក់ៗមិនងាយនឹងស្គាល់ខ្លួនឯងច្បាស់ទេ តែងមើលរំលងពីកំហុសរបស់ខ្លួនជានិច្ច ច្រើនមើលឃើញពីកំហុសអ្នកដទៃ ដូច្នេះពេលមានកំហុសគឺ មិនងាយនឹងដឹង មិនងាយនឹងកែប្រែ និងភ្ញាក់រលឹកឡើងវិញណាស់ ។ ដូច្នេះប្រសិនបើនរណាម្នាក់ស្គាល់ខ្លួនឯងច្បាស់ចេះភ្ញាក់រលឹកខ្លួន នោះអ្នកនោះឈ្មោះថា ជាអ្នកភ្ញាក់រលឹកហើយ ។

# ជំ.2 មេរៀនទី៩ : ការប្រតិបត្តិសាសនាក្នុងសង្គមបច្ចុប្បន្ន

## I. សំនួរត្រិះរិះ

☛ <u>សំនួរទី ១.</u> តើសាសនា និងមនោគមវិជ្ជាមានទំនាក់ទំនងគ្នាដូចម្ដេចខ្លះ ?

✍ <u>ចម្លើយ</u> សាសនា និងមនោគវិជ្ជាមានទំនាក់ទំនងគ្នា តាមរយៈការតម្រង់ទិសដៅវប្បធម៌សង្គម។

☛ <u>សំនួរទី ២.</u> តើការអប់រំរបស់សាសនា បាននាំមនុស្សទាំងអស់ឱ្យឈានទៅរកសន្តិភាពដែរ ឬទេ ?

✍ <u>ចម្លើយ</u> ការអប់រំរបស់សាសនាបាននាំមនុស្សទាំងអស់ ឱ្យឈានទៅរកសន្តិភាពព្រោះ ការអប់រំរបស់សាសនា សង្កត់ធ្ងន់លើតម្លៃគុណធម៌ សុជីវធម៌ និងការអប់រំផ្លូវចិត្ត ដែលឈានទៅរកការយោគយល់គ្នា និង សន្តិភាព។

☛ <u>សំនួរទី ៣.</u> តើការចេះអធ្យាស្រ័យ និងការគោរពគ្នា នៅក្នុងសង្គមពហុសាសនា នាំមកនូវប្រយោជន៍អ្វីខ្លះ ដល់មនុស្ស សង្គមជាតិ និងពិភពលោក ?

✍ <u>ចម្លើយ</u> ការអធ្យាស្រ័យនិងការគោរពគ្នានៅក្នុងសង្គម

ពហុសាសនា នាំមកនូវអត្ថប្រយោជន៍ដល់មនុស្សសង្គម ជាតិ និងពិភពលោកគឺ បានដឹកនាំមនុស្សឱ្យឆ្ពោះទៅរក សន្តិភាព និងរស់នៅមានភាពសុខដុមរមនាជា ពិសេស អាចឱ្យសង្គមញជាតិរីកចម្រើនសន្តិភាព ។

**<u>សំនួរទី ៤.</u> ចូរអ្នកសរសេរអត្ថបទមួយលើប្រធានបទ " វិទ្យាសាស្ត្រគ្មានសាសនានាំឱ្យវិនាស " ។**

**<u>ចម្លើយ</u>** សំណេរអត្ថបទ " **វិទ្យាសាស្ត្រគ្មានសាសនា នាំឱ្យវិនាស** " ជាការពិតណាស់ សព្វថ្ងៃវិទ្យាសាស្ត្រ មានការរីកចម្រើនយ៉ាងខ្លាំង ដោយសារតែមានការរីក ចម្រើនខ្លាំងផ្នែកធនធានមនុស្សអ្នកបច្ចេកទេសនេះ ។ ហើយវិទ្យាសាស្ត្របានផ្តល់ផលប្រយោជន៍ជាច្រើន ដូចជាជួយសម្រួលការងារដល់មនុស្ស និងបង្កើតនូវ សម្ភារៈផ្សេងៗរហូតដល់បង្កើតសព្វាវុធប្រល័យលោក ទៀតផង។ ប៉ុន្តែសាសនាក៏ជាកត្តាសំខាន់មួយដែរ គឺបាន អប់រំមនុស្សឱ្យប្រព្រឹត្តតែអំពើល្អ អំពើដែលជាកុសល អំពើបុណ្យ និង ប្រកបដោយសីលធម៌ ។ ប្រសិនបើមាន តែវិទ្យាសាស្ត្រគ្មានសាសនា នោះ វានឹងធ្វើឱ្យមានភាព អសីលធម៌កើតមានឡើង ដូចជា ការបំផ្លាញមនុស្សជាតិ

បំផ្លាញពិភពលោកយើងទាំងមូល ព្រោះពួកគេមិនខ្លាច បាប មិនខ្លាចអ្វីទាំងអស់ ហើយម្យ៉ាងទៀតនៅពេលគ្មាន សាសនាមនុស្សមានការលោភលន់ពុំចេះចប់ពុំចេះហើយ។

ដូចនេះវិទ្យាសាស្ត្រ និងសាសនាត្រូវដើរទន្ទឹមគ្នា ប្រសិនបើវិទ្យាសាស្ត្រគ្មានសាសនា វានឹងបំផ្លាញមនុស្សជាតិ ហើយប្រសិនបើមានតែសាសនា គ្មានវិទ្យាសាស្ត្រវិញនោះ គឺមិនអាចរីកចម្រើនបានទេ ព្រោះគ្មានសម្ភារៈ គ្មានបច្ចេកវិទ្យា វានឹងធ្វើឱ្យងងឹត ។

**<u>សំនួរទី ៥.</u> ចូរសិក្សាស្រាវជ្រាវពីការអប់រំសីលធម៌ និងការប្រតិបត្តិសាសនានានា ដែលមាននៅក្នុងសហគមន៍របស់អ្នក ?**

**<u>ចម្លើយ</u>** តាមស្រាវជ្រាវពីការអប់រំសីលធម៌ និង ការប្រតិបត្តិសាសនានា ដែលមាននៅក្នុងសហគមន៍របស់ខ្ញុំ ពិតជាមានការអាធ្យាស្រ័យ និង គោរពគ្នាទៅវិញទៅមក ដែលនេះជា កត្តាដែលនាំឱ្យសហគមន៍របស់ខ្ញុំមានការរីកចម្រើនជាខ្លាំង និង នាំមកនូវការឱ្យតម្លៃនៃការគោពស'សនា ប្រពៃណីទំនៀមទំលាប់របស់គេរៀងៗខ្លួន ។

# ជ.2 មេរៀនទី១០ : គុណវិបត្តិនៃគ្រឿងញៀន

## I. សំនួរឮត្រិះរិះ

**សំនួរទី ១.** ដូចម្ដេចហៅថាគ្រឿងញៀន ? តើគ្រឿងញៀនមានប្រភេទអ្វីខ្លះ ?

**ចម្លើយ** **ក-គ្រឿងញៀន** ជាសារធាតុទាំងឡាយណាដែលបានចូលទៅក្នុងរាងកាយ ហើយធ្វើឱ្យផ្លាស់ប្ដូរមុខងារដំណើរការនៃរាងកាយមនុស្ស ។

ខ- ប្រភេទសារធាតុញៀនមាន បារី ស្រា កាហ្វេ កញ្ឆា អាភៀន ថ្នាំបាញ់ ការ ថ្នាំជក់ ថ្នាំបំបាត់ការឈឺចាប់ ថ្នាំបាយបាន ថ្នាំងងុយដេក អ៊ិស្រ្តាស៊ី ឬថ្នាំគ្រវីក្បាល ហេរ៉ូអ៊ីន ម័រហ្វីន អំហ្វេតាមីន ឬយ៉ាម៉ាយ៉ាបា ឬថ្នាំឆ្កួត។

**សំនួរទី ២.** តើមានមូលហេតុអ្វីខ្លះដែលបណ្ដាលឱ្យជនខ្លះប្រើប្រាស់គ្រឿងញៀន ?

**ចម្លើយ** មូលហេតុដែលនាំអោយជនខ្លះចូលចិត្តប្រព្រឹត្តគ្រឿងញៀនគឺ :

**ក- កត្តាបុគ្គលផ្ទាល់ :**

- អវិជ្ជា ល្ងង់ ឆាប់ជឿគេ ចាញ់បោកគេ

- រៀនខ្សោយ រៀនមិនចូល ចេញក្រៅសាលាទៅផ្ទប និង ពួកខិលខូចបបួល ។
- ភាពចង់ដឹង ចង់សាក បណ្ដាលអោយញៀនខ្លាំងឈប់មិនបានអត្តចរិតរឹងមានៈ
- ចង់សប្បាយដើម្បីបំបាត់ការធុញទ្រាន់ គិតថាអាចបំភ្លេចបញ្ហាផ្សេងៗបាន
- សេពគប់មិត្តមិនល្អ
- ទទួលការគាបសង្កត់ គម្រាមកំហែងពីពួកក្មេងទំនើង
- ត្រូវគេចាប់បង្ខំអោយប្រព្រឹត្តដើម្បីទុកធ្វើជាអាយ៉ងរបស់ពួកគេក្នុងការរកប្រាក់

**ខ. កត្តាគ្រួសារ :**

- ខ្វះភាពកក់ក្តៅពីមាតាបិតាអាណាព្យាបាល
- មានអំពើហិង្សាក្នុងគ្រួសារ
- ជីវភាពគ្រួសារក្រីក្រ ត្រូវបង្ខំចិត្តរកស៊ីជួញដូរគ្រឿងញៀន

**គ. កត្តាសង្គម :**

- លំហូរចូលនៃវប្បធម៌របរទេស
- មានការចរាចរទំនិញក្លែងក្លាយ គ្រឿងញៀន ។ល។

ដោយសារអំពើពុករលួយពីសំណាក់អាជ្ញាធរខ្លះ

- មានការធ្វេសប្រហែសពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច

**កត្តាសំខាន់** គឺ មាតាបិតាត្រូវប្រុងប្រយ័ត្ន ណែនាំអប់រំកូនអោយបានដិតដល់ តាមដានរាល់សកម្មភាពរបស់កូនកុំបណ្តោយអោយកូនចាយវាយប្រាក់កាសខ្ជះខ្ជាយ ឬបណ្តោលអោយកូនសេពគប់មិត្តភក្តិមិនល្អជ្រុលហួស ដែលធ្វើអោយមានការពិបាកកែ ។

☛ <u>សំនួរទី ៣.</u> តើអ្នកប្រព្រឹត្តគ្រឿងញៀនមានផលប៉ះពាល់អ្វីខ្លះដល់ខ្លួន គ្រួសារ និងសង្គមជាតិ ?

✍ <u>ចម្លើយ</u> ការប្រើប្រាស់គ្រឿងញៀនបង្កអោយមានផលវិបាកអាក្រក់ ដល់ខ្លួន គ្រួសារ និងសង្គមជាតិ:

**ក. ចំពោះខ្លួន :**

- ខូចសុខភាព ( ទ្រុឌទ្រោម បាត់កំលាំង ចាស់មុន អាយុ )
- កើតជំងឺ ( ថ្លើម ក្រពះ ពោះវៀន រលាកស្រោមខួរ ពិសេសជំងឺមិនអាចព្យាបាលបាន អេដស៍ ) ។
- ខាតបង់ប្រាក់កាស ទ្រព្យសម្បត្តិ ។
- ខាតបង់ពេលវេលា ។
- បាត់បង់ការងារ ។

- ខាតបង់ការរៀនសូត្រ ។
- បាត់បង់កិត្តិយស សេចក្តីថ្លៃថ្នូរជាមនុស្ស
- ប៉ះពាល់ដល់ខួរក្បាល អាចក្លាយជាមនុស្សឆ្កួត ឡប់សតិ ងាយនឹងធាប់ភ្លេចភ្លាំង ។
- មានចរិតកាចសាហាវ ឃោឃៅ ចូលចិត្តប្រើហិង្សា ហ៊ានប្រព្រឹត្តចោរកម្ម ឆក់ប្លន់ ឧក្រិដ្ឋកម្ម..
- ធ្វើអ្វីមួយគ្មានការពិចារណា ។
- បាត់បង់មនុស្សដែលជាទីស្រលាញ់របស់ខ្លួន និងមិត្តភក្តិ អ្នកជិតខាង រស់នៅឯកោ ។
- បាត់បង់គ្រួសារ សាច់ញាតិ ។
- បាត់បង់ទំនុកចិត្តល្អពីសំនាក់គ្រួសារ បងប្អូន សាច់ញាតិ
- បាត់បង់ឱកាសល្អនៅក្នុងជីវិត (ខូចអនាគត) ។
- អាចជាប់គុក រឺ ស្លាប់ខ្លួន ។

**ខ-គ្រួសារ :**

- បាត់បង់ធនធានមនុស្សនៅក្នុងគ្រួសារ (ជាអ្នករកប្រាក់ចំណូល ជាអ្នកផ្តល់ភាពកក់ក្តៅ ជាក្តី សង្ឃឹមនៅក្នុងគ្រួសារ) ។
- ខាតបង់ប្រាក់កាស ទ្រព្យសម្បត្តិ ។

- ខាតបង់ពេលវេលា ។
- បាត់បង់សេចក្តីថ្លៃថ្នូរ កិត្តិយសគ្រួសារ (ពូជអំបូរ)
- បង្កអោយមានអំពើហិង្សាក្នុងគ្រួសារ (កើតមាន ជំលោះផ្សេងៗ) ។
- បាត់បង់មនុស្សដែលជាទីស្រឡាញ់របស់ខ្លួន និង មិត្តភក្តិ អ្នកជិតខាង ។
- បាត់បង់ទំនុកចិត្តល្អពីសំនាក់គ្រួសារ បងប្អូន សាច់ញាតិ
- ធ្វើអោយមានភាពសោកសៅ សោកសង្រេងនៅ ក្នុងគ្រួសារ ។
- មានការបារម្ភណ៍ពីសំនាក់សមាជិកគ្រួសារ(វិបត្តិផ្លូវចិត្ត)

**គ. សង្គមជាតិ :**

- បាត់បង់ធនធានមនុស្សនៅក្នុងសង្គម ។
- បាត់បង់សេចក្តីថ្លៃថ្នូរ កិត្តិយសសំរាប់ជាតិ ។
- បង្កអោយមានអំពើហិង្សាក្នុងសង្គម (កើតមាន ជម្លោះផ្សេងៗ) ។
- កើតមានអំពើអសន្តិសុខក្នុងសង្គម (ឆក់ ប្លន់ សម្លាប់ ចាប់ជម្រិត ចាប់រំលោភ ..)
- កើតមានភាពអនាធិបតេយ្យ ច្របូកច្របល់ រញ៉េរញ៉ៃ ។

- សង្គមគ្មានការរីកចម្រើន ជួបវិបត្តិក្រីក្រពឹងអាស្រ័យតែជំនួយបរទេស ។

**សំនួរទី ៤.** ចូរធ្វើផ្ទាំងរូបភាព ស្ដីពីយុទ្ធនាការប្រឆាំងនឹងគ្រឿងញៀនដោយប្រើគំនិតផ្ទាល់ខ្លួន ?

**ចម្លើយ** ផ្ទាំងរូបភាព ស្ដីពីយុទ្ធនាការប្រឆាំងនឹងគ្រឿងញៀន :

- ផ្ទាំងរូបភាពគំនូរ ដែលមានលក្ខណៈគួរឱ្យខ្លាចស្ដីពីគ្រឿងញៀន ។
- ផ្ទាំងរូបភាពគំនូរពុម្ព ដែលមានលក្ខណៈអប់រំស្ដីពីគ្រឿងញៀន ក្រោមពាក្យស្លោក :
  + គ្រឿនញៀនបង្កឱ្យមានអំពើហិង្សាក្នុងគ្រួសារ
  + គ្រឿនញៀនបងឱ្យមានភាពក្រីក្រ
  + គ្រឿនញៀនធ្វើឱ្យខូចអនាគត និងខាតទ្រព្យសម្បត្តិ
  + គ្រឿនញៀនបងឱ្យបាត់បង់ការសិក្សា
  + គ្រឿនញៀនបង្កឱ្យមានចោរកម្ម ។

**សំនួរទី ៥.** ប្រសិនបើមាននរណាម្នាក់ បង្ខំឱ្យអ្នកប្រើគ្រឿងញៀន តើអ្នកត្រូវមានវិធីបដិសេធដូចម្ដេច?

**ចម្លើយ** ប្រសិនបើមាននរណាម្នាក់បង្ខំឱ្យអ្នកប្រើគ្រឿងញៀនយើងត្រូវមានវិធីបដិសេធដោយនិយាយថា :

- សុំទោស ! ខ្ញុំមានជម្ងឺ
- សុំទោស ! ខ្ញុំប្រញាប់ណាស់
- សុំទោស ! ខ្ញុំតមចំណី
- ទេ ! ខ្ញុំអរគុណច្រើនណាស់ ខ្ញុំមិនអាចទេ ។

**សំនួរទី ៦. តើជនដែលប្រព្រឹត្តគ្រឿងញៀន និងត្រូវមានទោសដូចម្តេចខ្លះ ?**

ចម្លើយ ជនដែលប្រព្រឹត្តគ្រឿងញៀន និងត្រូវមានទោសដាក់ពន្ធនាគារពី ១ឆ្នាំដល់ ៥ឆ្នាំចំពោះ :

ក. ជនណាដែលសម្រួលដោយចេតនាឱ្យជនណាម្នាក់ប្រើប្រាស់គ្រឿងញៀនដោយខុសច្បាប់ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ទោះយកថ្លៃក្តី មិនយកថ្លៃក្តី ។

ខ. ជនណាដែលលួចដាក់គ្រឿងញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ក្នុងអាហារ ក្នុងភេសជ្ជៈ ឬក្នុងសម្ភារៈផ្សេងៗទៀតដោយមិនឱ្យអ្នកបរិភោគ ឬអ្នកប្រើប្រាស់ដឹង ។

ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសអាចទទួលបន្ថែមនៅទោសពិន័យជាប្រាក់ពី ៥ លានរៀលទៅដល់ ១០ លានរៀល ។

ជនណាប្រព្រឹត្តដោយចេតនាទាក់ទងនឹងការនាំចេញ

ការនាំចូល ការដឹកជញ្ជូនអន្តរជាតិនូវគ្រឿងញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសពី ១០ ទៅ ២០ ឆ្នាំ និងផន្ទាទោសពិន័យជាប្រាក់ពី ១០ លានរៀល ដល់ ៥០ លានរៀល (ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ ១៩៩៦) ៚

**សំនួរទី ៧. តើមានវិធីណាខ្លះ ដើម្បីចៀសវាងគ្រឿងញៀន ?**

**ចម្លើយ** វិធីសំខាន់ៗក្នុងការចៀសវាងគ្រឿងញៀនមាន :

- កុំសាកល្បងប្រើប្រាស់គ្រឿងញៀន សូម្បីតែម្តងក៏កុំប្រើដែរ ?
- មិនត្រូវជឿតាមការញុះញង់របស់ឈ្មួញលក់គ្រឿងញៀន ឬអ្នកញៀនគ្រឿងញៀនឡើយ
- បើមានគេបបួល អ្នកត្រូវនិយាយពាក្យ "ទេ" យ៉ាងជាក់ច្បាស់
- បដិសេធដោយមិនប្រព្រឹត្តគ្រឿងញៀនជាដាច់ខាត
- មិនសេបគប់ជាមួយអ្នកញៀនគ្រឿងញៀន
- ផ្តល់ពត៌មានដល់អាជ្ញាធរមានសមត្ថកិច្ច នៅពេលឃើញជនចែកចាយ ឬប្រើគ្រឿងញៀន ។

## ជ.2 មេរៀនទី១១ : គុណវិបត្តិនៃសុរា និងបារី

### I. សំនួរត្រិះរិះ

☛ <u>សំនួរទី ១.</u> **សុរា និងបារីមានគុណវិបត្តិច្រើន ប៉ុន្តែហេតុអ្វីក៏នៅតែមានមនុស្សមួយចំនួនជក់បារី និងផឹកស្រាទៀត ?**

✍ <u>**ចម្លើយ**</u> សុរា និង បារីមានគុណវិបត្តិច្រើន ប៉ុនតែក៏នៅតែមានមនុស្សមួយចំនួនជក់បារី និងផឹកស្រាទៀតព្រោះ :

- យល់ថាការជក់បារី និងផឹកស្រានាំឱ្យខ្លួនមានកិត្តយសមានភាពសង្ហា សប្បាយរីករាយ
- ភាពចង់ដឹងរសជាតិបារី និង ស្រា ចង់សាក
- មានការបង្ខំពីមិត្តភក្តិ ឬ យកតម្រាប់តាមគេ
- ការកែអផ្សុក និង កាត់បន្ថយការពិបាកចិត្ត
- ឥទ្ធិពលនៃការផ្សាយពាណិជ្ជកម្ម

☛ <u>សំនួរទី ២.</u> **តើការផឹកសុរា និងជក់បារីនឹងផ្តល់ផលអាក្រក់អ្វីខ្លះដល់អ្នកប្រព្រឹត្ត និងគ្រួសារ ?**

✍ <u>**ចម្លើយ**</u> ការផឹកសុរា និងជក់បារីនឹងផ្តល់ផលអាក្រក់

ក. ដល់អ្នកប្រព្រឹត្តដូចជា :

- បាត់បង់មនសិការការងារ ភ្លេចភ្លាំង បាត់បង់ការចងចាំ
- កើតមានគ្រោះថ្នាក់ចរាចរណ៍ (ពិការ ឬ ស្លាប់) បាត់ធនធានមនុស្ស
- ប្រព្រឹត្តអំពើហិង្សា បង្កជម្លោះ វាយដំគេឯងមានរបួសស្នាម អាចក្លាយខ្លួនជាឧក្រិដ្ឋជន
- ខាតបង់ប្រាក់កាស ទ្រព្យសម្បត្តិ ខាតបង់ពេលវេលា
- បាត់បង់សេចក្ដីថ្លៃថ្នូរ និង កិត្តិយសជាមនុស្ស
- សាច់ឈាមមិនភ្លឺថ្លា ជ្រីវជ្រួញ កើតមានជម្ងឺផ្សេងៗ ដូចជា វិលមុខ ក្អួតចង្អោរ ឈឺក្រពះពោះវៀន ជម្ងឺថ្លើមជាដើម ។

ខ. គ្រួសារ :

- បាត់បង់ធនធានមនុស្សនៅក្នុងគ្រួសារ (ជាអ្នករកប្រាក់ចំណូល ជាអ្នកផ្ដល់ភាពកក់ក្ដៅ ជាក្ដីសង្ឃឹមនៅក្នុងគ្រួសារ)
- ខាតបង់ប្រាក់កាស ទ្រព្យសម្បត្តិ ខាតបង់ពេលវេលា

- ជីវភាពគ្រួសារក្រីក្រ
- បាត់បង់សេចក្តីថ្លៃថ្នូរ កិត្តិយសគ្រួសារ (ពូជអំបូរ)
- បង្កអោយមានអំពើហិង្សាក្នុងគ្រួសារ (កើតមានជម្លោះផ្សេងៗ)
- បាត់បង់មនុស្សដែលជាទីស្រឡាញ់របស់ខ្លួន និងមិត្តភក្តិ អ្នកជិតខាង
- បាត់បង់ទំនុកចិត្តល្អពីសំណាក់គ្រួសារ បងប្អូន សាច់ញាតិ
- ធ្វើអោយមានភាពសោកសៅ សោកសង្រេងនៅក្នុងគ្រួសារ ។
- មានការបារម្ភណ៍ពីសំណាក់សមាជិកគ្រួសារ ( វិបត្តិផ្លូវចិត្ត )
- បែកបាក់គ្រួសារ គ្រួសារគ្មានសុភមង្គល ។

**<u>សំនួរទី ៣.</u> ហេតុអ្វីបានជាការផឹកស្រាបណ្តាលឱ្យកើតមានអំពើហិង្សាក្នុងគ្រួសារ ការបង្កជម្លោះផ្សេងៗ និងការធ្វើឱ្យគ្រួសារមានភាពក្រីក្រ ?**

**<u>ចម្លើយ</u>** បានជា ការផឹកស្រាបណ្តាលឱ្យកើតមានអំពើ

ហិង្សាក្នុងគ្រួសារ ការបង្កជម្លោះផ្សេងៗ ព្រោះនៅពេលមានជាតិសុរាចូលក្នុងខ្លួន ធ្វើឱ្យមនុស្សបាត់បង់ម្ចាស់លើខ្លួនឯង វង្វេងវង្វាន់ និងមានអំនួតអួតអាងលើខ្លួនឯង ជាហេតុធ្វើឱ្យមានប៉ះពាល់ដល់អ្នកដទៃ និងបង្កអំពើហិង្សាជាមួយអ្នកដទៃ និងគ្រួសារ ។ ចំណែកការធ្វើឱ្យគ្រួសារមានភាពក្រីក្រដោយសារមានការចំណាយថវិកាជាច្រើនក្នុងការទិញសុរា ទិញថ្នាំព្យាបាលជម្ងឺខ្លួន ឬ សងជម្ងឺចិត្តគេ ឬ ទៅលួសយកមនុស្សមកវិញជាដើម ។

ម្យ៉ាងទៀត នាំឱ្យមានការបាត់បង់ធនធានមនុស្សនៅក្នុងគ្រួសារ (ជាអ្នករកប្រាក់ចំណូល ជាអ្នកផ្តល់ភាពកក់ក្តៅ ជាក្តីសង្ឃឹមនៅក្នុងគ្រួសារ) ។

សរុបមក រាល់ទង្វើទាំងឡាយដែលទាក់ទងនឹងការផឹកស្រា គឺពិតជាធ្វើឱ្យខ្លួន និងគ្រួសារមានជីវភាពក្រីក្រ។

☛ **<u>សំនួរទី ៤.</u> ចូរអ្នកបង្ហាញរបៀបនៃការបដិសេធការផឹកសុរាការជក់បារីក្នុងពិធីជប់លៀងមួយដោយសុភាពរាបសា ?**

✍ **<u>ចម្លើយ</u>** បង្ហាញរបៀបនៃការបដិសេធការផឹកសុរា ជក់

ចារីក្នុងពិធីជប់លៀងមួយដោយសុភាពរាបសារ យើង
ត្រូវ និយាយថា :

- សុំទោស ! ខ្ញុំមិនចេះទេ
- សុំទោស ! ខ្ញុំបើកបរ ខ្ញុំមិនញាំទេ
- សុំទោស ! ខ្ញុំមិនស្រួលខ្លួន
- សុំទោស ! ខ្ញុំប្រញាប់ណាស់ អរគុណច្រើន ...។

**សំនួរទី ៥.** **ចូរអ្នករៀបរាប់ផលអាក្រក់ដែលបណ្តាលមកពីការផឹកស្រា ជក់បារីរបស់នរណាម្នាក់ ដែលអ្នកធ្លាប់បានស្គាល់ ?**

**ចម្លើយ** ផលអាក្រក់ដែលបណ្តាលមកពីការផឹកស្រា និង
ជក់បារីរបស់ ឧត្តម បានធ្វើឱ្យមានអំពើហិង្សាក្នុងគ្រួសារ
ហើយគ្រួសាររបស់គេកាន់តែក្រីក្រជំពាក់បំណុលគេ បាត់
បង់ការងារ (ត្រូវគេបញ្ឈប់ពីការងារ) បាត់បង់កិត្តិយស
និង មានជម្ងឺជាច្រើនដូចជា ឈឺក្រពះ រលៀកស្ងួត និង
ជម្ងឺថ្លើម ...។

**សំនួរទី ៦.** **បើអ្នកស្គាល់នរណាម្នាក់ចេះជក់បារី ឬ ផឹកសុរា តើអ្នកមានវិធីជួយគេបែបណាខ្លះ ដើម្បីឱ្យគេ**

ឈប់ជក់បារី និងផឹកសុរា ?

ចម្លើយ ដើម្បីអោយគេឈប់ជក់បារី ឬ ផឹកសុរាយើងត្រូវ :

- ណែនាំអោយគេកាត់បន្ថយបន្តិចម្តងៗ ដើម្បីសុខភាព
- អោយគេស្តាប់ដំបូន្មានល្អៗពីឪពុកម្តាយ គ្រូ មិត្តភក្តិ
- នៅពេលគេចង់ជក់បារី ឬ ផឹកសុរាយើងត្រូវអោយគេ បែរទៅរកការលេងកីឡា សិល្បៈរៀនសូត្រ ស្តាប់ចំរៀងជាដើម។

**សំនួរទី ៧. តើអ្នកជក់ដោយប្រយោលមានន័យដូចម្តេច ? ហើយអ្នកនោះមានផលប៉ះពាល់ដល់សុខភាពដែរ ឬទេ ?**

ចម្លើយ **អ្នកជក់ដោយប្រយោល**មានន័យថា ជាអ្នកទទួលឥទ្ធិពលផ្សែងបារីដែលគេបង្ហុយចេញមកហើយស្រូបចូលទៅក្នុងខ្លួន ។ ហើយអ្នកនោះមានផលប៉ះពាល់ដល់សុខភាពរបស់គេ ដោយកើតមានជំងឺផ្សេងៗដូចជា មហារីក គាំងបេះដូង និងជំងឺប្រព័ន្ធដង្ហើម ។





# ជំ.2 មេរៀនទី១៧ : ការតានតឹងចិត្ត

## I. សំនួរត្រិះរិះ

☛ <u>សំនួរទី ១.</u> តើការតានតឹងចិត្តជាអ្វី ?

✎ <u>ចម្លើយ</u> **ការតានតឹងចិត្ត**ជាប្រតិកម្មឆ្លើយតបទៅនឹងបញ្ហា ឬ ហេតុការណ៍ដែលបង្កការលំបាកដល់ផ្លូវចិត្ត។

☛ <u>សំនួរទី ២.</u> តើមនុស្សដែលមានការតានតឹងចិត្តមានអាកប្បកិរិយាបែបណាខ្លះ ?

✎ <u>ចម្លើយ</u> មនុស្សដែលមានការតានតឹងចិត្តមានអាកប្បកិរិយាដូចជា :

- រសាប់រសល់ មិនរួសរាយរាក់ទាក់ ងាយមានទំនាស់ជាមួយគេឯង និងច្រើននៅឯកោ
- អសកម្មក្នុងការបំពេញការងារផ្សេងៗ សកម្មភាពការងារចុះខ្សោយ ឬអាចមានសកម្មភាពការងារច្រើនហួសមិនបានសម្រាក
- ច្រើនពឹងពាក់អ្នកដទៃ ដើម្បីជួយគាំទ្រ និងជួយធ្វើការសម្រេចចិត្ត

- ចូលចិត្តផឹកស្រា ឬប្រើប្រាស់គ្រឿងញៀន ដូចជា ថារី កញ្ឆា យ៉ាម៉ា អាភៀនជាដើម ។

**<u>សំនួរទី ៣.</u> តើការតានតឹងចិត្តបណ្តាលមកពីបុព្វហេតុអ្វីខ្លះ ?**

**<u>ចម្លើយ</u>** ការតានតឹងចិត្តបណ្តាលមកពី :

- **បញ្ហាសង្គម :** មានគ្រោះទុរភិក្ស ភាពក្រីក្រ សង្គ្រាម គ្រោះធម្មជាតិ( គ្រោះរាំងស្ងួត ទឹកជំនន់..) រៀនខ្សោយ ការប្រឡងធ្លាក់ ការបាត់បង់ ឬគ្មានការងារធ្វើ អំពើអបាយមុខ ការគម្រាមកំហែង អំពើហិង្សា ការរំលោភសិទ្ធិមនុស្ស និងការមិនគោរពច្បាប់ ។
- **ទាក់ទងនឹងការរស់នៅ :** មានទំនាស់ក្នុងគ្រួសារ ជីវភាពក្រីក្រ បន្ទុកការងារច្រើនហួសពេក ការមិនយល់ចិត្តគ្នា ការមិនចុះសម្រុងក្នុងការងារ ការបំពេញការងារពុំបានជោគជ័យ ការគិតព្រួយចំពោះហេតុការណ៍សម្រាប់អនាគត មានជម្ងឺរ៉ាំរ៉ៃប្រចាំរាងកាយ និងការបាត់បង់មនុស្សជាទីស្រឡាញ់។
- **តាមជំនឿ :** បណ្តាលមកពីវាសនាអាក្រក់ កម្មផល ទំនាយ ត្រូវអំពើ ត្រូវស្នេហ៍ ។ល។

**សំនួរទី ៤. តើមានវិធីសាស្ត្រអ្វីខ្លះ ដើម្បីជួយអ្នកតានតឹងចិត្តឱ្យមានភាពធូរស្រាល និងជាសះស្បើយ ?**

**ចម្លើយ** ដើម្បីជួយអ្នកតានតឹងចិត្តឱ្យមានភាពធូរស្រាល និងជាសះស្បើយយើងត្រូវប្រើវិធីសាស្ត្រ ៤ គឺ :

- វិធីសាស្ត្រសាមញ្ញា : ការសម្រាកលំហែកាយ ការលើកទឹកចិត្តចំពោះអ្នកមានអារម្មណ៍ឯកោ ការជម្រុញ និងលើកទឹកចិត្តអ្នកតានតឹងចិត្ត ការលើកទឹកចិត្តពីសំណាក់ក្រុមគ្រួសារ
- សកម្មភាពសហគមន៍ (វិធីសាស្ត្រក្នុងសហគមន៍) : ការជួបជុំគ្នា លើកទឹកចិត្ត និងចែករំលែកទុក្ខព្រួយ ការបង្កើតជាកម្មវិធីសិល្បៈ ការប្រារព្ធពិធីបុណ្យសាសនាផ្សេងៗ ការលេងកីឡា ការដោះស្រាយតាមបែបមន្តអាគមផ្សេងៗ
- ការអប់រំ (វិធីសាស្ត្រនៃការអប់រំ) : តាមរយៈការផ្សព្វផ្សាយផ្សេងៗ
- លំហាត់សម្រាកចិត្តកាយ : ការប្រើប្រាស់របៀបសមាធិ

**សំនួរទី ៥. ចូររៀបរាប់ពីវិធីជួយមិត្ត បងប្អូនដែលមានការតានតឹងចិត្តធ្ងន់ធ្ងរ ?**

**ចម្លើយ** វិធីជួយមិត្ត បងប្អូន ដែលមានការតានតឹងចិត្ត

ធ្ងន់ធ្ងរយើងត្រូវមានការជម្រុញលើកទឹកចិត្តចែករំលែកនូវអ្វីដែលពួកគេមាន ឱ្យគេសម្រាកលំហែរកាយ និងធ្វើសកម្មភាពដែលបង្កភាពរីករាយដល់ពួកគេ ។

**សំនួរទី ៦. ប្រសិនបើប្អូនមានការតានតឹងចិត្ត តើប្អូនដោះស្រាយដូចម្ដេច ?**

**ចម្លើយ** ប្រសិនបើខ្ញុំមានការតានតឹងចិត្ត ខ្ញុំនឹងព្យាយាមធ្វើចិត្តឱ្យសប្បាយៗ ជួបជុំមិត្តភក្តិឱ្យបានច្រើន ធ្វើដំណើរកម្សាន្ត ហាត់ប្រាណ ឬ លេងកីឡា ។ល។

**សំនួរទី ៧. តើការតានតឹងចិត្តអាចធ្វើឱ្យមានផលប៉ះពាល់អ្វីខ្លះដល់ខ្លួនឯង គ្រួសារ និងសង្គម ?**

**ចម្លើយ** ការតានតឹងចិត្តអាចធ្វើឱ្យមានផលប៉ះពាល់ដល់ខ្លួនឯង គ្រួសារ និងសង្គម :

ក. ខ្លួនឯង :

- អាចធ្វើឱ្យខ្លួនឆេវឆាវ មានអារម្មណ៍មួរម៉ៅ ក្ដៅក្រហាយច្រឡោត អាចជម្រុញឱ្យកើតមានអំពើហិង្សា
- អាចក្លាយទៅជាជនវិកលចរិត ឬឡប់សតិ
- អាចកើតជម្ងឺបេះ
- ខាតបង់ពេលវេលា ប្រាក់កាសដើម្បីទៅពិនិត្យ ពិគ្រោះ

ជម្ងឺ

- ធ្វើឱ្យមានអារម្មណ៍នឿយណាយ ធុញថប់ ភ្លេចភ្លាំងច្រើន រៀនសូត្រមិនពូកែ ព្រួយបារម្ភខ្លាំង និងរស់សង្ស័យក្នុងជីវិត ។

ខ- ចំពោះគ្រួសារ :

- បាត់បង់នូវធនធានមនុស្សក្នុងគ្រួសារ ដែលធ្លាប់ជួយគិតគូរ ធ្លាប់ជួយរកប្រាក់..
- ជីវភាពជួបការលំបាក ក្រីក្រ ជំពាក់បំណុលគេ ឬ អស់ផ្ទះសំបែងដោយសារទៅព្យាបាលជម្ងឺ
- កើតមានអំពើហិង្សាក្នុងគ្រួសារ
- អំពុលដល់គ្រួសារ មានការពិបាកចិត្ត បារម្ភណ៍ចំពោះខ្លួន
- ខាតពេលវេលាក្នុងការរកប្រាក់កម្រៃចិញ្ចឹមគ្រួសារ ។

គ- ចំពោះសង្គម :

- បាត់បង់ធនធានមនុស្សដើម្បីជួយអភិវឌ្ឍសង្គម
- មានបញ្ហាអសុវត្ថិភាព កើតមានអំពើហិង្សាក្នុងសង្គម
- អំពុលដល់រដ្ឋាភិបាលក្នុងការជួយគ្រប់បែបយ៉ាង
- សង្គមមានការរអភិវឌ្ឍយឺត ។

# ? សំណួរបញ្ចប់ជំពូក ២

## I. *ចូរគូសសញ្ញា✓ ក្នុងប្រអប់ខាងមុខចម្លើយដែលត្រឹមត្រូវ*

១- ការបួសជាព្រះសង្ឃនៅក្នុងព្រះពុទ្ធសាសនាត្រូវ :

☐ក. រក្សាសីលជានិច្ច ☑ខ. សិក្សាគម្ពីរព្រះត្រៃបិដក

☐គ. ស្រោចទឹកប្រោះព្រំ ☐ឃ. រៀនមន្តអាគម ។

២-,គ្រប់សាសនាទាំងអស់តែងតែអប់រំទូន្មានមនុស្សឱ្យ :

☑ក.ចេះស្រឡាញ់គ្នា ☐ខ. ព្យាបាទ ☐គ. អធ្យាស្រ័យគ្នា

☐ឃ. ឈ្នានីសគ្នា ។

៣- សារធាតុញៀនដែលផ្ទុកទៅដោយសារជាតិពុលជាច្រើនប្រភេទនឹងបណ្តាលឱ្យអ្នកប្រព្រឹត្តកើតជម្ងឺមហារីក គឺ :

☐ក. អាភៀន ☐ខ. សុរា ☑គ. ថារី ☐ឃ. គ្រឿងញៀន ។

## II. ចូរផ្គូផ្គងពាក្យក្នុងប្រអប់ ផ្នែក ក ទៅនឹងអត្ថន័យផ្នែក ខ ឱ្យបានត្រឹមត្រូវ

| ក | ខ | ចម្លើយ |
|---|---|---|
| **អានុភាពជាតិស្រវឹង** | **គុណវិបត្តិ** | ១.> |
| ១. ការធ្វើឱ្យខួរក្បាលឈប់គិត | ក. ភ្លេចភ្លាំងស្មារតី បាត់ការចងចាំ | ២.> |
| ២. ការវង្វេងស្មារតី | | ៣.> |
| ៣. ការធ្វើឱ្យគំនិតច្របូកច្រ ប់ | ខ. ប្រព្រឹត្តអំពើហិង្សា បង្កជម្លោះ | ៤.> |
| ៤. ការបាត់បង់សមត្ថភាពវិនិច្ឆ័យ | | |

| | | |
|---|---|---|
| **៥**. ការកើតមានជម្ងឺរ៉ាំរ៉ៃ<br>**៦**. ការបង្កការលំបាកដល់សង្គម | **គ**. គ្មានការពិចារណាហ៊ាន ប្រព្រឹត្តអំពើផ្សេងៗ<br>**ឃ**. និយាយផ្ដេសផ្ដាស ឡូឡា គ្មានខ្មាសអៀន<br>**ង**. ស្លាប់ បាត់បង់ធនធាន មនុស្ស<br>**ច**. គ្រោះថ្នាក់ចរាចរណ៍ បង្កចលាចល | **៥.>**<br>**៦.>** |

**III**. បំពេញល្បះចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

១. មនុស្សខ្លះដែលមានជីវភាពក្រីក្រ ជួបទុក្ខលំបាក មានជម្ងឺរ៉ាំរ៉ៃ ប្រចាំកាយ បាត់បង់មនុស្សជាទីស្រឡាញ់អាចបណ្ដាលឱ្យកើតមាន..***ការតានតឹងចិត្ត***..។

២. ការបួសគឺជាការចេះលះបង់ចោលអ្វីៗគ្រប់យ៉ាង និងជាការស្វែងរកសេចក្ដីស្ងប់ខាងផ្លូវចិត្តតាមរយៈការសង្រួម..***ផ្លូវចិត្ត***..។

**IV. ហេតុអ្វីបានជាមនុស្សមានជំនឿលើសាសនា ? ចូរពន្យល់ឱ**

✍ <u>**ចម្លើយ**</u> សាសនាមកពីពាក្យ**សាសនៈ**មានន័យថាជាឱវាទ ការទូន្មានប្រៀនប្រដៅ ឬ ពាក្យបណ្ដាំរបស់

គ្រូអាចារ្យណាមួយក្នុងលោក ។

- គេតែងសង្កេតឃើញថា កាលណាមាន ភយន្តរាយ ឬ បញ្ហាណាមួយកើតមានឡើង ហើយដែលមនុស្ស ដោះស្រាយដោយកំលាំងកាយ ឬ កំលាំងប្រាជ្ញា របស់ខ្លួនពុំរួចនោះ ក៏កើតមានជំនឿទៅលើកំលាំង ក្រៅខ្លួន ថាមានវត្ថុខ្លាំងពូកែស័ក្តិសិទ្ធិផ្សេងៗ អាច ជួយសំរេចគោលបំនងខ្លួនបាន ។

ជនជាតិខ្មែរយើង កាលដើមឡើយក៏មានជំនឿបែប នេះដែរ គឺនិយមគោរពកំលាំងធម្មជាតិដោយយល់ ថា ធម្មជាតិទាំងឡាយសុទ្ធតែមានព្រលឹង និងមាន កំលាំងស័ក្តិសិទ្ធិដែលយើងមើលពុំឃើញ ។ គេបាន យកដុំថ្មជាតំនាងកំលាំងធម្មជាតិ ដែលគេគោរព ហើយគេហៅដុំថ្មនោះថាអ្នកតា ដូចជាអ្នកតាទឹក អ្នកតាដី ។ល។ ក្រៅពីអ្នកតាតំនាងធម្មជាតិ មាន អ្នកតាតំនាងមេបា ឬ បុព្វបុរសដែលបានស្លាប់ទៅ ហើយៗនៅចាំថែរក្សា និងផ្តល់សេចក្តីសុខដល់អ្នក ស្រុក ដូចជាអ្នកតាដំបងដែក អ្នកតាក្រហមក.. សាសនាអ្នកតានិយមនេះ ពុំសូវល្អតលាស់ ព្រោះពុំ មានអត្ថបទ (គម្ពីរ) ដែលកត់ត្រាទស្សនៈ ទ្រឹស្តី

ដូចជា សាសនាដទៃទៀតឡើយ ។ ទោះបីគ្មានការរីកចំរើនលូតលាស់ក៏ដោយ ក៏សាសនាបែបនេះនៅតែរស់បន្តក្នុងចិត្តគំនិត និងក្នុងទំនៀមទំលាប់ខ្មែររហូតមកដល់សព្វថ្ងៃនេះដែរ ។

- សាសនាណាក៏ដូចជាសាសនាណាដែរ តែងតែអប់រំមនុស្សឱ្យសាងអំពើល្អ ។
- សាសនានីមួយៗតែងតែផ្សារភ្ជាប់ជំនឿនៅលើព្រះអាទិទេព ឬទេវៈដែលមានមហិទ្ធិឫទ្ធិអាចជួយស្រោចស្រង់មនុស្សឱ្យផុតទុក្ខបាន ។
- សាសនាផ្សារភ្ជាប់ការអប់រំ និងអបិយជំនឿដែលជាកត្តាផ្តល់កម្លាំងចិត្តដល់មនុស្ស និងផ្តល់នូវសុទិដ្ឋិ
- សាសនាផ្តល់សុខៈឱ្យមនុស្សផ្ទៃកស្មារតី ។

ឧទាហរណ៍ : ព្រះពុទ្ធសាសនាអប់រំមនុស្សឱ្យមានជំនឿលើកម្មផល សាងល្អ បានល្អ សាងអាក្រក់ បានអាក្រក់ ។ ធ្វើឱ្យមនុស្សមានជំនឿថាកម្មពៀរពិតជាមានមែន ។

- សាសនាបានបង្ហាញពីអត្តសញ្ញាណជាតិរបស់ខ្មែរ

( ជាតិ **សាសនា** ព្រះមហាក្សត្រ ) ។

**V. តើនៅប្រទេសកម្ពុជាមានសាសនាអ្វីខ្លះ ? ចូររៀបរាប់ ។**

**ចម្លើយ** នៅក្នុងប្រទេសកម្ពុជាយើងសព្វថ្ងៃនេះមាន សាសនាព្រះពុទ្ធ អ៊ីស្លាម គ្រិស្ត ព្រះនាងគង់សាអ៊ីម អ៊ីក្វាន់ តាវ..។ *ព្រះពុទ្ធសាសនា* ជាសាសនារបស់រដ្ឋ ។

**VI. តើព្រះពុទ្ធសាសនាបានអប់រំពុទ្ធសាសនិកជន និង ចូលរួមជួយកសាងប្រទេសកម្ពុជាដូចម្ដេចខ្លះ ?**

**ចម្លើយ** ព្រះពុទ្ធសាសនាបានអប់រំពុទ្ធសាសនិកជន និង ចូលរួមជួយកសាងប្រទេសកម្ពុជា ក្នុងវិស័យដូចខាងក្រោម :

**ក.** វិស័យអប់រំ : ព្រះសង្ឃជាឃោសនិក :

- ព្រះសង្ឃជាឃោសនិក ឬ ទ្រង់ជាអ្នកសំដែងធម្ម ទេសនាប្រៀនប្រដៅមនុស្ស ។
- អប់រំមនុស្សអោយមានជំនឿលើ កម្ម ផល បុណ្យ បាប ។
- អប់រំអោយវៀរចាកអំពើអាក្រក់គ្រប់បែបយ៉ាង។
- អប់រំអោយយល់អំពីមូលហេតុ ដែលនាំអោយមាន ទុក្ខគឺ លោភៈ ទោសៈ និងមោហៈអោយចេះរំលត់ ទុក្ខ( អរិយសច្ចៈ ) ។
- អប់រំមនុស្សអោយលះបង់នូវអសវក្កិលេស( អវិជ្ជា

និងតណ្ហា ) ។

- អោយចេះស្រលាញ់អានិតជួយគ្នាមានសាមគ្គីគ្នា បំបាត់វណ្ណៈមិនរើសអើង ( ព្រហ្មវិហារធម៌ )។

**ខ. វិស័យសង្គមកិច្ច :**

- សម័យបុរាណព្រះសង្ឃជាគ្រូពេទ្យព្យាបាលជំងឺផ្លូវចិត្ត និងផ្លូវកាយ ។
- ព្រះសង្ឃជាវិស្វករខាងជំនាញផ្សេងៗដូចជាបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញខាងសិល្បៈ ។

( ឧ. ធ្វើទូកប្រណាំង ធ្វើតុ ទូ ចំលាក់ រូបផ្សេងៗ...)

- ព្រះសង្ឃជាអ្នកបំផុសអោយមានចលនាក់សាងស្ថាបនាសមិទ្ធផលផ្សេងៗដោយផ្អែកលើជំនឿ និងអានិសង្ឃនៃការកសាងដូចជា កសាងកុដិ វិហារ សាលារៀន មន្ទីរពេទ្យលើកផ្លូវ ថ្នល់ ជីកស្រះសង់ស្ពានជាដើម។
- ជាអ្នកជួយដោះស្រាយទំនាស់ និងជួយសំរបសំរួលបញ្ហាទំនាស់ផ្សេងៗនៅក្រៅប្រព័ន្ធតុលាការ
- ជាអ្នកចូលរួមលប់បំបាត់អំពើហិង្សា អប់រំអោយចេះដោះស្រាយបញ្ហាផ្សេងៗដោយសន្តិវិធី ។

គ. វិស័យសេដ្ឋកិច្ច :

- ជាមជ្ឈមណ្ឌលព្យាបាលជំងឺផ្លូវចិត្ត និង ផ្លូវកាយ
- ជាកន្លែងអប់រំផ្លូវចិត្តអោយមានភាពស្ងប់ និង ព្យាបាលរោគតាមឱសថបុរាណ ។
- ជាកន្លែងបណ្តុះបណ្តាលវិជ្ជាជីវៈ និង ជំនាញសិល្បៈផ្សេងៗ ។
- ជាថ្នាលបណ្តុះផ្នែកជំនាញ ចំលាក់ ហត្ថកម្មសំណង់ និង សំភារៈប្រើប្រាស់នានា... ។
- ជាកន្លែងចូលរួមកសាងសមិទ្ធផលសង្គមមានដូចជា សាលារៀន មន្ទីរពេទ្យ ផ្លូវ ថ្នល់ ស្ពាន ជីកស្រះ...។
- ជាអ្នកដឹកនាំផ្សព្វផ្សាយ និងជួយឧបត្ថម្ភទីជំរកផ្នែកសេដ្ឋកិច្ចគ្រួសារដល់ទុរគតជន ចាស់ជរាកុមារកំព្រា និង ជនក្រីក្រ ។

**ឃ. វិស័យវប្បធម៌ :**

- ជាមជ្ឈមណ្ឌលថែរក្សា និងការពារនូវទំនៀមទំលាប់ប្រពៃណីជាតិ ។
- ជាមជ្ឈមណ្ឌលផ្សព្វផ្សាយ និងដឹកនាំអនុវត្តពិធីបុណ្យរបស់ជាតិ ។
- ជាកន្លែងតំកល់ទុកនូវឯកសារ គម្ពីរក្បួនខ្នាត អក្សរសាស្ត្រ និងភាសាជាតិ ។

- ជាគ្រូបង្រៀនផ្នែកអក្សរសាស្ត្រនិងភាសាបូរាណ ជាតិនៅតាមវត្តអារាម ។
- ជាថ្នាលបណ្ដុះពូជអក្សរសាស្ត្រ ភាសា និងវប្បធម៌ខ្មែរ

**ង. វិស័យនយោបាយ :**

- ជាអ្នកអប់រំ និងទាមទារនូវវប្បធម៌សន្តិភាព ។
- ធម្មយាត្រារបស់ព្រះសង្ឃដើម្បីទាមទារសន្តិភាព ទាមទារការចរចារបំបាត់អំពើហឹង្សាគ្រប់បែបយ៉ាង
- ជាអ្នកទាមទារការពារ និងថែរក្សាអត្តសញ្ញាណជាតិ
- ជាអ្នកទាមទារឯករាជ្យ និងសិទ្ធិសេរីភាពពីអាណានិគមនិយមបារាំង (អាចារ្យស្វា អាចារ្យ ហែមចៀវ..)
- ជាអ្នកចូលរួមក្នុងការគ្រប់គ្រង និងដឹកនាំសណ្ដាប់ធ្នាប់សាធារណៈសង្គមនៅតាមមូលដ្ឋាន ។
- ជាអ្នកចូលរួមទាមទារការគោរព និងការអនុវត្តនូវលទ្ធិប្រជាធិបតេយ្យ (ការបោះឆ្នោត) ។



## ជំពូក III : ការចូលរួមអភិវឌ្ឍសហគមន៍

# ជំ.៣ មេរៀនទី១ : លទ្ធិប្រជាធិបតេយ្យ

## I. សំនួរត្រិះរិះ

**សំនួរទី ១. តើលទ្ធិប្រជាធិបតេយ្យជាអ្វី ?**

**ចម្លើយ** លទ្ធិប្រជាធិបតេយ្យ មានន័យថាជាទម្រង់នៃការដឹកនាំប្រទេសដែលអំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។

អំណាចកំពូលក្នុងរដ្ឋាភិបាលថិតក្នុងកណ្ដាប់ដៃប្រជាពលរដ្ឋប្រើប្រាស់ដោយប្រជាពលរដ្ឋផ្ទាល់ និង ដោយអ្នកតំណាងប្រជាពលរដ្ឋ ដែលជ្រើសរើសដោយការបោះឆ្នោត ។

**សំនួរទី ២. តើលក្ខណៈពិសេសនៃលទ្ធិប្រជាធិបតេយ្យមានអ្វីខ្លះ ? ចូររៀបរាប់ ។**

**ចម្លើយ** លក្ខណៈពិសេសនៃលទ្ធិប្រជាធិបតេយ្យគឺ :

- ប្រជាពលរដ្ឋមានសិទ្ធិ និងសេរីភាពពេញលេញ
- មានសេរីភាពខាងសារព័ត៌មាន
- មានគណបក្សនយោបាយច្រើន
- ការបោះឆ្នោតមានលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌
- ពហុនិយម និង មានការអធ្យាស្រ័យ ។

☛ សំនួរទី ៣. ហេតុអ្វីបានជាលទ្ធិប្រជាធិបតេយ្យទាមទារឱ្យមានការបោះឆ្នោត ?

✍ ចម្លើយ បានជាលទ្ធិប្រជាធិបតេយ្យទាមទារឱ្យមានការបោះឆ្នោតព្រោះ **ក្នុងលទ្ធិប្រជាធិបតេយ្យ** ប្រជារាស្ត្រគឺជាម្ចាស់ទឹកដីម្ចាស់លើជោគវាសនារបស់ប្រទេសជាតិ។ ប្រជារាស្ត្រជាអ្នកទទួលខុសត្រូវលើអនាគតរបស់ប្រទេស ប៉ុន្តែប្រជារាស្ត្រទាំងអស់មិនអាចទៅចាត់ចែងកិច្ចការរដ្ឋដោយផ្ទាល់ទាំងអស់គ្នាបានទេគឺ ត្រូវជ្រើសរើសបេក្ខជនដែលខ្លួនពេញចិត្តម្នាក់ ឬច្រើនធ្វើជាតំណាងឱ្យខ្លួនហៅថា តំណាងរាស្ត្រដើម្បីទៅចាត់ចែងកិច្ចការរដ្ឋជំនួស ។ ការជ្រើសរើសនេះត្រូវឆ្លងកាត់តាមរយៈការបោះឆ្នោតដែលមានលក្ខណៈដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។

☛ សំនួរទី ៤. ដើម្បីឱ្យមានដំណើរការលទ្ធិប្រជាធិបតេយ្យអនុវត្តទៅបានល្អ តើសង្គមត្រូវទាមទារឱ្យមានអ្វីខ្លះ?

✍ ចម្លើយ ដើម្បីឱ្យមានដំណើរការលទ្ធិប្រជាធិបតេយ្យអនុវត្តទៅបានល្អ សង្គមត្រូវទាមទារឱ្យមានតម្លាភាព ឱ្យមានការគោរពសិទ្ធិ ។

☛ សំនួរទី ៥. ហេតុអ្វីបានជាសេរីភាពនៃសារព័ត៌មាននៅក្នុងសង្គមប្រជាធិបតេយ្យ មានសារៈសំខាន់ ?

**ចម្លើយ** បានជាសេរីភាពនៃសាព័ត៌មាននៅក្នុងសង្គមប្រជាធិបតេយ្យ មានសារៈសំខាន់ ព្រោះ :

- ដើម្បីជួយផ្សព្វផ្សាយព័ត៌មាន និងព្រឹត្តិការណ៍នានាក្នុង និងក្រៅប្រទេសដល់ប្រជាពលរដ្ឋ
- ដើម្បីជួយផ្សព្វផ្សាយនូវគំនិត ការបញ្ចេញមតិ
- ដើម្បីជួយផ្តល់ព័ត៌មាន និងបទពិសោធនានាដល់ថ្នាក់ដឹកនាំ
- ដើម្បីជួយដល់ការអភិវឌ្ឍផ្នែកនយោបាយ និងវិទ្យាសាស្ត្រ
- ដើម្បីឱ្យប្រជាពលរដ្ឋមានលទ្ធភាព សេរីភាពគ្រប់យ៉ាងក្នុងការបញ្ចេញគំនិត យោបល់ដើម្បីជួយអភិវឌ្ឍសង្គមជាតិ
- ដើម្បីបង្ហាញថា ប្រទេសមួយប្រកាន់យកលទ្ធិប្រជាធិបតេយ្យពេញលេញពិតប្រាកដ ។

**សំនួរទី ៦. ក្នុងលទ្ធិប្រជាធិបតេយ្យ តើការមានគណបក្សនយោបាយច្រើននាំមកនូវសារៈសំខាន់អ្វីខ្លះចំពោះសង្គមជាតិ ?**

**ចម្លើយ** ក្នុងលទ្ធិប្រជាធិបតេយ្យ ការមានគណបក្សនយោបាយច្រើននាំមកនូវសារៈសំខាន់ ព្រោះ របបពហុបក្ស

សមាជិកទាំងអស់ដែលរស់នៅក្នុងសង្គមប្រជាធិបតេយ្យ ត្រូវតែផ្សារភ្ជាប់នឹងទស្សនៈពហុបក្ស ហើយទទួលស្គាល់ថា បុគ្គល ឬ ក្រុមខុសៗគ្នារមែងមានទស្សនៈ និងយោបល់ខុសៗគ្នា។ លើសពីនេះ ពួកគេត្រូវតែទទួលស្គាល់ថា ទស្សនៈសំដែងចេញមកមិនមែនត្រឹមត្រូវទាំងអស់នោះទេ ។

ម្យ៉ាងទៀតការមានគណបក្សច្រើន គឺបានផ្ដល់លទ្ធភាពច្រើនក្នុងជម្រើសរបស់ប្រជាពលរដ្ឋ ក្នុងការបញ្ចេញមតិប្រព័ន្ធពហុបក្សនេះហើយ ធ្វើអោយមានប្រទេសយើងមានលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ។

<u>**សំនួរទី ៧.**</u> **ហេតុអ្វីបានជាអំណាចនៃការគ្រប់គ្រងរដ្ឋតាមទារឱ្យមានការបែងចែកអំណាចដាច់ដោយឡែកពីគ្នា ?**

<u>**ចម្លើយ**</u> ក្នុងប្រទេសអនុវត្តលទ្ធិប្រជាធិបតេយ្យអំណាចនៃការគ្រប់គ្រងរដ្ឋទាមទារឱ្យមានការបែងចែកអំណាចដាច់ពីគ្នា អំណាចទាំងនោះមានអំណាច ៣

មានការបែងចែកដាច់ពីគ្នា គឺ :

- **អំណាចនីតិបញ្ញត្តិ( រដ្ឋសភា_ព្រឹទ្ធសភា )** : មាននាទី តាក់តែងច្បាប់ និងអនុម័តច្បាប់ ។
- **អំណាចនីតិប្រតិបត្តិ ( រដ្ឋាភិបាល )**: មាននាទីជាអ្នក អនុវត្តច្បាប់ និង ក្រិត្យ ។
- **អំណាចតុលាការ (អង្គចៅក្រម )**: ជំនុំជំរះក្តី និង រក· យុត្តិធម៌ជូនសង្គម ។

✷ អំណាចទាំង ៣ បែងចែកដាច់ពីគ្នាដើម្បីចៀសវាងការ រំលោភអំណាចគ្នាដែលគេហៅថា "**អំណាចផ្តាច់ការ**" ។ អំណាចទាំង ៣ នេះ ជាស្ថាប័នផ្សេងៗពីគ្នា ប៉ុន្តែត្រូវ ពិនិត្យគ្នាទៅវិញទៅមកដើម្បីកុំអោយអំណាចណា មួយរំលោភទៅលើអំណាចណាមួយទៀត ។

☛ <u>សំនួរទី ៨.</u> **ហេតុអ្វីបានជាប្រទេសភាគច្រើននិយម ជ្រើសរើសយកការដឹកនាំប្រទេសតាមលទ្ធិប្រជាធិប តេយ្យ ?**

**ចម្លើយ** បានជាប្រទេសភាគច្រើននិយមជ្រើសរើសយក ការដឹកនាំប្រទេសតាមលទ្ធិប្រជាធិបតេយ្យ ព្រោះ តាម លទ្ធិនេះ ការដឹកនាំគឺ យកប្រជាជនជាធំ ហើយថ្នាក់ ដឹកនាំ ត្រូវបានជ្រើសរើសដោយប្រជាពលរដ្ឋ ។

**សំនួរទី ៩. ចូរសិក្សាស្រាវជ្រាវពីការគ្រប់គ្រងប្រទេស តាមបែបប្រជាធិបតេយ្យនៅកម្ពុជា ?**

**ចម្លើយ** ការគ្រប់គ្រងប្រទេសតាមបែបប្រជាធិបតេយ្យនៅ កម្ពុជា មាន :

- ការបោះឆ្នោត
- កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ព្រោះមានសន្តិភាព
- កំណែទម្រង់ច្បាប់រដ្ឋបាលសាធារណៈជាដើម ។



# ៦.៣ មេរៀនទី២ : សិទ្ធិពលរដ្ឋ

## I. សំណួរត្រិះរិះ

☛ <u>សំនួរទី ១.</u> ដូចម្ដេចហៅថា សិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌ ?

✍ <u>**ចម្លើយ**</u> **ក. សិទ្ធិពលរដ្ឋ** : ជាសិទ្ធិរបស់មនុស្សក្នុងការរស់នៅ និងការពារខ្លួនស្របច្បាប់ ស្របតាមវប្បធម៌ទំនៀមទម្លាប់របស់ជាតិ ។

**ខ. សិទ្ធិនយោបាយ :** គឺសំដៅទៅលើការចូលរួមចំណែកក្នុងឆាកនយោបាយ ការចូលរួមចំណែកក្នុងកិច្ចការសង្គមផ្សេងៗ និងការចូលរួមកំណត់វាសនាប្រទេសជាតិរបស់ខ្លួន (សិទ្ធិចូលរួមបោះឆ្នោត សិទ្ធិក្នុងការបញ្ចេញមតិ...)។

**គ. សិទ្ធិសេដ្ឋកិច្ច** : ជាសិទ្ធិដែលផ្ដល់ និងអនុញ្ញាតិឱ្យប្រជាពលរដ្ឋមានការអភិវឌ្ឍផ្នែកជីវភាព ទ្រព្យសម្បត្តិក្នុងបំណងលើកតំកើងសុខមាលភាពប្រជាពលរដ្ឋ ។

**ឃ. សិទ្ធិសង្គមកិច្ច** : ជាសិទ្ធិដែលផ្ដល់ការគាំទ្រដល់ប្រជាពលរដ្ឋឱ្យទទួលបាននូវសន្តិសុខ សន្តិភាព និងសុខភាព ។

**ង. សិទ្ធិវប្បធម៌** : ជាសិទ្ធិដែលផ្ដល់ដល់ប្រជាពលរដ្ឋ ដើម្បី

ចូលរួមថែរក្សាទំនៀមទម្លាប់ ប្រពៃណី អក្សរ អក្សរសាស្ត្រ និងច្បាប់ទម្លាប់ផ្សេងៗ ។

**<u>សំនួរទី ២.</u> តើការធ្វើកូដកម្ម និងបាតុកម្មអហិង្សា ជាសិទ្ធិអ្វី ? ហេតុអ្វីចាំបាច់ត្រូវមានច្បាប់អនុញ្ញាត ក្នុងការធ្វើបាតុកម្មអហិង្សា ?**

**<u>ចម្លើយ</u>** ការធ្វើកូដកម្ម និងបាតុកម្មអហិង្សា ជាសិទ្ធិនយោបាយ ។

បានជាចាំបាច់ត្រូវមានច្បាប់អនុញ្ញាតក្នុងការធ្វើបាតុកម្មអហិង្សា ព្រោះ :

- ដើម្បីបង្ហាញពីសេរីភាពខាងផ្នែកនយោបាយរបស់ប្រទេស
- ដើម្បីបង្ហាញពីលទ្ធិប្រជាធិបតេយ្យ ។

**<u>សំនួរទី ៣. *ចូរគូសសញ្ញា✓ នៅក្នុងប្រអប់ចំពោះចម្លើយណាដែលអ្នកយល់ថាត្រឹមត្រូវ*</u>**

**<u>ចម្លើយ</u>** ក. សិទ្ធិនយោបាយ

☐ ស្នាក់នៅក្រៅប្រទេស ☐ ស្ម័គ្រចិត្តចូលបម្រើកងទ័ព

☑ ចូលជាសមាជិកសមាគម ។

ខ. សិទ្ធិសេដ្ឋកិច្ច

☑ ការដាក់ពាក្យបណ្តឹងទៅអាជ្ញាធរមានសមត្ថកិច្ចចំពោះក្រុម

ហ៊ុនមួយដែលរំលោភយកដី

☐ ទិញសម្ភារៈមករៀបចំពិធីបុណ្យចូលឆ្នាំខ្មែរ

☐ ចេញទៅកំសាន្តនៅឯបរទេស ។

គ. សិទ្ធិវប្បធម៌

☐ ការសុំសំបុត្រកំណើត ☐ ការសុំចូលបម្រើការងារ

☑ ការឆ្លាក់រូបបដិមា ។

ឃ. សិទ្ធិសង្គមកិច្ច

☑ ការសាងសង់សាលារៀន

☐ ម្ដាយខ្ញុំចែកដីស្រែទៅឱ្យប្អូនខ្ញុំ

☐ ជនមិនទាន់គ្រប់អាយុមិនមានសិទ្ធិចូលរួមបោះឆ្នោតទេ ។

**សំនួរទី ៤. តើប្រជាពលរដ្ឋខ្មែរម្នាក់ៗមានសិទ្ធិអ្វីខ្លះ?**

**ចម្លើយ** ប្រជាពលរដ្ឋខ្មែរម្នាក់ៗមានសិទ្ធិជាអាទិ៍ :

- **សិទ្ធិនយោបាយ :** ប្រជាពលរដ្ឋម្នាក់ៗមានសេរីភាពក្នុងការនិយាយស្ដី ក្នុងការផ្សព្វផ្សាយព័ត៌មាន ក្នុងការប្រជុំ ក្នុងការប្ដឹងតវ៉ា មានសិទ្ធិបោះឆ្នោត និង ឈរឈ្មោះឱ្យគេបោះឆ្នោត មានសិទ្ធិបង្កើតសមាគម និង គណបក្សនយោបាយ ។
- **សិទ្ធិសេដ្ឋកិច្ច :** ប្រជាពលរដ្ឋម្នាក់ៗមានកម្មសិទ្ធិផ្ទាល់ខ្លួន មានសិទ្ធិលក់ដូរទ្រព្យសម្បត្តិស្របច្បាប់ របស់ខ្លួន

មានសិទ្ធិជ្រើសរើសការងារសមស្របតាមសមត្ថភាពរបស់ខ្លួន ។

- **សិទ្ធិវប្បធម៌ :** ប្រជាពលរដ្ឋម្នាក់ៗទទួលការអប់រំ ទទួលព័ត៌មាន និយាយស្តី ប្រើប្រាស់ភាសា និងគោរពប្រពៃណីទំនៀមទម្លាប់របស់ខ្លួន ។

ប៉ុន្តែការប្រើប្រាស់សិទ្ធិសេរីភាពរបស់មនុស្សម្នាក់ៗ មិនត្រូវធ្វើឱ្យ ប៉ះពាល់ដល់របៀបរៀបរយសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខ និង ទំនៀមទម្លាប់ដ៏ល្អរបស់សង្គមជាដាច់ខាត ។

**សំនួរទី ៥.** ចូររៀបរាប់សិទ្ធិពលរដ្ឋដែលកំពុងអនុវត្តសព្វថ្ងៃ ?

**ចម្លើយ** សិទ្ធិពលរដ្ឋដែលកំពុងអនុវត្តសព្វថ្ងៃមានដូចចម្លើយសំណួរទី ៤ ខាងលើ ។

**សំនួរទី ៦.** តើសិស្សមានសិទ្ធិដូចគ្នានឹងមនុស្សចាស់ដែរ ឬទេ ?

**ចម្លើយ** សិស្សក៏មានសិទ្ធិដូចគ្នានឹងមនុស្សចាស់ដែរ ។

# ៤.៣ មេរៀនទី៣ ៖ សិទ្ធិ និងការទទួលខុសត្រូវ

## I. សំនួរត្រិះរិះ

**សំនួរទី ១.** ចូរគូសភ្ជាប់រវាងសិទ្ធិ និងការទទួលខុសត្រូវក្នុងតារាងខាងក្រោម ៗ

**ចម្លើយ**

| យើងមានសិទ្ធិក្នុង | ការទទួលខុសត្រូវរបស់យើងក្នុងការអនុវត្តសិទ្ធិ | ចម្លើយ |
|---|---|---|
| ក. ការដើរលេងកំសាន្ត<br>ខ. ការជ្រើសរើសមិត្តភក្តិ<br>គ. ការនិយាយធ្វើឱ្យអ្នកណាម្នាក់បាក់មុខ<br>ឃ. ការធ្វើចរាចរ<br>ង. ការទាមទារឱ្យឪពុកម្តាយផ្តល់ប្រាក់ច្រើនតាមការចង់បាន<br>ច. ការលេងសើចសប្បាយហោរកព្រៀវ | ១. អាចបង្កទំនាស់ធ្វើឱ្យបាត់បង់មិត្តភាពសាមគ្គីភាពបង្កើតសត្រូវជុំវិញខ្លួន<br>២. បើគ្មានកំណត់នឹងបាត់បង់ឱកាសរៀនសូត្រ ។<br>៣. បើស្តាប់តែពាក្យបញ្ជោរនឹងនាំឱ្យវិនាសដល់ខ្លួននិងនាំទុក្ខដល់ឪពុកម្តាយ ។ | ក > ២<br>ខ > ៣<br>គ > ១<br>ឃ > ៤<br>ង > ៥<br>ច > ៦ |

| | | |
|---|---|---|
| | ៤. មិនគោរពច្បាប់នឹងនាំឱ្យមានគ្រោះថ្នាក់ដល់ជីវិតរបស់ខ្លួននិងអ្នកដទៃ ។<br>៥. ទ្រព្យសម្បត្តិវិនាសហិនហោច គ្រួសារត្រូវទទួលការមើលងាយពីអ្នកជិតខាង ។<br>៦. បើហួសពេលម៉ោងនឹងត្រូវអ្នកជិតខាងប្តឹងទៅអាជ្ញាធរឱ្យផ្តន្ទាទោស ។ | |

<u>សំនួរទី ២.</u> ដូចម្តេចហៅថាសិទ្ធិ ? តើមនុស្សត្រូវមានសិទ្ធិអ្វីខ្លះ ?

<u>**ចម្លើយ**</u> ***សិទ្ធិ*** គឺជាអំណាចពិសេសរបស់មនុស្សគ្រប់ៗរូប ទោះចាស់ក្តី ក្មេងក្តី តូច ឬ ធំក្តី ។ ដែលធម្មជាតិផ្តល់ឱ្យតាំងពីកំណើតមកម្ល៉េះសំរាប់អោយមនុស្សការពារខ្លួនពីការរំលោភបំពាននៃអ្នកដទៃ និងអាចអោយមនុស្សធ្វើនេះ ឬ ធ្វើនោះក្នុងករណីស្របច្បាប់។ ម្យ៉ាងទៀតសិទ្ធិ គឺ ជាកេតនភ័ណ្ឌពិសិទ្ធ

ដែលធម្មជាតិផ្តល់ឱ្យមនុស្សមានលក្ខណៈខ្ពស់ជាងអំពីសត្វ។ បើគ្មានសិទ្ធិទេ មនុស្សមិនខុសពីសត្វឡើយ ហើយមិនអាចរស់បានផងក៏មាន។

**មនុស្សត្រូវមានសិទ្ធិ** មានជាអាទិ៍ :

- **សិទ្ធិនយោបាយ :** ប្រជាពលរដ្ឋម្នាក់ៗមានសេរីភាពក្នុងការនិយាយស្តី ក្នុងការផ្សព្វផ្សាយព័ត៌មាន ក្នុងការប្រជុំ ក្នុងការប្តឹងតវ៉ា មានសិទ្ធិបោះឆ្នោត និង ឈរឈ្មោះឱ្យគេបោះឆ្នោត មានសិទ្ធិបង្កើតសមាគម និង គណបក្សនយោបាយ ។
- **សិទ្ធិសេដ្ឋកិច្ច :** ប្រជាពលរដ្ឋម្នាក់ៗមានកម្មសិទ្ធិផ្ទាល់ខ្លួន មានសិទ្ធិលក់ដូរទ្រព្យសម្បត្តិស្របច្បាប់ របស់ខ្លួន មានសិទ្ធិជ្រើសរើសការងារសមស្របតាមសមត្ថភាពរបស់ខ្លួន ។
- **សិទ្ធិវប្បធម៌ :** ប្រជាពលរដ្ឋម្នាក់ៗទទួលការអប់រំ ទទួលព័ត៌មាន និយាយស្តី ប្រើប្រាស់ភាសា និង គោរពប្រពៃណីទំនៀមទម្លាប់របស់ខ្លួន ។

ប៉ុន្តែការប្រើប្រាស់សិទ្ធិសេរីភាពរបស់មនុស្សម្នាក់ៗ មិនត្រូវធ្វើឱ្យ ប៉ះពាល់ដល់របៀបរៀបរយសណ្ដាប់ធ្នាប់ សាធារណៈ សន្តិសុខ និង ទំនៀមទម្លាប់ដ៏ល្អរបស់ សង្គមជាដាច់ខាត ។

**សំនួរទី ៣. ដូចម្ដេចហៅថា ការទទួលខុសត្រូវ ? ចូរលើកឧទាហរណ៍ ។**

ចម្លើយ ដែលហៅថា **ការទទួលខុសត្រូវ** គឺជាការព្វកិច្ចរបស់បុគ្គលម្នាក់ៗដែលត្រូវធានារ៉ាប់រងអំពើរបស់ខ្លួន ដោយមានមូលដ្ឋាននៅលើសីលធម៌ និងច្បាប់ ហើយហ៊ានទទួលសារភាពថាខ្លួនជាអ្នកប្រព្រឹត្ត និងទទួលផលវិបាកនៃអំពើទាំងនោះ ។

**ឧទាហរណ៍ :** អ្នកបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍ដល់អ្នកដទៃ អ្នកត្រូវទទួលខុសត្រូវចំពោះសកម្មភាព ឬអំពើដែលខ្លួនបានប្រព្រឹត្តដូចជា ក្រោយពីកើតមានគ្រោះថ្នាក់ចរាចរណ៍ អ្នកត្រូវសងការខូចខាតទ្រព្យសម្បត្តិដល់ ‌អ្នករងគ្រោះ ។

**សំនួរទី ៤. តើសិទ្ធិ និងការទទួលខុសត្រូវមានទំនាក់ទំនងគ្នាដូចម្ដេចខ្លះ ? ចូរឱ្យឧទាហរណ៍ ។**

**ចម្លើយ** សិទ្ធិ និងការទទួលខុសត្រូវមានទំនាក់ទំនងគ្នាទៅវិញទៅមកដូចជា មនុស្សគ្រប់រូបសុទ្ធតែមានសិទ្ធិអាចធ្វើអ្វីៗបានដោយសេរី ប៉ុន្តែគេត្រូវមានការទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួនជាដាច់ខាត ។

មនុស្សម្នាក់ៗមានសិទ្ធិនិយាយស្តី តែក៏ត្រូវដឹងថា ការនិយាយស្តីនោះមិនត្រូវធ្វើឱ្យខូចដល់កិត្តិយស កេរ្តិ៍ឈ្មោះ ឬ ធ្វើឱ្យខូចប្រយោជន៍របស់អ្នកដទៃ ដោយសារការនិយាយរបស់ខ្លួននោះទេ ។ ចំពោះអ្នកដែលត្រូវគេនិយាយមិនល្អ ឬ បើកកកាយអាថ៌កំបាំងរបស់ខ្លួន នោះគេក៏មានសិទ្ធិការពារសេចក្តីថ្លៃថ្នូរ ឬកិត្តិយសរបស់គេដែរ ។ នៅពេលគេប្តឹង ការទទួលខុសត្រូវរបស់យើងគឺ ការសងជម្ងឺចិត្ត និងត្រូវសុំទោសគេវិញឱ្យស្របតាមច្បាប់ ។ ដូចនេះមនុស្សម្នាក់ៗអាចមានសិទ្ធិនិយាយអ្វីក៏បាន តែត្រូវមានការទទួលខុសត្រូវក្នុងការនិយាយស្តីក្នុងក្របខ័ណ្ឌសីលធម៌ និងសច្ចធម៌ ។

**ឧទាហរណ៍ :** អ្នកសារព័ត៌មាន ហ៊ានចុះផ្សាយអត្ថបទ

អ្វីមួយ គឺត្រូវតែហ៊ានទទួលខុសត្រូវចំពោះផលអាក្រក់ផ្សេងៗ ដែលអាចកើតចេញពីអត្ថបទនោះ ឬ ត្រូវហ៊ានទទួលខុសត្រូវចំពោះមុខច្បាប់ ។

**សំនួរទី ៥.** **ចូរសរសេររៀបរាប់អំពី "ការទទួលខុសត្រូវរបស់បុគ្គលម្នាក់ ចំពោះទង្វើរបស់ខ្លួន " ។**

**ចម្លើយ** សំណោរ "ការទទួលខុសត្រូវរបស់បុគ្គលម្នាក់ចំពោះទង្វើរបស់ខ្លួន " :

- ការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន និងក្នុងសីលធម៌រស់នៅល្អ
- ការទទួលខុសត្រូវលើសកម្មភាពរបស់ខ្លួន គឺការគោរពគោលការណ៍សីលធម៌ គោរពសិទ្ធិ និងផលប្រយោជន៍អ្នកដទៃ
- ការទទួលខុសត្រូវលើអំពើរបស់ខ្លួនទោះចេតនាក្តី ឬអចេតនាក្តី ( ដោយសេចក្តីក្លាហាន )
- ការហ៊ានទទួលកំហុសនូវរាល់ទង្វើដែលខ្លួនបានធ្វើ
- ការគោរពពាក្យសំដី និងកិច្ចសន្យារបស់ខ្លួន និងការប្រកាន់

ខ្ជាប់មនសិការការងារ

- ការទទួលខុសត្រូវចំពោះប្រពន្ធ កូន និងក្រុមគ្រួសារ
- ការទទួលខុសត្រូវចំពោះមាតា បិតា ពេលលោកចាស់ជរា ក្មានលទ្ធភាពធ្វើការ ...។

**សំណួរទី ៦.** តើការប្រើសិទ្ធិ សេរីភាពដោយខ្វះការទទួលខុសត្រូវនឹងកើតមានអ្វីខ្លះដល់ខ្លួន និងសង្គម?

**ចម្លើយ** ការប្រើសិទ្ធិ សេរីភាពដោយខ្វះការទទួលខុសត្រូវនឹងកើតមានដល់ខ្លួន និងសង្គម គឺនឹងនាំក្តីអន្តរាយមកដល់ខ្លួន និងសង្គម ។





សុ-ចិ-មុ-លិ !

## ៩.៣ មេរៀនទី៤ ៖ តួនាទីពលរដ្ឋក្នុងសហគមន៍

### I. សំនួរត្រិះរិះ

សំនួរទី ១. តើសកម្មភាពណាខ្លះក្នុងចំណោមសកម្មភាពខាងក្រោមនេះបង្ហាញតួនាទីរបស់ពលរដ្ឋនៅក្នុងសហគមន៍ដែលធានាការ ពិចារណាយ៉ាងតិច ៤ ? ចូរបញ្ជាក់ហេតុផល ។

ក. ប្រជាពលរដ្ឋនាំគ្នាធ្វើដំណើរទៅសាលាឃុំដើម្បីចូលរួមអនុម័តលើគម្រោងអភិវឌ្ឍឃុំ និងកំណត់តម្លៃសារពើពន្ធ ។

ខ. ពូម៉ៅជាប់រវល់រៀបការកូនរបស់គាត់នៅថ្ងៃនេះ ។ គាត់ប្រាប់កូនប្រុសគាត់ដែលមិនត្រូវម៉ោងរៀនពេលល្ងាចឱ្យទៅចូលរួមប្រជុំនៅសាលាឃុំជំនួសគាត់ ។

គ. កូនពូម៉ែន និងអ្នកនៅជិតផ្ទះគាត់នាំគ្នាទៅដាំត្នោតលើជម្រាលទំនប់ទឹក ផ្លូវជាតិដែលទើបកសាងហើយថ្មី

ឃ. អ្នកភូមិខ្លះបានយកទឹកសល់ពីការប្រើប្រាស់ដូចជាទឹកលាងចាន ទឹកបោកគក់ខោអាវ ចាក់ទៅលើផ្លូវលំ

ង. យុវជនមួយក្រុមបានផឹកស្រាស្រវឹងយ៉ាងខ្លាំង

ហើយនាំគ្នាបើកម៉ូតូយ៉ាងលឿនត្រឡប់ទៅផ្ទះវិញដោយមិនគោរពស្លាកសញ្ញាចរាចរណ៍ ។

ច. មនុស្សមួយក្រុមបានទិញនំចំណីមកហូបរួចក៏បោះចោលកាកសំណល់ពាសវាលពាសកាល ។

ឆ. ពូសុខមិនបានទៅចូលរួមបោះឆ្នោតទេ ដោយសារគាត់ជាប់រវល់ធ្វើការ ។

**ចម្លើយ** សកម្មភាពដែលបង្ហាញតួនាទីរបស់ពលរដ្ឋនៅក្នុងសហគមន៍ដែលទាក់ទង និងវិស័យទាំង ៤ គឺ ចំណុច **ក** និង **គ** ។

**សំនួរទី ២.** តើពលរដ្ឋត្រូវមានតួនាទី និងការទទួលខុសត្រូវអ្វីខ្លះចំពោះសហគមន៍ ?

**ចម្លើយ** ពលរដ្ឋត្រូវមានតួនាទី និងការទទួលខុសត្រូវចំពោះសហគមន៍ គឺ :

- ចូលរួមបង្កបង្កើនផល
- ចូលរៀនសូត្រទទួលការអប់រំផ្សេងៗ
- រក្សាប្រពៃណីទំនៀមទម្លាប់ល្អរបស់សហគមន៍
- ការចូលរួមសំអាតបរិស្ថាន អនាម័យ ការថែរក្សាសុខភាព

- ចូលរួមបោះឆ្នោតជ្រើសរើសអ្នកតំណាង និងអ្នកដឹកនាំសហគមន៍
- គោរព និងការពារសិទ្ធិមនុស្ស
- ការពារសុវត្ថិភាព ការចូលរួមជួយរក្សាការពារសណ្ដាប់ធ្នាប់សន្តិសុខសាធារណៈ ។ល។

**<u>សំនួរទី ៣.</u> តើអ្នកបានចូលរួមក្នុងសកម្មភាពផ្សេងៗដើម្បីចូលរួមជួយអភិវឌ្ឍសហគមន៍ដែរ ឬទេ ? ចូរអ្នកសរសេរតួនាទីសំខាន់ៗ របស់អ្នកចំពោះសហគមន៍ឱ្យបានប្រាំល្បះ ។**

**<u>ចម្លើយ</u>** ខ្ញុំបានចូលរួមក្នុងសកម្មភាពផ្សេងៗដើម្បីចូលរួមជួយអភិវឌ្ឍសហគមន៍ខ្ញុំ ដូចជា :

- ចូលរួមក្នុងការសំអាតបរិស្ថាន
- ចូលរួមក្នុងការផ្ដល់គំនិត បញ្ចេញមតិដើម្បីធ្វើការអភិវឌ្ឍសហគមន៍
- ចូលរួមក្នុងការថែរក្សាសុខភាព និងអនាម័យ
- ចូលរួមជួយថែរក្សាសណ្ដាប់ធ្នាប់ សន្តិសុខសាធារណៈក្នុងសហគមន៍
- ចូលរួមធ្វើឱ្យគ្រួសារមានសុភមង្គល គ្មានអំពើហិង្សា ។

☛ <u>សំនួរទី ៤.</u> ហេតុអ្វីបានជាតួនាទី និងការទទួលខុសត្រូវរបស់ពលរដ្ឋជាផ្នែកមួយដ៏សំខាន់នៃលទ្ធិប្រជាធិបតេយ្យ ?

<u>ចម្លើយ</u> បានជាតួនាទី និងការទទួលខុសត្រូវរបស់ពលរដ្ឋជាផ្នែកមួយដ៏សំខាន់នៃលទ្ធិប្រជាធិបតេយ្យ ប្រសិនបើមនុស្សគ្មានការទទួលខុសត្រូវនោះទេសង្គមមួយ និងមិនអាចរីកចម្រើនបានឡើយហើយក៏ធ្វើឱ្យសង្គមមានភាពអនាធិបតេយ្យ ដូចនេះលទ្ធិប្រជាធិបតេយ្យក៏មិនអាចដំណើរការបានល្អប្រសើរដែរ ។



# ៩.៣ មេរៀនទី៩ : ច្បាប់ការងារ

## I. សំនួរត្រិះរិះ

**សំនួរទី ១. ហេតុអ្វីបានជាត្រូវមានច្បាប់ការងារ ?**

ចម្លើយ បានជាមានច្បាប់ការងារព្រោះដើម្បីគ្រប់គ្រងរាល់ទំនាក់ទំនងដែលកើតចេញពីច្បាប់កិច្ចសន្យាការងាររវាងនិយោជក និង និយោជិក ។

**សំនួរទី ២. តើកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា មានលក្ខណៈខុសគ្នាពីកិច្ចសន្យាការងារមិនកំណត់ថិរវេលាដូចម្តេចខ្លះ ?**

ចម្លើយ កិច្ចសន្យាការងារសន្យាការងារដែលមានកំណត់ថេរវេលាមានលក្ខណៈខុសគ្នាពីកិច្ចសន្យាការងារមិនកំណត់ថេរដូចជា :

- កិច្ចសន្យាការងារកំណត់ថេរវេលា : ជាកិច្ចសន្យាធ្វើឡើងដោយមានការព្រមព្រៀងគ្នារវាងនិយោជក និងនិយោជិកមានការកំណត់ពេលវេលាច្បាស់លាស់ និង

កាលបរិច្ឆេទបញ្ចប់កិច្ចសន្យាច្បាស់លាស់ ។

- កិច្ចសន្យាការងារសន្យាការងារមិនកំណត់ថេរវេលា : ជាកិច្ចសន្យាដែលគ្មានកំណត់ពេលវេលា និងកាលបរិច្ឆេទច្បាស់លាស់ ហើយកិច្ចសន្យានេះអាចរំលាយតាមកាលឆន្ទៈភាគតែម្ខាងបាន ។

**<u>សំនួរទី ៣.</u> តើនិយោជកអាចឱ្យកុមារម្នាក់ដែលមានអាយុ ១៥ឆ្នាំធ្វើការងារអ្វីខ្លះនៅក្នុងសិប្បកម្ម ឬ រោងចក្ររបស់ខ្លួន ? ចូររកឧទាហរណ៍ ២**

**<u>ចម្លើយ</u>** និយោជកអាចឱ្យកុមារម្នាក់ដែលមានអាយុ ១៥ ឆ្នាំធ្វើការងារនៅក្នុងសិប្បកម្មឬរោងចក្ររបស់ខ្លួននូវការងារណាដែលមិនប៉ះពាល់ដល់សុខភាព និង ការសិក្សាឡើយ ។

**<u>សំនួរទី ៤.</u> ហេតុអ្វីចាំបាច់ត្រូវមានការហ្វឹកហ្វឺនកូនជាង ? តើការហ្វឹកហ្វឺនកូនជាងត្រូវមានលក្ខខណ្ឌអ្វីខ្លះ ?**

**<u>ចម្លើយ</u>** បានជាចាំបាច់ត្រូវមានការហ្វឹកហ្វឺនកូនជាង

ព្រោះ ដើម្បីឱ្យពួកគេមានជំនាញច្បាស់លាស់មុន និង បំពេញការងារ ។

❖ ការហ្វឹកហ្វឺនកូនជាងត្រូវមានលក្ខខណ្ឌបញ្ជាក់ដូចជា :

- ឈ្មោះ អាយុ វិជ្ជាជីវៈ ទីលំនៅរបស់គ្រូ និងសិស្ស
- ឈ្មោះ អាយុ ទីលំនៅរបស់អាណាព្យាបាល
- លក្ខខណ្ឌនៃការផ្តល់កម្រៃ អាហារ លំនៅដ្ឋានជាដើម
- កាតព្វកិច្ចរវាងគ្រូ និងកូនជាង ។ល។

**សំនួរទី ៥.**ហេតុអ្វីបានជាកម្មករនិយោជិត និងនិយោជក ត្រូវចុះកិច្ចសន្យាមុននឹងធ្វើការងារអ្វីមួយ ?

**ចម្លើយ** បានជាកម្មករនិយោជិក និង និយោជកត្រូវចុះ កិច្ចសន្យាមុននឹងធ្វើការងារព្រោះ ដើម្បីឱ្យមានទំនាក់ទំនងគ្នារវាងអ្នកទាំងពីរ ដែលចង់ធ្វើការកំណែទម្រង់នៅពេលខាងមុខតាមការព្រមព្រៀងរបស់អ្នកទាំងពីរ ។

**សំនួរទី ៦.** តើនៅពេលមានគ្រោះថ្នាក់ការងារ កម្មករនិយោជិត និងក្រសួងទទួលបន្ទុកការងារត្រូវធ្វើដូចម្តេចខ្លះ ?

ចម្លើយ នៅពេលដែលមានគ្រោះថ្នាក់កម្មករនិយោជិក និង ក្រសួងទទួលបន្ទុកការងារត្រូវ :

- ជូនដំណឹងជាបន្ទាន់ទៅនាយកដ្ឋានពេទ្យការងារ
- ធ្វើទំនាក់ទំនងជាបន្ទាន់ទៅសហគ្រាសកើតហេតុ
- ចាត់ចែង និង ពិនិត្យអង្កេតដល់កន្លែងកើតហេតុ
- ស្នើសុំជំនួយពីអ្នកឯកទេស ។

សំនួរទី ៧. ក្នុងបណ្តាជនរងគ្រោះថ្នាក់ខាងក្រោម តើគ្រោះថ្នាក់មួយណាជាគ្រោះថ្នាក់ការងារ ?ព្រោះអ្វី?

ក. សីហាធ្វើការនៅឡឥដ្ឋបានថ្ពុលដៃចូលក្នុងម៉ាស៊ីនកាត់ឥដ្ឋបណ្តាលឱ្យដាច់ដៃ ។

ខ. វិចិត្រជាកម្មកររោងចក្រកាត់ដេរបានផឹកស្រាស្រវឹងនៅពេលហូបបាយ ហើយមានទំនាស់ជាមួយអ្នកដទៃ ត្រូវគេវាយឱ្យមានរបួស ។

គ. តារាធ្វើការនៅរោងចក្រផលិតបារី ។ ដោយសារថ្នាំជក់ធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់តារាហើយធ្លាក់ខ្លួនឈឺ ។

ប. នារីធ្វើដំណើរតាមរថយន្តដើម្បីលក់ផលិតផល ប្រស់ក្រុមហ៊ុន ៗ ជាចៃដន្យរថយន្តនោះក្រឡាប់ បណ្តាលឱ្យនាងមានរបួសដៃ ៗ

<u>ចម្លើយ</u> ក្នុងបណ្តាជនរងគ្រោះខាងក្រោម គ្រោះថ្នាក់ការងារគឺចំនុច <u>ក.គ.ឃ</u> ព្រោះគ្រោះថ្នាក់នេះកើតឡើងនៅពេលដែលសីហាកំពុងបំពេញការងារជាក់ស្តែង ។



## ជ.៣ មេរៀនទី៦ : ច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ

### I. <u>សំនួរត្រិះរិះ</u>

☛ <u>សំនួរទី ១.</u> តើអាពាហ៍ពិពាហ៍ជាអ្វី ? ហេតុអ្វីបានជាសង្គមតម្រូវឱ្យបុរស និងស្ត្រីចាំបាច់ត្រូវរៀបអាពាហ៍ពិពាហ៍ ?

✍ <u>ចម្លើយ</u> ក. អាពាហ៍ពិពាហ៍ = អាពាហ៍ + ពិពាហ៍

- **អាពាហ៍** : នាំកូនប្រុសទៅរៀបការនៅផ្ទះកូនស្រី
- **ពិពាហ៍** : នាំកូនស្រីទៅរៀបការនៅផ្ទះកូនប្រុស ។

➤ ហេតុនេះអាពាហ៍ពិពាហ៍ គឺជាការផ្សំផ្គុំយ៉ាងឱឡារិកជាផ្លូវការរវាងបុរសម្នាក់ និងស្រីម្នាក់ ដើម្បីបង្កើតគ្រួសារថ្មីមួយទៀត ។

បានជាសង្គមតម្រូវឱ្យបុរស និង ស្ត្រីចាំបាច់ត្រូវរៀបអាពាហ៍ពិពាហ៍ព្រោះ ដើម្បីឱ្យត្រឹមត្រូវតាមផ្លូវច្បាប់ និង តាមប្រពៃណីទំនៀមទំលាប់ ។

☛ <u>សំនួរទី ២.</u> ដើម្បីឱ្យអាពាហ៍ពិពាហ៍ប្រព្រឹត្តទៅតាមផ្លូវច្បាប់ តើគូស្រករទាំងពីរត្រូវធ្វើដូចម្តេចខ្លះ ?

**ចម្លើយ** ដើម្បីឱ្យអាពាហ៍ពិពាហ៍ប្រព្រឹត្តតាមផ្លូវច្បាប់ គូស្រករត្រូវទៅចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅមុខមន្ត្រីអត្រានុកូលដ្ឋាននៅគេហដ្ឋានខាងស្រី ។

**សំនួរទី ៣.** បុរស និងស្ត្រីមុននឹងឈានទៅដល់ការរៀបអាពាហ៍ពិពាហ៍ តើគេគួរតែគោរពតាមលក្ខខណ្ឌដូចម្តេចខ្លះ ?

**ចម្លើយ** បុរស និងស្ត្រីមុននឹងឈានទៅដល់ការរៀបអាពាហ៍ពិពាហ៍គេត្រូវគោរពលក្ខខណ្ឌដូចតទៅ :

ក. *លក្ខខណ្ឌសម្ភារៈ*

- ត្រូវមានទ្រព្យសម្បត្តិ ធនធាន
- ត្រូវមានសុខភាពល្អ គ្មានជំងឺឆ្លងផ្សេងៗ ឬជំងឺសួពូជ
- ត្រូវមានចំណេះដឹង សមត្ថភាពវិជ្ជាជីវៈ
- មានមុខរបរ អាជីវកម្ម ឬការងារផ្សេងៗ
- ត្រូវមានទីជំរកត្រឹមត្រូវ

ខ. *លក្ខខណ្ឌវេទនា*

- ត្រូវស្គាល់ចិត្តគ្នាទៅវិញទៅមក ចេះស្រឡាញ់គ្នា

ទៅវិញទៅមក

- គ្មានការបង្ខិតបង្ខំ ពីឪពុកម្តាយ ឬបង្ខំគ្នាទៅវិញទៅមក
- មានសេរីភាពពេញលេញក្នុងការជ្រើសរើសដៃគូរជីវិត

គ. *លក្ខខណ្ឌសង្គម*

- ត្រូវរៀបចំតាមទំនៀមទម្លាប់ប្រពៃណីរបស់សង្គម
- ត្រូវចុះសំបុត្រអាពាហ៍ ពិពាហ៍ជាផ្លូវការ( អតាស៊ីវិល មានការទទួលដឹងឮពីរដ្ឋអំណាច ឬអាណាព្យាបាលទាំងសងខាង

ឃ. *លក្ខខណ្ឌសីលវិជ្ជា ឬ សីលលក្ខខណ្ឌ*

- មិនប្រើអំពើហឹង្សាក្នុងគ្រួសារ
- ត្រូវចេះយោគយល់ អធ្យាស្រ័យគ្នាទៅវិញទៅមក
- ត្រូវចេះរក្សាគ្នាលុះគ្រាចុងក្រោយនៃជីវិត
- មិនបំពានពេលមានគំណាម
- គោរពសិទ្ធិសម្រេចក្នុងការកំណត់ចំនួនកូន
- ស្មោះត្រង់នឹងគ្នា( ស្មោះស្មោះមួយនឹងមួយមិនព្រួយ

ឆ្លងជំងឺអេដស៍)

- ត្រូវមានគុណធម៌គ្រប់យ៉ាង ទើបអាចរកសុភមង្គលឃើញ ។

**សំនួរទី ៤. តើមានលក្ខខណ្ឌអ្វីខ្លះដែលបុរស និងស្ត្រីមិនអាចរៀបអាពាហ៍ពិពាហ៍បាន ?**

**ចម្លើយ** លក្ខខណ្ឌដែលបុរស និងស្ត្រីមិនអាចរៀបអាពាហ៍ពិពាហ៍បានមាន :

- បុគ្គលមានភេទដូចគ្នា
- បុគ្គលគ្មានពលានុភាពនៃលិង្គ
- បុគ្គលមានជំងឺឃ្លង់ របេង មហារីកកាមរោគ ដែលមិនទាន់ព្យាបាលជាដាច់ ជាពិសេសជម្ងឺមហារីក និងជម្ងឺអេដស៍
- ជនវិកលចរិត ឬជនមិនដឹងខុសត្រូវ
- បុគ្គលមានចំណងអាពាហ៍ ពិពាហ៍ពីមុន
- បុគ្គលដែលជាប់ជាចំណងញាតិពន្ធលោហិត ឬញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ ទោះជាចំណង៖ ង នោះមានខាន់ស្លាក្ត ឥតខាន់ស្លាក្ត ឬសាច់ចិញ្ចើ្តក្ត

- បុគ្គលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រំលាយ

**សំនួរទី ៥.** **ដើម្បីឱ្យអាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជា និងជនបរទេសប្រព្រឹត្តទៅតាមផ្លូវច្បាប់ តើគេត្រូវធ្វើឡើងតាមរបៀបដូចម្តេចខ្លះ ?**

**ចម្លើយ** ដើម្បីឱ្យអាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជា និងជនបរទេសប្រព្រឹត្តទៅតាមផ្លូវច្បាប់គេត្រូវ ប្រព្រឹត្តទៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៃស្ថានទូត នៃប្រទេសទាំងពីរ ។

**សំនួរទី ៦.** **តើច្បាប់ឯកពន្ធភាពមានសារប្រយោជន៍អ្វីខ្លះ ដល់សង្គម ?**

**ចម្លើយ** ច្បាប់ឯកពន្ធភាពមានសារប្រយោជន៍ដូចជាការពារសេចក្តីថ្លៃថ្នូរ ពង្រឹងសុខមាលភាព និងសុភមង្គលក្នុងគ្រួសារ ។

**សំនួរទី ៧.** **តើឪពុកម្តាយមានភាតព្វកិច្ចអ្វីខ្លះក្នុងការចិញ្ចឹមកូន ? ចូរលើកឧទាហរណ៍បញ្ជាក់ ៥**

**ចម្លើយ** ឪពុកម្តាយមានភាតព្វកិច្ចក្នុងការចិញ្ចឹមកូន

- ស្រឡាញ់ថ្នាក់ថ្នម និង យោគយល់ដល់កូនទាំងអស់ស្មើៗគ្នា
- ពង្រឹងការអប់រំខាងស្មារតី សីលធម៌វិន័យផ្ទាល់ខ្លួន និង សាសនា
- ត្រួតពិនិត្យរាល់សកម្មភាព និង ការកំសាន្តរបស់កូន
- អប់រំកូនឱ្យឧស្សាហ៍ព្យាយាមអត់ធ្មត់ សន្សំសំចៃ និង មានជំនឿលើខ្លួនឯង
- ជួយជម្រុញ លើកទឹកចិត្តធ្វើកិច្ចការផ្ទះ កិច្ចការសាលារៀន និង កិច្ចការសង្គម
- បង្រៀនគេពីការកិច្ចជាពលរដ្ឋ និង ធ្វើឱ្យពួកគេមានគំនិតចេះស្រឡាញ់ជាតិ
- ផ្តល់ដំបូន្មានល្អៗ ចំពោះការអភិវឌ្ឍ និងសុខុមាលភាព
- ធ្វើជាគំរូល្អដល់ពួកគេ
- ទុកដាក់ពួកគេឱ្យមានគូស្រករតាមប្រពៃណី និងចែកទ្រព្យសម្បត្តិ ប្រសិនបើម្តាយឪពុកមានលទ្ធភាព ។

**សំនួរទី ៨.** តើកូនត្រូវមានភារកិច្ចអ្វីខ្លះក្នុងការបម្រើនិងថែរក្សាឪពុកម្តាយ ? ចូរលើកឧទាហរណ៍បញ្ជាក់ៗ

**ចម្លើយ** កូនមានភារកិច្ចក្នុងការបម្រើនិងថែទាំឪពុកម្ដាយ ដូចជាស្រឡាញ់ និង គោរពលោកទាំងពីរជាពិសេសការផ្គត់ផ្គង់តាមសេចក្ដីត្រូវការរបស់លោកទាំងពីរ ។
**ឧទាហរណ៍** នៅពេលមានការងារធ្វើកូនត្រូវមានភារកិច្ចចិញ្ចឹមបីបាច់ថែរក្សាឪពុកម្ដាយ ។

**សំនួរទី ៩.** ចូរសិក្សាស្រាវជ្រាវពិធីរៀបអាពាហ៍ពិពាហ៍តាមទំនៀមទម្លាប់ប្រពៃណីជាតិខ្មែរតាំងពីបុរាណហើយសរសេររៀបរាប់តាមលំដាប់លំដោយនៃពិធីនេះ ?

**ចម្លើយ** ដំបូងផ្ដើមពីការស៊ើបសួរ> ចែចូវ> ស្ដីដណ្ដឹង > ភ្ជាប់ពាក្យ > ចូលរោងការ (ដោយសង្ខេបគោលៗ) ។

**សំនួរទី ១០. តើអ្វីទៅហៅថា ឯកពន្ធភាព ?**

**ចម្លើយ** **ឯកពន្ធភាព** ជាចំណងអាពាហ៍ពិពាហ៍ស្ម័គ្រចិត្តដែលបុរសមានប្រពន្ធតែមួយ ឯស្ត្រីមានប្ដីតែមួយ ដោយមានចុះបញ្ជីអាពាហ៍ពិពាហ៍ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ស្របតាមលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ។ (តាមមាត្រា ៣)

## ៣ មេរៀនទី៧ : ក្រមនីតិវិធីរដ្ឋប្បវេណី

. សំនួរត្រិះរិះ

**សំនួរទី ១.** តើបណ្តឹងរដ្ឋប្បវេណីជាអ្វី ?

**ចម្លើយ បណ្តឹងរដ្ឋប្បវេណី** : ជាបណ្តឹងដែលទាក់ទងនឹងសិទ្ធិឯកជន ឬជាបណ្តឹងដែលទាមទារឱ្យជនប្រព្រឹត្តបទល្មើសជួសជុលសងការខូចខាតផ្នែកសម្ភារៈ ការព្យាបាលរូបរាងកាយ និងការសងជម្ងឺចិត្តទៅតាមភាពជាក់ស្តែងនៃការរងគ្រោះសមល្មមនឹងកំហូចខាតដែលខ្លួនបានបាត់បង់។

**សំនួរទី ២.** តើគោលបំណងនៃក្រមនីតិវិធីរដ្ឋប្បវេណីមានអ្វីខ្លះ ?

**ចម្លើយ** គោលបំណងនៃរដ្ឋប្បវេណីមាន :

- ឱ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណីដោយផ្អែកលើច្បាប់
- ទាមទារឱ្យមានការសាក់សួរ ឬកោះហៅទាំងដើមចោទនិងចុងចោទមុនជម្រះក្តីក្នុងករណីណាក៏ដោយ

- ឱ្យសងការខូចខាតជាថវិកា ឬសងជាជម្ងឺចិត្តដល់ជនរង គ្រោះ ។

សំនួរទី ៣. តើជនណាខ្លះដែលមានសមត្ថភាពក្នុងការ ធ្វើបណ្តឹង ?

ចម្លើយ អ្នកដែលមានសម្ថភាពធ្វើបណ្តឹង លុះត្រាតែ :

- បុគ្គលដែលមានសិទ្ធិ និងករណីយកិច្ចតាមបញ្ញត្តិនៃក្រម នីតិវិធីរដ្ឋប្បវេណី និង ច្បាប់ផ្សេងៗអាចជាដើមចោទឬ ចុងចម្លើយក្នុងបណ្តឹងរដ្ឋប្បវេណី

- បុគ្គលដែលមានសម្ថភាពធ្វើសកម្មភាពដោយខ្លួនឯងតាម បញ្ញត្តិនៃក្រមរដ្ឋប្បវេណី និងច្បាប់ផ្សេងទៀត ។

សំនួរទី ៤. តើប្រាក់ប្រដាប់ក្តីជាអ្វី ហើយវាមាន សារៈសំខាន់ដូចម្តេចខ្លះ ? ចូររៀបរាប់ ?

ចម្លើយ ប្រាក់ប្រដាប់ក្តី ជាប្រាក់ពន្ធសរុបដែលត្រូវចំនាយ ផ្សេងៗក្នុងរឿងរដ្ឋប្បវេណី ។ ហើយវាមានសារៈសំខាន់ ដូចជា :

- សម្រាប់ធ្វើលិខិត ឯកសារបណ្តឹងផ្សេងៗ

- សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃជាដើម ។

**<u>សំនួរទី ៥.</u> តើហេតុអ្វីបានជាមានភាគីបណ្តឹងប្តឹងឧទ្ធរណ៍ ? ហើយគេត្រូវធ្វើបណ្តឹងឧទ្ធរណ៍ដូចម្តេច ?**

**<u>ចម្លើយ</u>** បានជាមានភាគីបណ្តឹងប្តឹងឧទ្ធរណ៍ព្រោះ មានការមិនសុខចិត្ត នឹងការសម្រេចក្តីរបស់តុលាការថ្នាក់ដំបូង ឬតុលាការខេត្ត ក្រុង ។

ដើម្បីធ្វើបណ្តឹងឧទ្ធរណ៍គេត្រូវ ដាក់ពាក្យបណ្តឹងទៅតុលាការដើមដែលបានជំនុំជម្រះលើកទីមួយហើយ ហើយមិនឯកភាពនូវការសម្រេចក្តីនោះ ។

**<u>សំនួរទី ៦.</u> ចូរពន្យល់ពីសិទ្ធិរបស់សាលាឧទ្ធរណ៍ចំពោះការធ្វើបណ្តឹងឧទ្ធរណ៍ ?**

**<u>ចម្លើយ</u>** សិទ្ធិរបស់សាលាឧទ្ធរណ៍ចំពោះការធ្វើបណ្តឹងឧទ្ធរណ៍ ក្នុងករណីដែលពាក្យបណ្តឹងឧទ្ធរណ៍ មិនបានត្រឹមត្រូវតាមរបៀបបណ្តឹងឧទ្ធរណ៍ ដូចជាពុំបានកែតម្រូវចំណុចដែលខ្វះខាត ឬមិនបានបង់ពន្ធសម្រាប់ដាក់ពាក្យបណ្តឹងឧទ្ធរណ៍ជាដើម តុលាការនៃបណ្តឹងឧទ្ធរណ៍មានសិទ្ធិលុបចោលបណ្តឹងឧទ្ធរណ៍នោះដោយដីកាសម្រេច ។

តុលាការនៃបណ្តឹងឧទ្ធរណ៍មានសិទ្ធិច្រានចោលបណ្តឹងឧទ្ធរណ៍ ក្នុងករណីដែលយល់ឃើញថាសាលក្រមនៃការជំនុំជម្រះលើកទី ១ ត្រឹមត្រូវ ។ ទោះបីជាក្នុងករណីដែលសម្រាងហេតុនៃសាលក្រមជំនុំជម្រះលើកទី ១មិនត្រឹមត្រូវក៏ដោយ ក៏តុលាការនៃបណ្តឹងឧទ្ធរណ៍មានសិទ្ធិច្រានចោលបណ្តឹងឧទ្ធរណ៍នោះដែរ ប្រសិនបើតុលាការនេះយល់ឃើញថាសេចក្តីសម្រេចបញ្ចប់នៃសាលក្រមនោះត្រឹមត្រូវដោយផ្អែកលើសម្អាងហេតុផ្សេងទៀត ។

តុលាការនៃបណ្តឹងឧទ្ធរណ៍មានសិទ្ធិលុបចោលសាលក្រមនៃការជុំនំជម្រះលើកទី ១ ក្នុងករណ៍ដូចជា សាលក្រមនៃការជំនុំជម្រះលើកទីមួយមិនត្រឹមត្រូវ ឬ នីតិវិធីនៅសាលាដំបូងផ្ទុយនឹងច្បាប់ធ្ងន់ធ្ងរ ។ ក្នុងករណីនេះតុលាការនៃបណ្តឹងឧទ្ធរណ៍នឹងធ្វើការជំនុំជម្រះលើបណ្តឹងនោះលើកលែងតែការបញ្ជូនរឿងក្តីនោះត្រឡប់ទៅសាលាដំបូងវិញក្នុងករណីចាំបាច់បន្ថែមទៀតអំពីរឿងក្តីនោះ។

**<u>សំនួរទី ៧.</u> ដូចម្តេចហៅថាបណ្តឹងសាទុក្ខ ? ហេតុអ្វីបានជាមានភាគីបណ្តឹង ប្តឹងសាទុក្ខ ?**

<u>**ចម្លើយ**</u> ដែលហៅថា**បណ្តឹងសាទុក្ខ** ជាបណ្តឹងសើរើ ឬបណ្តឹងសុំតវ៉ា សុំឱ្យពិនិត្យឡើងវិញ បដិសេធសេចក្តី

សម្រេចរបស់សាលដីកាដែលសម្រេចជាស្ថាពរដោយសាលាឧទ្ធរណ៍ ។

បានជាមានភាគីបណ្តឹង ប្តឹងសាទុក្ខព្រោះ ដោយសារភាគីបណ្តឹងមិនយល់ព្រមទទួលសាលដីកានៃការជម្រះក្តីរបស់សាលាជម្រះក្តីចុងក្រោយ (តុលាការកំពូល). ។

__សំនួរទី ៨.__ **តើបណ្តឹងសាទុក្ខ និងបណ្តឹងជំទាស់ខុសគ្នាដូចម្តេចខ្លះ ?**

__ចម្លើយ__ ភាពខុសគ្នានៃបណ្តឹងសាទុក្ខ និងបណ្តឹងជំទាស់

ក. បណ្តឹងសាទុក្ខ : - ជាបណ្តឹងសើរើ ឬ បណ្តឹងសុំតវ៉ាសុំឱ្យពិនិត្យឡើងវិញ បដិសេធសេចក្តីសម្រេចរបស់សាលដីកាដែលសម្រេចជាស្ថាពរដោយសាលាឧទ្ធរណ៍

- អាចធ្វើឡើងនៅតុលាការកំពូល ចំពោះសាលដីកាចុងក្រោយ ដែលបានជំនុំជម្រះលើកទី២នៅសាលាឧទ្ធរណ៍ ឬ កាជម្រះក្តីលើកទី ១ នៅសាលាដំបូងដោយភាគីបណ្តឹងទាំងសងខាងបានឯកភាពគ្នា ឬព្រមព្រៀងគ្នា មិនប្តឹងឧទ្ធរណ៍ដោយរក្សាសិទ្ធិប្តឹងសាទុក្ខនៅតុលាការកំពូល

- អំឡុងពេលសម្រាប់ធ្វើបណ្តឹងសាទុក្ខមានរយៈពេល ១ខែ

**ខ. បណ្តឹងជំទាស់** : - ជាបណ្តឹងដែលកើតឡើងពីការ

មិនយល់ព្រមចំពោះសាលក្រម ឬជាពាក្យតវ៉ាសុំបដិសេធសេចក្តីសម្រេចរបស់ចៅក្រម ដែលត្រូវបើកឱ្យគូវក្តីមិនមានវត្តមាននៅពេលជំនុំជម្រះ ។

- ធ្វើឡើងនៅតុលាការដើម ។
- បណ្តឹងជំទាស់ត្រូវធ្វើនៅក្នុងអំឡុងពេល ១ សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលដំណឹងអំពីដីកាសម្រេច ហើយអំឡុងពេលនេះមិនអាចពន្យារបានឡើយ ។

**<u>សំនួរទី</u> <u>៩.</u> តើបណ្តឹងរដ្ឋប្បវេណី និងបណ្តឹងព្រហ្មទណ្ឌខុសគ្នាដូចម្តេចខ្លះ ?**

**<u>ចម្លើយ</u>** បណ្តឹងរដ្ឋប្បវេណី និង បណ្តឹងព្រហ្មទណ្ឌខុសគ្នាគឺ :

**ក - បណ្តឹងរដ្ឋប្បវេណី** : ទាក់ទងនឹងសិទ្ធិឯកជនឬ បណ្តឹងដែលទាមទារឱ្យជនប្រព្រឹត្តបទល្មើស ជួសជុលសងការខូចខាតព្យាបាលរូបរាងកាយ និង សងជម្ងឺចិត្ត ។

**ខ- បណ្តឹងព្រហ្មទណ្ឌ** : ទាក់ទងនឹងបទល្មើសដែលបង្កគ្រោះថ្នាក់ដល់មនុស្ស សង្គម និង មានការដាក់ទណ្ឌកម្ម ឬ ផ្តន្ទាទោសចំពោះជនប្រព្រឹត្ត ។

៤.៣ មេរៀនទី៨ : ក្រមនីតិវិធីព្រហ្មទណ្ឌ

# I. សំនួររំលឹក

**សំនួរទី ១.** ដូចម្ដេចហៅថាក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ?

**ចម្លើយ** - ក្រមព្រហ្មទណ្ឌ ឬ ច្បាប់ព្រហ្មទណ្ឌ គឺជាបទបញ្ញត្តិសម្រាប់កំណត់អំពើទាំងឡាយណាដែលជាបទល្មើសដោយរួមទាំងជាតុផ្សំនៃបទល្មើសដែលបង្កគ្រោះថ្នាក់ដល់មនុស្ស សង្គម និងការដាក់ទណ្ឌកម្ម ឬផ្ដន្ទាទោសចំពោះជនប្រព្រឹត្តបទល្មើស និងបណ្ដាករណីដែលត្រូវអនុវត្តទៅលើជនដែលត្រូវទទួលទោស ។

- ក្រមនិតិវិធីព្រហ្មទណ្ឌ គឺជាការកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរព និង ប្រតិបត្តិដោយម៉ត់ចត់។

**សំនួរទី ២.** ចូរបង្ហាញភាពខុសគ្នារវាងបណ្ដឹងអាជ្ញា និង បណ្ដឹងរដ្ឋប្បវេណី ?

**ចម្លើយ** ភាពខុសគ្នារវាងបណ្ដឹងអាជ្ញា និង បណ្ដឹងរដ្ឋប្បវេណី :

ក. បណ្ដឹងអាជ្ញា ជាបណ្ដឹងស្របច្បាប់មួយដែលរដ្ឋទទួលបន្ទុក

ធ្វើបណ្តឹងដោយអយ្យការជាតំណាងដើម្បីធ្វើការចោទប្រកាន់ទៅលើបុគ្គលណាម្នាក់ ដែលបានប្រព្រឹត្តបទល្មើសទាក់ទងនឹងរឿងព្រហ្មទណ្ឌ ។ បណ្តឹងអាជ្ញាមានគោលបំណង ពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពីពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជនល្មើសនោះតាមច្បាប់កំណត់ ។

**ខ. បណ្តឹងរដ្ឋប្បវេណី** ជាបណ្តឹងដែលទាក់ទងនឹងសិទ្ធិឯកជន ឬជាបណ្តឹងដែលទាមទារឱ្យជនប្រព្រឹត្តបទល្មើសជួសជុលសងការខូចខាតផ្នែកសម្ភារៈ ការព្យាបាលរូបរាងកាយ និងការសងជម្ងឺចិត្តទៅតាមភាពជាក់ស្តែងនៃការរងគ្រោះសមល្មមនឹងកំហូចខាតដែលខ្លួនបានបាត់បង់ ។

**<u>សំនួរទី ៣.</u> ដូចម្តេចហៅថាអាជ្ញាយុកាលនៃបទល្មើស? ចូរផ្តល់ឧទាហរណ៍ ២**

**<u>ចម្លើយ</u>** ដែលហៅថា**អាជ្ញាយុកាលនៃបទល្មើស ឬ ជួន**កាលគេហៅថា **អាជ្ញាយុកាលនៃបណ្តឹង** គឺជារយៈពេលដែលច្បាប់កំណត់ឱ្យមានសិទ្ធិធ្វើបណ្តឹងអាជ្ញានិងបណ្តឹងរដ្ឋប្បវេណី ឬជារយៈពេលដែលត្រូវទទួលខុសត្រូវអំពើល្មើសច្បាប់ទាំងបទព្រហ្មទណ្ឌ ទាំងបទរដ្ឋប្បវេណី មាន

ន័យថា បើហួសរយៈពេលកំណត់នោះហើយគេមិនបាន ធ្វើបណ្តឹង ឬគ្មានការចោទប្រកាន់អ្វីមួយនោះ គេមិនអាច ប្តឹងបានទៀតទេ ថេរវេលានៃអាជ្ញាយុកាលនៃបណ្តឹង អាជ្ញាបានបែងចែកជា **បីប្រភេទ** តាមកម្រិតពីទោសធ្ងន់ ទៅទោសស្រាល ដូចជា ១៥ ឆ្នាំចំពោះបទឧក្រិដ្ឋ ៥ឆ្នាំ ចំពោះបទមជ្ឈិម និង ១ ឆ្នាំចំពោះបទលហុ ។

**សំនួរទី ៤. តើសកម្មភាពរបស់ចៅក្រមស៊ើបសួរមាន អ្វីខ្លះ ?**

**ចម្លើយ** សកម្មភាពរបស់ចៅក្រមស៊ើបសួរមាន :

- ការស៊ើបសួរត្រូវតែធ្វើដោយខានមិនបានចំពោះបទឧក្រិដ្ឋ
- ការស៊ើបសួរត្រូវជាការសម្ងាត់ ។
- ចៅក្រមស៊ើបសួរត្រូវមានក្រឡាបញ្ជីម្នាក់អមជានិច្ច ។
- បន្ទាប់ពីការស៊ើបសួររួចចៅក្រមស៊ើបសួរត្រូវរាយការណ៍ ជូនប្រធានតុលាការ និងព្រះរាជអាជ្ញា ដើម្បីធ្វើការ សន្និដ្ឋានជាស្ថាពរ (ចោទប្រកាន់ ឬលើកលែងទោស) ។
- ក្នុងករណីចាំបាច់ការស៊ើបសួរត្រូវចុះដល់ទីកន្លែងនៅលើ វិសាលភាពនៃដែនដីជាតិទាំងមូល ។

☛ <u>សំនួរទី ៥.</u> **តើមន្ត្រីនគរបាលយុត្តិធម៌មានសមាសភាពដូចម្តេចខ្លះ ?**

✍ <u>ចម្លើយ</u> មន្ត្រីនគរបាលយុត្តិធម៌មានសមាសភាពដូចជា :

- ភ្នាក់ងារមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់របស់កងរាជអាវុធហត្ថ និង នគរបាលជាតិ
- អភិបាល អភិបាលរង រាជធានី ខេត្ត ក្រុង ស្រុក/ខណ្ឌ និង មេឃុំ ចៅសង្កាត់។

☛ <u>សំនួរទី ៦.</u> **តើហេតុអ្វីចាំបាច់ត្រូវមាននីតិវិធីឃាត់ខ្លួន និងចាប់ខ្លួន ?**

✍ <u>ចម្លើយ</u> បានជាចាំបាច់ត្រូវមាននិតិវិធីឃាត់ខ្លួនព្រោះដើម្បីធានាបាននូវសណ្តាប់ធ្នាប់សាធារណៈ និង ការគេចវេសរបស់ជនដែលបានប្រព្រឹត្តខុសច្បាប់ ។

☛ <u>សំនួរទី ៧.</u> **តើអ្នកអាចជួយមិត្តភក្តិរបស់អ្នកដូចម្តេចខ្លះ ប្រសិនបើមានមន្ត្រីនគរបាលយុត្តិធម៌ មកឃាត់ខ្លួន ឬ ចាប់ខ្លួនមិត្តភក្តិអ្នក ?**

✍ <u>ចម្លើយ</u> ប្រសិនមានមន្ត្រីនគរបាលយុត្តិធម៌មកឃាត់ខ្លួន ឬចាប់ខ្លួនមិត្តភក្តិរបស់ខ្ញុំ ខ្ញុំត្រូវសុំមើលដីការឃាត់ខ្លួន ឬចាប់ខ្លួនដែលចេញដោយចៅក្រម ឬព្រះរាជអាជ្ញា ថាតើមានឈ្មោះមិត្តខ្ញុំមែនឬមិនមែន ។

***** [illegible] *****

# ៥.៣ មេរៀនទី៥ : ច្បាប់ភូមិបាល

## I. *ចូរបំពេញល្បះឱ្យបានត្រឹមត្រូវ :*

១. អចលនវត្ថុដែលបានកំណត់នៅក្នុងច្បាប់ភូមិបាលមាន 3 ប្រភេទគឺ អចលនវត្ថុ..***ពីកំណើត***..អចលនវត្ថុ.***ពីភ័ព្វវាសនា*** និងអចលនវត្ថុ..***តាមការកំណត់របស់ច្បាប់***...។

## II. សំនួរត្រិះរិះ

☛ <u>សំនួរទី ១.</u> តើច្បាប់ភូមិបាលជាអ្វី ?

✍ <u>ចម្លើយ</u> ច្បាប់ភូមិបាល ជាច្បាប់ដែលកំណត់របបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាការពារសិទ្ធិនៃកម្មសិទ្ធិ និង សិទ្ធិផ្សេងៗទៀតលើអចលនវត្ថុ ។

☛ <u>សំនួរទី ២.</u> តើទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមានអ្វីខ្លះ ? ចូរបង្ហាញភាពខុសគ្នារវាងទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

✍ <u>ចម្លើយ</u> ក. ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមាន :

- ទ្រព្យធនធានធម្មជាតិ មានជាអាទិ៍ ព្រៃឈើ ផ្លូវទឹក បឹងធម្មជាតិ ច្រាំងទន្លេ និងឆ្នេរសមុទ្រ។
- ទ្រព្យដាក់ឱ្យប្រើប្រាស់ជាសាធារណៈមានកំពង់ផែ ផ្លូវទឹក

ព្រលានយន្តហោះ ផ្លូវថ្នល់ ផ្លូវលំ។ល។

- ទ្រព្យទាំងឡាយដែលដាក់ឱ្យដំណើរការជាសាធារណៈ ដូចជា សាលារៀន អគាររដ្ឋបាល និង មន្ទីរពេទ្យជាដើម។
- ទ្រព្យផ្សេងទៀតដែលបង្កើតជាដែនបម្រុងធម្មជាតិ បេតិកភ័ណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ អចលនវត្ថុជាព្រះរាជទ្រព្យដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សានុវង្ស ។

ខ. ភាពខុសគ្នារវាងទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ :

- **ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ** ជាទ្រព្យដែលមានជាប់ផលប្រយោជន៍សាធារណៈ មិនអាចលក់ដូរ មិនអាចកំណត់អាជ្ញាយុកាលបាន ។
- **ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ** ជាទ្រព្យសម្បត្តិទាំងឡាយដែលមិនស្ថិតនៅក្រោមទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងមិនមែនទ្រព្យជាកម្មសិទ្ធិរបស់ឯកជន ឬសមូហភាព។ ទ្រព្យសម្បត្តិនេះអាចលក់ ដូរ បែងចែក ឬផ្ទេរសិទ្ធិបាន តាមការកំណត់ដោយច្បាប់ ។

**<u>សំនួរទី ៣.</u> តើបុគ្គលឯកជនអាចទទួលបានដីដែលបច្ចុប្បន្នត្រូវបានចាត់ថ្នាក់ជាដីរបស់ខ្លួនដែរ ឬទេ ?**

ហេតុអ្វី ?

**ចម្លើយ** បុគ្គលឯកជនមិនអាចទទួលបានដីដែលបច្ចុប្បន្នត្រូវបានចាត់ថ្នាក់ជាដីរបស់រដ្ឋបានទេ ព្រោះអចលនវត្ថុរបស់រដ្ឋទាំងអស់មិនអាចលក់ដូរ ឬធ្វើអំណោយ មិនអាចកាន់កាប់ដោយប្រជាពលរដ្ឋ និងមិនអាចក្លាយជាកម្មសិទ្ធិឯកជនបានឡើយ ។

**សំនួរទី ៤.** ចូរអ្នកអង្កេតស្រាវជ្រាវនៅក្នុងសហគមន៍របស់អ្នក ។ តើសហគមន៍របស់អ្នកមានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋដែរ ឬទេ ? បើមានគឺអ្វីខ្លះ ?

**ចម្លើយ** តាមស្រាវជ្រាវនៅក្នុងសហគមន៍របស់ខ្ញុំមានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋដូចជា ផ្លូវថ្នល់ សួនសាធារណៈ សាលារៀន មន្ទីរពេទ្យ-ល-។

**សំនួរទី ៥.** តើការទិញដីថ្មី ដើម្បីធ្វើលំនៅស្ថានត្រូវមានលក្ខខណ្ឌដូចម្ដេចខ្លះ ?

**ចម្លើយ** ការទិញដីថ្មីដើម្បីធ្វើលំនៅស្ថានត្រូវមានលក្ខខណ្ឌដូចជា ត្រូវធ្វើកិច្ចសន្យាដែលអនុញ្ញាតិឱ្យផ្ទេរកម្មសិទ្ធិនៃអចលនវត្ថុពីអ្នកលក់ទៅអ្នកទិញ និងចុះកិច្ចសន្យាលក់ ឬទិញនៅអង្គភាពសុរិយោដី ។

**សំនួរទី ៦.** តើអំពើណាខ្លះចាត់ទុកជាការប៉ះពាល់កម្ម

***** ***** 

## សិទ្ធិ និងសិទ្ធិស្របច្បាប់ផ្សេងៗទៀតលើអចលនវត្ថុ? តើអំពើទាំងនោះចាត់ទុកជាបទល្មើសប្រភេទណា ?

**ចម្លើយ** អំពើដែលចាត់ទុកជាការប៉ះពាល់កម្មសិទ្ធិ និងសិទ្ធិស្របច្បាប់ផ្សេងៗទៀតលើអចលនវត្ថុ គឺ :

- រាល់អំពើប្រព្រឹត្តដោយជាក់ស្តែងរំលោភកាន់កាប់អចនវត្ថុដោយចេតនា ដោយមិនទទួលស្គាល់ប័ណ្ណចេញដោយរដ្ឋបាលសុរិយោដី
- រាល់ការប្រព្រឹត្តដោយជាក់ស្តែង រារាំអ្នកកាន់កាប់ដោយសន្តិភាព ឬម្ចាស់ទ្រព្យនៅក្នុងតំបន់ដែលមិនទាន់មានប្លង់សុរិយោដី
- រាល់ការចូលកាន់កាប់មិនត្រឹមត្រូវតាមច្បាប់ ឬមិនប្រក្រតីលើអចលនវត្ថុដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ
- រាល់ការបំប្លែងពីសម្បទានមកជាកម្មសិទ្ធិ លើកលែងតែសម្បទានឆ្លើយតបទៅនឹងប្រយោជន៍សង្គម ។

រាល់អំពើទាំងអស់ខាងលើចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ។

# ៩.៣ មេរៀនទី១០ : រដ្ឋបាលសាធារណៈ

## I. សំនួរគ្រឹះៗ

☛ សំនួរទី ១. ដូចម្តេចហៅថា រដ្ឋបាល ? រដ្ឋបាលសាធារណៈ ?

✍ចម្លើយ ដែលហៅថា **រដ្ឋបាល** គឺជាសកម្មភាពនៃការរក្សា និង គ្រប់គ្រង ។

- **រដ្ឋបាលសាធារណៈ** ជាស្ថាប័នទាំងឡាយណាដែលមានក្នុងរដ្ឋនីមួយៗ និង មានតួនាទីបម្រើផលប្រយោជន៍សាធារណៈ ឬ បម្រើផលប្រយោជន៍រួមជាទូទៅ (ស្ថិតក្រោមអង្គការនីតិប្រតិបត្តិ) ។

☛ សំនួរទី ២. តើមានមូលហេតុអ្វីខ្លះ ដែលនាំឱ្យមានការងាររដ្ឋបាលកើតឡើង ?

✍ចម្លើយ មូលហេតុដែលនាំឱ្យមានការងាររដ្ឋបាលកើតឡើង ព្រោះដើម្បីងាយស្រួលក្នុងការចាត់ចែង គ្រប់គ្រង ការដឹកនាំ កិច្ចការទំនាក់ទំនងដោយរាប់ទាំងសណ្តាប់ធ្នាប់ និង វិន័យផងដែរ ។

☛ សំនួរទី ៣. តើរដ្ឋបាលសាធារណៈ និងរដ្ឋបាលឯកជនខុសគ្នាដូចម្តេចខ្លះ ?

✍ <u>**ចម្លើយ**</u> ភាពខុសគ្នារវាង *រដ្ឋបាលសាធារណៈ* និង *រដ្ឋបាលឯកជន* :

- **រដ្ឋបាលសាធារណៈ** បម្រើផលប្រយោជន៍រួមទូទៅ ហើយ ជាទូទៅរដ្ឋបាលសាធារណៈស្ថិតនៅក្រោមការដឹកនាំរបស់អង្គការនីតិប្រតិបត្តិ ។
- **រដ្ឋបាលឯកជន** បម្រើផលប្រយោជន៍រួមសម្រាប់មនុស្សមួយក្រុមតូចតែប៉ុណ្ណោះ ។

☛ <u>**សំនួរទី ៤.**</u> **តើហេតុអ្វីបានជាប្រទេសជាច្រើនលើសកលលោក និងប្រទេសកម្ពុជាយើងធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈ ?**

✍ <u>**ចម្លើយ**</u> បានជាប្រទេសជាច្រើនលើសកលលោក និងប្រទេសកម្ពុជាយើងធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈ ព្រោះ ដើម្បីធ្វើការផ្លាស់ប្តូរ ការគ្រប់គ្រងក្នុងវិស័យសាធារណៈឆ្ពោះទៅរកការគ្រប់គ្រងរដ្ឋបាលសាធារណៈមួយដែលងាយបត់បែន និង ដើម្បីបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ជាពិសេសតម្រូវការចរន្តទីផ្សារសេរី ។

☛ <u>**សំនួរទី ៥.**</u> **ចូរពន្យល់ពីអំណាចរដ្ឋបាលសាធារណៈ ៖**

✍ <u>**ចម្លើយ**</u> អំណាចរដ្ឋបាលសាធារណៈ បម្រើផលប្រយោជន៍រួមទូទៅ ហើយ ជាទូទៅរដ្ឋបាលសាធារណៈស្ថិតនៅ

ក្រោមការដឹកនាំរបស់អង្គការនីតិប្រតិបត្តិ ។

**<u>សំនួរទី ៦.</u> តើហេតុអ្វីបានជាគេថា អំណាចរដ្ឋបាលសាធារណៈ ជាមូលដ្ឋានគ្រឹះនៃសន្តិសុខនិងការអភិវឌ្ឍសង្គម ?**

**<u>ចម្លើយ</u>** បានជាគេថា អំណាចរដ្ឋបាល សាធារណៈ ជាមូលដ្ឋានគ្រឹះនៃសន្តិសុខ និង ការអភិវឌ្ឍសង្គម ព្រោះអំណាចនេះអាចធានាបាននូវសន្តិសុខ សណ្តាប់ធ្នាប់ និង ការអភិវឌ្ឍជានិរន្ត និង ធ្វើអោយសកម្មភាពរបស់ប្រទេសជាតិរស់រវើក ។

**<u>សំនួរទី ៧.</u> តើអ្នកនិងគ្រួសារអ្នកទទួលបានសេវាកម្មអ្វីខ្លះពីរដ្ឋការ ឬ រាជការ ? ចូររៀបរាប់ ៥**

**<u>ចម្លើយ</u>** ខ្ញុំ និងគ្រួសារខ្ញុំបានទទួលសេវាពីរដ្ឋការ គឺ :

- សេវាព្យាបាលជម្ងឺ នៅមន្ទីរពេទ្យរដ្ឋ
- សេវាចាក់វ៉ាក់សាំងការពារជម្ងឺផ្សេងៗ
- សេវាទឹកស្អាត
- សេវាប្រើប្រាស់ភ្លើងអគ្គិសនី...។ល។

## ៤.៣.មេរៀនទី១១ : គណបក្សនយោបាយ និងតួនាទី

## I. សំនួរត្រិះរិះ

**សំនួរទី ១.** តើប្រទេសនីមួយៗបង្កើតគណបក្សនយោបាយដើម្បីអ្វី ?

**ចម្លើយ** ប្រទេសនីមួយៗបង្កើតគណបក្សនយោបាយដើម្បីចូលរួមក្នុងឆាកនយោបាយជាតិតាមរបបប្រជាធិបតេយ្យសេរីពហុបក្ស ដោយការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ស្របតាមការកំណត់នៃរដ្ឋធម្មនុញ្ញ និងច្បាប់ពាក់ព័ន្ធជាធរមាន (ជំពូក ១ មាត្រា ២ នៃច្បាប់ស្តីពី គណបក្សនយោបាយ) ។

**សំនួរទី ២.** ក្នុងចំណោមប្រព័ន្ធបក្សដឹកនាំទាំងបី មាន ទ្វេបក្ស ពហុបក្ស និងឯកបក្ស តើប្រព័ន្ធដឹកនាំបែបណាខ្លះដែលមានលក្ខណៈប្រជាធិបតេយ្យពិតប្រាកដ ? ពីព្រោះអ្វី ? ចំពោះអ្នក តើអ្នកជ្រើសរើសយកប្រព័ន្ធគណបក្សនយោបាយមួយណា ? ហេតុអ្វី ?

**ចម្លើយ** ក្នុងចំណោមប្រព័ន្ធបក្សដឹកនាំទាំងបី មាន

ទ្វេបក្ស ពហុបក្ស និងឯកបក្ស ប្រព័ន្ធបក្សដឹកនាំដែលមានលក្ខណៈប្រជាធិបតេយ្យពិតប្រាកដនោះ គឺ ***ទ្វេបក្ស និងពហុបក្ស*** ។ ពីព្រោះប្រជាពលរដ្ឋមានសិទ្ធិសេរីភាពគ្រប់គ្រាន់ គ្រប់បែបយ៉ាងក្នុងការបោះឆ្នោតជ្រើសរើសតំនាងរបស់ខ្លួនក្នុងគណបក្សនយោបាយណាមួយ ។ លទ្ធិប្រជាធិបតេយ្យលើកទឹកចិត្តប្រជារាស្ត្រអោយចេះគិតដោយខ្លួនឯងហើយបញ្ចេញមតិ និងទស្សនៈរបស់ខ្លួនដោយគ្មានការបង្ខិតបង្ខំទិញទឹកចិត្ត ឬ គម្រាមកំហែងអ្វីឡើយ ។

ចំពោះខ្ញុំ ខ្ញុំជ្រើសរើសយកការបោះឆ្នោតតាមបែបប្រព័ន្ធពហុបក្ស ។ ព្រោះ អត្ថប្រយោជន៍របស់ប្រព័ន្ធពហុបក្ស គឺ ផ្តល់ដល់ម្ចាស់សំលេងឆ្នោតនូវជំរើសប្រកបដោយគំនិតនយោបាយទូលំទូលាយ ។

**<u>សំនួរទី ៣.</u> តើប្រទេសណាខ្លះមានប្រព័ន្ធឯកបក្ស ឬ ទ្វេបក្ស និងពហុបក្ស ? ចូរសិក្សាស្រាវជ្រាវ ៗ**

**<u>ចម្លើយ</u>** . ប្រព័ន្ធឯកបក្ស គឺជាប្រភេទការបោះឆ្នោតដែលមានបក្សតែមួយគត់ នៅក្នុងប្រទេស ។ នៅក្នុងសាធារណរដ្ឋប្រជាមានិតចិន កូរេខាងជើង វៀតណាម

មានគណបក្សតែមួយគត់គឺ គណបក្សកុំមុយនីស ។

- ប្រព័ន្ធទ្វេបក្ស ជាប្រព័ន្ធនយោបាយដែលអនុញ្ញាតឱ្យ មានគណបក្សប្រជែងគ្នា តែពីរគត់នៅក្នុងប្រទេស។ ឧទាហរណ៍ សហរដ្ឋអាមេរិចមានប្រព័ន្ធទ្វេបក្ស តាំងពីថ្ងៃដំបូងនៃកំនើតប្រជាជាតិ ។
- ប្រព័ន្ធពហុបក្ស គឺជាប្រព័ន្ធគណបក្សច្រើនធ្វើការ ប្រកួតប្រជែង ដើម្បីគ្រប់គ្រងរដ្ឋាភិបាល ។ ឧទាហរណ៍ អ៊ីស្រាអែល ជប៉ុន កម្ពុជា ..។

**សំនួរទី ៤. តើនរណាខ្លះមានសិទ្ធិបង្កើតគណបក្សនយោបាយនៅកម្ពុជា ?**

**ចម្លើយ** ប្រជាពលរដ្ឋខ្មែរចំនួនយ៉ាងតិច ៨០ នាក់ ដែល មានអាយុយ៉ាងតិច ១៨ ឆ្នាំ ហើយដែលមានទីលំនៅជា អចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិបង្កើត គណបក្សនយោបាយមួយ ដោយគ្រាន់តែជូនដំណឹងជា លាយលក្ខអក្សរទៅក្រសួងមហាផ្ទៃ (ជំពូក២ មាត្រា៩ ច្បាប់ស្តីពីគណបក្សនយោបាយ )។

**សំនួរទី ៥. តើគណបក្សមួយដែលមានសមាជិកច្រើន នៅក្នុងសភាមានសិទ្ធិដូចម្តេចខ្លះ ?**

**ចម្លើយ** គណបក្សមួយដែលមានសមាជិកច្រើននៅក្នុងសភា មានសិទ្ធិរៀបចំរដ្ឋាភិបាល និងចាត់ចែងការងារផ្សេងៗទៅតាមទិសដៅ និងគោលនយោបាយរបស់បក្សខ្លួន ។

សូមបញ្ជាក់ថា នៅអាណត្តិថ្មីនេះ គឺមានតែគណបក្សប្រជាជនប៉ុណ្ណោះដែលមានសម្លេងយ៉ាងច្រើនលើសលប់ក្នុងសភាជាតិកម្ពុជា ។



# ៥.៧ មេរៀនទី១២ : ការឈរឈ្មោះ និងការបោះឆ្នោត

## I. សំនួរត្រិះរិះ

**សំនួរទី ១.** **តើការបោះឆ្នោតនៅក្នុងប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យមានលក្ខណៈដូចម្តេច ?**

**ចម្លើយ** ការបោះឆ្នោតនៅក្នុងប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យមានលក្ខណៈ *ដូចខាងក្រោម* :

- **លក្ខណៈសេរី** : គ្មានការបង្ខិតបង្ខំគំរាមកំហែង
- **លក្ខណៈត្រឹមត្រូវ** : គ្មានការក្លែងបន្លំសន្លឹកឆ្នោត។
- **លក្ខណៈយុត្តិធម៌** : មានអ្នកសង្កេតការណ៍ពីគ្រប់គណៈបក្សចូលរួម និង មានតំលាភាពអជ្ញាធរបោះឆ្នោតឯករាជ្យ ។
- **លក្ខណៈជាសកល** : បោះឆ្នោតក្នុងថ្ងៃតែមួយទូទាំងប្រទេស ។
- **លក្ខណៈទូទៅ** : ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុ ១៨ ឆ្នាំឡើងមានសិទ្ធិទៅបោះឆ្នោតបានដោយគ្មានការរើសអើង ។
- លក្ខណៈជាសំងាត់ : បោះក្នុងបន្ទប់សំងាត់តែម្នាក់ឯង

- **លក្ខណៈស្មើភាព** : មនុស្សម្នាក់គឺបោះឆ្នោតបានតែមួយសន្លឹកមួយដងគត់ គឺ មានន័យថាមួយសំលេងដូចគ្នា ។
- **លក្ខណៈដោយចំពោះ** : ទៅបោះឆ្នោតដោយខ្លួនឯងផ្ទាល់ពេញចិត្តមួយណាបោះអោយមួយនោះ ។
- **លក្ខណៈទៀងទាត់** : កំនត់ពេលវេលាទៀងទាត់ គឺ រយៈពេល ៥ ឆ្នាំម្តង។

**<u>សំនួរទី ២.</u> ហេតុអ្វីចាំបាច់ត្រូវមានការបោះឆ្នោត ?**

**<u>ចម្លើយ</u>** បានជាចាំបាច់ត្រូវមានការបោះឆ្នោត ព្រោះ **ក្នុងលទ្ធិប្រជាធិបតេយ្យ** ប្រជារាស្ត្រ គឺជាម្ចាស់ទឹកដី ម្ចាស់លើជោគវាសនារបស់ប្រទេសជាតិ។ ប្រជារាស្ត្រ ជាអ្នកទទួលខុសត្រូវលើអនាគតរបស់ប្រទេស ។ ប៉ុន្តែ ប្រជារាស្ត្រទាំងអស់មិនអាចទៅចាត់ចែងកិច្ចការរដ្ឋ ដោយផ្ទាល់ទាំងអស់គ្នាបានទេ គឺ ត្រូវជ្រើសរើស បេក្ខជនដែលខ្លួនពេញចិត្តម្នាក់ ឬ ច្រើនធ្វើជាតំណាង អោយខ្លួនហៅថា តំណាងរាស្ត្រដើម្បីទៅចាត់ចែង កិច្ចការរដ្ឋជំនួស ។ ការជ្រើសរើសនេះត្រូវឆ្លងកាត់តាម រយៈការបោះឆ្នោត ដែលមានលក្ខណៈដោយសេរី

ត្រឹមត្រូវ និងយុត្តិធម៌ ។

- ជាការអនុវត្តតាមលិទ្ធិប្រជាធិបតេយ្យពិតៗ ។
- ជាសេរីភាពក្នុងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ ។
- ដើម្បីបណ្តុះពូជលទ្ធិប្រជាធិបតេយ្យ ។
- មានរបបពហុបក្ស នាំទៅដល់ការអភិវឌ្ឍន៍ ។
- ការបោះឆ្នោតជួយឱ្យមានបំលាស់ប្តូរអ្នកដឹកនាំដោយសន្តិវិធីតាមផ្លូវច្បាប់ គឺ បញ្ចៀសការដណ្តើម ឬ ការប្រជែងអំនាចគ្នាដោយអាវុធ ឬ ហិង្សា ឬ តាមរយៈបក្សពួកនិយម ។
- អោយមានស្ថិរភាពខាងនយោបាយ សេដ្ឋកិច្ច និងសន្តិសុខ ។
- ការបោះឆ្នោតបានល្អសេរី យុត្តិធម៌ នាំអោយមានការទទួលស្គាល់ពីសហគមន៍ជាតិ និងសហគមន៍អន្តរជាតិ ។

☛ **<u>សំនួរទី ៣.</u> តើនៅប្រទេសកម្ពុជាមានការបោះឆ្នោតអ្វីខ្លះ ? ចូររៀបរាប់ ។**

✍ **<u>ចម្លើយ</u>** នៅប្រទេសកម្ពុជាមានការបោះឆ្នោត**ពីរប្រភេទ**

**គឺ** ***ការបោះឆ្នោតជាសកល*** **និង** ***ការបោះឆ្នោតជាអសកល***

ក. ***ការបោះឆ្នោតជាសកល*** មាន :

- ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ
- ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់

ខ. ***ការបោះឆ្នោតជាអសកល*** មាន :

- ការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា
- ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាធម្មនុញ្ញ

**សំនួរទី ៤.** **ចូរបង្ហាញសារៈសំខាន់នៃការបោះឆ្នោត ព្រមទាំងលើកឧទាហរណ៍មកបញ្ជាក់ ២**

**ចម្លើយ** សារៈសំខាន់នៃការបោះឆ្នោត :

- បង្ហាញពីសេរីភាពក្នុងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ ។
- ការបោះឆ្នោតជួយឱ្យមានបំលាស់ប្ដូរអ្នកដឹកនាំដោយសន្តិវិធីតាមផ្លូវច្បាប់ គឺ បញ្ចៀសការដណ្ដើម ឬ កប្រជែងអំណាចគ្នាដោយអាវុធ ឬ ហិង្សា ឬ តាមរយៈបក្សពួកនិយម ។
- ធ្វើឱ្យមានឥទ្ធិពលទៅលើអ្នកដឹកនាំ ឬ រដ្ឋាភិបាល

(ត្រូវសភាបោះឆ្នោតទម្លាក់ ឬ ប្រជារាស្ត្រដកសេចក្តីទុកចិត្តតាមរយៈសន្លឹកឆ្នោតនៅអាណត្តិក្រោយ)

- ធ្វើឱ្យមានការទទួលខុសត្រូវខ្ពស់ចំពោះអ្នកជាក់ឆ្នោតដែលហៅថាតំណាងរាស្ត្រ ។
- អោយមានស្ថិរភាពខាងនយោបាយ សេដ្ឋកិច្ច និងសន្តិសុខ ។
- ការបោះឆ្នោតបានល្អសេរី យុត្តិធម៌ នាំអោយមានការទទួលស្គាល់ពីសហគមន៍ជាតិ និងសហគមន៍អន្តរជាតិ
- បង្ហាញពីការអនុវត្តតាមលិទ្ធិប្រជាធិបតេយ្យពិតៗ
- មានការបោះឆ្នោត នាំទៅដល់ការអភិវឌ្ឍន៍ជាតិ ។

**ឧទាហរណ៍** ប្រសិនបើរដ្ឋាភិបាល ឬអ្នកដឹកនាំណាដែលមិនបានធ្វើឱ្យប្រទេសជាតិមានការរីកចម្រើនទេនោះនឹងត្រូវសភាបោះឆ្នោតទម្លាក់ ឬ ប្រជារាស្ត្រដកសេចក្តីទុកចិត្តតាមរយៈសន្លឹកឆ្នោតនៅអាណត្តិក្រោយ ។

☛ <u>សំនួរទី ៥.</u> តើគោលការណ៍សំខាន់ៗសម្រាប់អ្នកបោះឆ្នោតមានអ្វីខ្លះ ?

**ចម្លើយ** គោលការណ៍សំខាន់ៗសម្រាប់អ្នកបោះឆ្នោតមាន :

- មានសិទ្ធិទទួលពត៌មានដំណើរការបោះឆ្នោតដោយតម្លាភាព
- មានសិទ្ធិចូលរួមប្រជុំ និងបញ្ចេញមតិដោយសេរី
- ពិភាក្សាអំពីបេក្ខជន ឬបេក្ខនារី និងគណបក្សនយោបាយដែលបានឈរឈ្មោះប្រកួតប្រជែង ។

**សំនួរទី ៦.** ចូរប្រៀបធៀបលក្ខណៈខុសគ្នារវាងការបោះឆ្នោតជាសកល និងការបោះឆ្នោតអសកលៈ

**ចម្លើយ** ការបោះឆ្នោតជ្រើសតាំងសមាជិក*រដ្ឋសភា* ឬ សកល និង ការបោះឆ្នោតជ្រើសតាំង*ព្រឹទ្ធសភា* អសកលមានចំនុចខុសគ្នាដូចតទៅ :

| រដ្ឋសភា ឬ សកល | ព្រឹទ្ធសភា ឬ អសកល |
|---|---|
| - ជ្រើសរើសតំនាងរាស្ត្រជាសមាជិករដ្ឋសភា ឬ ក្រុមប្រឹក្សាឃុំ សង្កាត់ ។ | - ជ្រើសរើសសមាជិកព្រឹទ្ធសភា ។ |
| - សមាជិករដ្ឋសភា ឬតំណាង | - អាយុយ៉ាងតិច ៤០ឆ្នាំ ។ |

| | |
|---|---|
| ភាស្ត្រូវមានអាយុយ៉ាងតិច ២៥ឆ្នាំ ។ | |
| - បោះឆ្នោតជាសកល ។ | បោះឆ្នោតជាអសកល តាមចំណាត់តាំង :<br>+ ពីររូបត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ។<br>+ ពីររូបទៀតត្រូវបោះឆ្នោតជាអសកល ។ |
| - សមាជិកនៅអាណត្តិទី៣ គឺ ១២៣រូប ។ | - មានចំនួនស្មើនឹងចំនួនពាក់កណ្តាលនៃសមាជិករដ្ឋសភា គឺ ៦១រូប។ |
| - នីតិកាល ៥ ឆ្នាំម្តង ។ | - ៦ ឆ្នាំម្តង ។ |
| - បោះឆ្នោតដោយប្រជាពលរដ្ឋទូទាំងប្រទេស។ | - បោះបានតែសមាជិកសភា គណៈបក្សនយោបាយ ឬ ក្រុមប្រឹក្សាឃុំ សង្កាត់ ។ |
| - ប្រជាពលរដ្ឋជាអ្នកបោះដោយផ្ទាល់ និង ដោយ | - ការបោះឆ្នោតមានលក្ខណៈជាប្រយោលមិនចំពោះទេ។ |

ចំពោះ៖

| | |
|---|---|
| - យកខេត្ត ក្រុងធ្វើជាកន្លែងប្រជុំមណ្ឌលបោះឆ្នោត។ | - យកភូមិភាគធ្វើជាកន្លែងប្រមូលផ្ដុំមណ្ឌលបោះឆ្នោត។ |
| - យុទ្ធនាការផ្សព្វផ្សាយឃោសនាមានរយៈពេល ៣០ ថ្ងៃ ។ | - រយៈពេលផ្សព្វផ្សាយឃោសនាមានរយៈពេល ២១ ថ្ងៃ ។ |

**សំនួរទី ៧. តើគេត្រូវធ្វើដូចម្ដេច ដើម្បីលើកទឹកចិត្តស្ត្រីឱ្យចូលរួមឈរឈ្មោះបោះឆ្នោតធ្វើជាអ្នកដឹកនាំ ?**

**ចម្លើយ** ដើម្បីលើកទឹកចិត្តស្ត្រីឱ្យចូលរួមឈរឈ្មោះបោះឆ្នោតធ្វើជាអ្នកដឹកនាំ យើងត្រូវគាំទ្រ និងផ្ដល់សិទ្ធិសេរីភាពឱ្យស្ត្រីដោយលើកតម្លៃឱ្យមានសិទ្ធិស្មើនឹងបុរស និងផ្ដល់ឱ្យស្ត្រីបានចូលរួមធ្វើការក្នុងសង្គមឱ្យបានច្រើន និងជាពិសេសបញ្ជាក់ប្រាប់ស្ត្រីថា ស្ត្រីក៏អាចក្លាយជាអ្នកដឹកនាំបានដែរ ហើយត្រូវលើកឧទាហរណ៍ប្រាប់ជាក់ស្ដែងពីអ្នកដឹកនាំដែលជាស្ត្រីណាម្នាក់នៅក្នុងសង្គម ម្យ៉ាងទៀតត្រូវពន្យល់ប្រាប់គាត់ឱ្យយល់ច្បាស់ពីសិទ្ធិ

មនុស្ស នោះទើបអាចឱ្យគាត់ហ៊ានសម្រេចចិត្តសាកល្បង ។

**សំនួរទី ៨.** តើការចូលរួមរបស់យុវជនក្នុងការបោះឆ្នោតមានសារៈសំខាន់ដែរ ឬទេ ? ព្រោះអ្វី ?

**ចម្លើយ** ការចូលរួមរបស់យុវជនក្នុងការបោះឆ្នោតមានសារៈសំខាន់ណាស់ ព្រោះ :

- យុវជនជាសរសរទ្រូង និងជាទំពាំងស្នងឫស្សីរបស់ប្រទេសជាតិ ។
- យុវជនមានប្រាជ្ញាវាងវៃឆ្លាត មានគំនិតជ្រាលជ្រៅដឹងអ្វីខុសដឹងអ្វីត្រូវ ។
- យុវជនជាអ្នកសម្រេចចិត្តផ្ទាល់ក្នុងការជ្រើសរើសអ្នកដឹកនាំ ។

**សំនួរទី ៩.** ប្រសិនបើអ្នកមិនបានទៅបោះឆ្នោត តើវានឹងមានអ្វីកើតឡើងដល់អ្នក ?

**ចម្លើយ** ប្រសិនបើខ្ញុំមិនបានទៅបោះឆ្នោត វានឹងធ្វើឱ្យខ្ញុំមានអារម្មណ៍ថា សោកស្តាយក្រៃលែង ព្រោះមិនបានបំពេញកាតព្វកិច្ចជាប្រជាពលរដ្ឋម្នាក់ បាត់បង់ឱកាសជាប្រជាពលរដ្ឋ បាត់បង់សិទ្ធិនយោបាយ និងមិនបាន

បង្ហាញពីឆន្ទៈរបស់ខ្លួន ។

**សំនួរទី ១០.** ហេតុអ្វីបានជាគេនិយាយថា ការបោះឆ្នោតមិនគ្រាន់តែជាសិទ្ធិ និងការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋទេ តែវាជាវិធីមួយដ៏ល្អដើម្បីជម្រុញឱ្យអ្នកដឹកនាំគិតគូរពីជីវភាព សុខុមាលភាពរបស់ប្រជាពលរដ្ឋ ? ចូរពន្យល់ ៗ

**ចម្លើយ** បានជាគេនិយាយថា ការបោះឆ្នោតមិនគ្រាន់តែជាសិទ្ធិ និង ការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋទេ តែវាជាវិធីមួយដ៏ល្អដើម្បីជម្រុញឱ្យអ្នកដឹកនាំគិតគូរពីជីវភាព សុខុមាលភាពរបស់ប្រជាពលរដ្ឋ ព្រោះនៅពេលបោះឆ្នោតគណបក្សនិមួយៗតែងតែបានសន្យាធ្វើនូវអ្វីៗដែលប្រជាពលរដ្ឋបានស្នើសុំ ដូចនេះនៅពេលគណបក្សមួយណាបានឈ្នះឆ្នោតនោះពួកគេក៏បានគិតគូរពីបញ្ហាទាំងឡាយដែលចោទមាននៅក្នុងប្រទេស ដែលជាក់ស្តែងប្រទេសកម្ពុជាបន្ទាប់ពីបោះឆ្នោតចប់រាជរដ្ឋាភិបាលបានគិតគូរពីជីវភាព សុខមាលភាពរបស់ប្រជាពលរដ្ឋជាខ្លាំង នេះដោយសារការបោះឆ្នោតមានឥទ្ធិពលដល់រដ្ឋាភិបាល ។

**សំនួរទី ១១.** អ្នកកំពុងចូលរួមក្នុងយុទ្ធនាការឃោសនារកសំឡេងឆ្នោតឱ្យបេក្ខជនម្នាក់ ឈរឈ្មោះឱ្យគេបោះឆ្នោត ។ កិច្ចការដែលអ្នកត្រូវធ្វើ គឺសរសេរខិតប័ណ្ណមួយរកដំណោះស្រាយបញ្ហាដែលកំពុងចោទឡើងនៅក្នុងសហគមន៍ ។ តើអ្នកត្រូវសរសេរពន្យល់ដោះស្រាយបញ្ហានោះដូចម្ដេច ? អ្វីដែលអ្នកសរសេរត្រូវតែទាក់ទាញអ្នកបោះឆ្នោតឱ្យគាំទ្របេក្ខជននោះ ។

**ចម្លើយ** សាកល្បងឆ្លើយដោយខ្លួនឯង ។

**សំនួរទី ១២.** តើប្រជាពលរដ្ឋទាំងពីរភេទអាចឈរឈ្មោះឱ្យគេបោះឆ្នោតជាតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភាត្រូវគោរពលក្ខខណ្ឌអ្វីខ្លះ ?

**ចម្លើយ** ប្រជាពលរដ្ឋទាំងពីរភេទអាចឈរឈ្មោះឱ្យគេបោះឆ្នោតជាតំណាងរាស្ត្រ និង សមាជិកព្រឹទ្ធសភាត្រូវគោរពលក្ខខណ្ឌដូចខាងក្រោម :

១. មានសញ្ជាតិខ្មែរពីកំណើត

២. មានអាយុ 25 ឆ្នាំឡើងទៅចំពោះបេក្ខជនតំណាង

រាស្ត្រ ហើយអាយុ 40 ឆ្នាំចំពោះបេក្ខជនសមាជិក
ព្រឹទ្ធសភាដោយគិតដល់ថ្ងៃបោះឆ្នោត

៣. មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត

៤. ស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជាយ៉ាងតិចមួយឆ្នាំគិតដល់ថ្ងៃបោះឆ្នោត

៥. មានការតែងតាំងពីគណបក្សនយោបាយ ដែលបានចុះបញ្ជីឈ្មោះបោះឆ្នោត ។

(មាត្រា ៣៣ នៃច្បាប់បោះឆ្នោត)



# ? សំណួរបញ្ចប់ជំពូក ៣

## I. ចូរគូសសញ្ញា✓ ក្នុងប្រអប់ខាងមុខចម្លើយដែលត្រឹមត្រូវ

១. តើប្រជាពលរដ្ឋទាំងពីរភេទមានអាយុប៉ុន្មានឆ្នាំ ទើបមានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតធ្វើតំណាងរាស្ត្រ ?

☐ក. ២០ ឆ្នាំ ☐ខ. ១៨ ឆ្នាំ ☑គ. ២៥ ឆ្នាំ ☐ឃ. ២២ឆ្នាំ។

២. នៅពេលមានប៉ូលីសត្រូវចាប់ខ្លួននរណាម្នាក់ អ្នកនោះត្រូវ

☐ក. សុំពន្យាពេលចាប់ខ្លួន ☐ខ. សុំរកអ្នកធានា

☑គ. សុំមើលដីកា ☐ឃ. សុំរកជួបសាច់ញាតិ ។

៣. តើអ្នកណាជាអ្នកចេញដីកាសម្រេចឱ្យចាប់ខ្លួន ឃុំខ្លួនជនល្មើស ?

☐ក. ចៅក្រមជំនុំជម្រះ ☐ខ. ព្រះរាជអាជ្ញា

☑គ. ចៅក្រមស៊ើបសួរ ☐ឃ. អគ្គព្រះរាជអាជ្ញា ។

## II. ចូរផ្គូផ្គងពាក្យក្នុងប្រអប់ ផ្នែក ក ទៅនឹងអត្ថន័យផ្នែក ខ ឱ្យបានត្រឹមត្រូវ

| ក | ខ | ចម្លើយ |
|---|---|---|
| ១. ពាក្យសុំឱ្យពិនិត្យឡើងវិញចំពោះសាលក្រម ឬសាលដីកា | ក. បណ្ដឹងរដ្ឋប្បវេណី | ១.> ង |
| ២. ពាក្យទាមទារឱ្យមានសងការអន្តរាយ | ខ. បណ្ដឹងសាទុក្ខ | ២.> ក |
| | គ. បណ្ដឹងអាជ្ញា | ៣.> ខ |

| | | |
|---|---|---|
| ទាំងសម្ភារៈទាំងជម្ងឺចិត្ត<br>៣. ពាក្យសុំតវ៉ា ឬបដិសេធសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍<br>៤. បណ្ដឹងសុំឱ្យផ្ដន្ទាទោសពិន័យជាប្រាក់ និងដាក់ពន្ធនាគារ | ឃ. បណ្ដឹងជំទាស់<br>ង. បណ្ដឹងឧទ្ធរណ៍<br>ច. បណ្ដឹងសើរើ | ៤.> គ |

III. បំពេញល្បះចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

១. សេចក្ដីសម្រេចរបស់សាលាជម្រះក្ដីជាន់ខ្ពស់មានសាលាឧទ្ធរណ៍ និងតុលាការកំពូលហៅថា..*ការសម្រេចសាលក្រម*..។

២. អាយុអប្បបរមាដែលកុមារអាចចូលធ្វើតែការងារស្រាលៗបានក្នុងលក្ខខណ្ឌនៃការធានាសុខភាព សន្តិសុខ និងសីលធម៌ គឺ..*មានអាយុតិចជាង ១៥ ឆ្នាំ*..។

IV. **ចូររកការទទួលខុសត្រូវ ដែលមានទំនាក់ទំនងជាមួយសិទ្ធិបញ្ចេញមតិ សិទ្ធិមានកម្មសិទ្ធិផ្ទាល់ខ្លួន សិទ្ធិក្នុងការលេងកីឡា សិទ្ធិធ្វើការងារ និងសិទ្ធិគោរពជំនឿសាសនា ?**

✍ <u>ចម្លើយ</u> - ការទទួលខុសត្រូវដែលមានក្នុងសិទ្ធិ

បញ្ចេញមតិ គឺនៅពេលដែលខ្ញុំបញ្ចេញមតិ និង បង្ហាញម្តងៗសុទ្ធតែជាការពិត

- ការទទួលខុសត្រូវដែលមានក្នុងសិទ្ធិមានកម្មសិទ្ធិផ្ទាល់ខ្លួន គឺខ្ញុំមានសិទ្ធិទិញរបស់របរផ្ទាល់ខ្លួនតាមតម្រូវការ និងរក្សាសុវត្ថិភាពកម្មសិទ្ធិផ្ទាល់របស់ខ្ញុំកុំឱ្យបាត់បង់
- ការទទួលខុសត្រូវដែលមានក្នុងសិទ្ធិដើរលេងកំសាន្ត គឺខ្ញុំមានសិទ្ធិសេរីភាពដើរលំហែកាយគ្រប់ទីកន្លែង ខ្ញុំត្រូវគិតពីបរិស្ថានជាចំបង ។
- ការទទួលខុសត្រូវដែលមានក្នុងសិទ្ធិធ្វើការងារ និងសិទ្ធិគោរពសាសនា គឺខ្ញុំត្រូវបំពេញការងារឱ្យបានត្រឹមត្រូវ និងគោរពសាសនារបស់ខ្ញុំ ទោះបីខ្ញុំធ្វើការជាមួយអ្នកកាន់សាសនាដទៃក៏ដោយ ។

**V. តាមមាគ៌ានៃការអប់រំព្រះពុទ្ធសាសនា តើមនុស្សម្នាក់ៗត្រូវចេះប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួន និងគោរពសេរីភាពអ្នកដទៃដូចម្តេចខ្លះ ?**

**ចម្លើយ** តាមមាគ៌ានៃការអប់រំព្រះពុទ្ធសាសនា មនុស្សម្នាក់ៗត្រូវចេះប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួន និង គោរពសេរីភាពអ្នកដទៃដូចជា ត្រូវចេះប្រើសិទ្ធិរបស់ខ្លួនឱ្យបានស្របច្បាប់ និងមិនត្រូវបៀតបៀនអ្នកដទៃឡើយ និងជាពិសេសត្រូវចេះគោរពសិទ្ធិអ្នកដទៃដែលវាជាផ្លូវនាំទៅរកសេចក្ដីសុខ និង សន្តិភាពគ្រប់ៗគ្នា ។



# ចប់

# និងពរសំណាងល្អ !



សុ_ចិ_បុ_ណិ !